ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩**

**សវនាការលើកទី២៨**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា

លោក វីលៀម ស្មីត *(Mr. William SMITH)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំប៉ែល *(Zachery LAMPELL)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ**

លោក ហ្វ្រង់ស្វ័រ រូ (*François Roux)*

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឹន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក គង់ ពិសី

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទូត ហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី ៖** ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ....................................................................ទំព័រ ៥
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី .....................................................ទំព័រ ៣៩
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ......................................................ទំព័រ ៥១

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| លោក វីលៀម ស្មីត | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ-បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:១៥:00]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តនីតិវិធីសវនាការដេញដោលលើអង្គហេតុប្រតិបត្តិការស-២១ ព្រមទាំងជើងឯកផងដែរ ។ មុននឹងដំណើរការនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនដែលបានចូលរួម បានជ្រាបថា អង្គជំនុំជម្រះមានការយឺតដប់មីនុត ក្នុងការចូលមកផ្ដើមដំណើរការសវនាការនៅព្រឹកនេះ ដោយមានបញ្ហាផ្នែកខាងបច្ចេកទេសផ្នែកខាងសោតទស្សន៍ និងកុំព្យូទ័រ ដែលនាំឲ្យមានការអាក់ខាន យឺតពេលក្នុងការផ្ដើមដំណើរការសវនាការអស់ដប់មីនុតនេះ ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី ដែលត្រូវចូលរួមនៅក្នុងនីតិវិធីសវនាការដេញដោលនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលបានចូលរួម នៅក្នុងដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទមកកាន់ ឈើរាងវង់ក្រចកសេះនៅទីនេះ ។

មុននឹងឈានចូលដល់ធ្វើនីតិវិធីពិភាក្សាដេញដោលលើអង្គហេតុប្រតិបត្តិការស-២១ រួមទាំងជើងឯកផងនោះ អង្គជំនុំជម្រះឆ្លៀតឱកាសនេះ ធ្វើសេចក្ដីប្រកាស លើសេចក្ដីសម្រេចលើសំណើរបស់ភាគីមេធាវីការពារក្ដី ដែលស្នើសុំឲ្យដោះលែងជនជាប់ចោទនៅក្រៅឃុំបណ្ដោះអាសន្ន ហើយនិងទីពីរជម្រាបអំពីលទ្ធផលនៃកិច្ចប្រជុំរៀបចំដំណើរការសវនាការ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ដែលអង្គជំនុំជម្រះមានបំណងជម្រាបជូនដល់ភាគីពាក់ព័ន្ធក្នុងកិច្ចដំណើរការសវនាការ ។

អង្គជំនុំជម្រះសាលាដំបូង សូមធ្វើការប្រកាសនូវសេចក្ដីសម្រេចដែលអង្គជំនុំជម្រះសាលាដំបូងត្រូវចេញទាក់ទងនឹងសំណើសុំដោះលែងជនជាប់ចោទ គឺឥឡូវនេះ កំពុងត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងហើយ ។ សាធារណជននិងភាគីនៃរឿងក្ដី អាចទទួលបាននូវព័ត៌មាននៃសេចក្ដីសម្រេចទាំងស្រុងជាលាយលក្ខណ៍អក្សរនាពេលដ៏ខ្លីខាងមុខនេះ តាមគេហទំព័រនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ

កម្ពុជា ។ ទោះជាបែបនេះក្តី ដើម្បីជាផលប្រយោជន៍នៃការស្វែងរកយុត្តិធម៌នោះ អង្គជំនុំជម្រះសាលាដំបូង សូមធ្វើការប្រកាសនូវផ្នែកនៃសេចក្តីសម្រេចរបស់ខ្លួនដូចខាងក្រោម៖

អង្គជំនុំជម្រះសាលាដំបូង សម្រេចបដិសេធសំណើដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំនេះ។ បង្គាប់ថា ជនជាប់ចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួនជាបន្តទៀតនៅក្នុងអំឡុងពេលសវនាការ ។ រកឃើញថា ការឃុំខ្លួនជនជាប់ចោទ ដោយតុលាការយោធា គឺជាកំហុសក្នុងការអនុវត្តច្បាប់នីតិវិធី រំលោភលើសិទ្ធិរបស់ជនជាប់ចោទ ។ ដូច្នេះ ហើយការឃុំខ្លួននេះមិនត្រឹមត្រូវតាមច្បាប់ទេ ។

ប្រកាសថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់តុលាការយោធា និងចំពោះការរំលោភលើសិទ្ធិរបស់គាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានិងតាមច្បាប់អន្តរជាតិទូទៅ ។

កត់សម្គាល់ថា ប្រសិនបើត្រូវបានសម្រេចឲ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់នោះ ជនជាប់ចោទអាចទាមទារសំណងសមស្រប ចំពោះរយៈពេលដែលត្រូវបានឃុំខ្លួននៅតុលាការយោធា និងចំពោះការរលោភសិទ្ធិរបស់គាត់នៅតុលាការជាតិ ។

ប្រកាសថា ប្រសិនបើរកឃើញថា មានពិរុទ្ធភាពនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺចាប់តាំងពី ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ដោយអនុលោមតាមមាត្រា៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ។

ប្រកាសបន្ថែមថា ប្រសិនបើរកឃើញថាមានពិរុទ្ធភាពនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់រយៈពេល ដែលជនជាប់ចោទត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់តុលាការយោធា គឺចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ។

រក្សាទុកសិទ្ធិបញ្ហានៃចរិតលក្ខណៈនិងទំហំនៃសំណងបន្ថែម ដែលជាបច្ច័យនៃការរំលោភសិទ្ធិរបស់ជនជាប់ចោទដល់អង្គជំនុំជម្រះ ដើម្បីពិចារណានៅពេលធ្វើសេចក្តីសម្រេចអំពីទោស ប្រសិនបើត្រូវយកមកពិចារណា ។ ភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ។

ប្រធានអង្គជំនុំជម្រះសាលាដំបូង ហត្ថលេខា និងត្រា និល ណុន ។

[០៩:២៣:៥៣]

ជាកិច្ចបន្ត គឺអង្គជំនុំជម្រះសូមប្រកាសអំពីលទ្ធផលនៃកិច្ចប្រជុំរៀបចំដំណើរការសវនាការដែលបានធ្វើកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ដែលអង្គជំនុំជម្រះ មានបំណងជម្រាបជូនដល់ភាគីទាក់ទងទៅនឹងកិច្ចប្រជុំរៀបចំសវនាការនេះ ។

ដើម្បីជាកិច្ចបន្តនេះ អង្គជំនុំជម្រះខ្ញុំសូមប្រគល់ភារៈនេះជូនទៅលោកស្រីចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍ ដើម្បីលោកស្រីជម្រាបអំពីលទ្ធផលនៃកិច្ចប្រជុំរបស់អង្គជំនុំជម្រះ ជូនដល់ភាគីដែលត្រូវចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន ។ ដូចដែលលោកប្រធាន មានប្រសាសន៍អម្បាញ់មិញអ៊ីចឹង គឺមានកិច្ចប្រជុំរៀបចំសវនាការមួយ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ។ ហើយអង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងដល់សាធារណជននិងភាគីពាក់ព័ន្ធទាំងអស់ អំពីនីតិវិធីដែលធ្វើដូចខាងក្រោមនេះ គឺនឹងអាចមានព័ត៌មានបន្ថែមទៀត ដែលនឹងអាចផ្តល់ជូននៅពេលក្រោយ ។

ដំបូង អង្គជំនុំជម្រះសាលសដំបូងបានកត់ត្រាយ៉ាងយកចិត្តទុកដាក់នូវរាល់ការលើកឡើងរបស់ភាគីទាំងអស់ ទាក់ទងនឹងការកំណត់ចិរវេលា នៃការបញ្ចប់ការពិភាក្សាដេញដោលបង្ហាញភស្តុតាងលើសំណុំរឿងលេខ០០១នេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ជាពិសេស អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញថា ភាគីនានាបានលើកឡើងជាគំនិតថា ជាការពិភាក្សាដេញដោលក្នុងការបង្ហាញភស្តុតាង ដែលអាចនឹងបានបញ្ចប់នៅវវាងខែសីហា និងខែធ្នូ ឆ្នាំ២០០៩ ។ ដូច្នេះ ហើយអង្គជំនុំជម្រះសាលាដំបូងកំពុងធ្វើការពិនិត្យនូវកាលវិភាគសវនាការ និងលទ្ធភាពធ្វើយ៉ាងណាដើម្បីដោះស្រាយនូវបញ្ហាទាំងនេះដើម្បីជាប្រយោជន៍ដល់ការជំនុំជម្រះ ដែលថាអាចនឹងបញ្ចប់បានឆាប់ដោយរក្សាបាននូវកិច្ចដំណើរការនីតិវិធីមួយ ប្រកបដោយភាពយុត្តិធម៌ ។

ដោយហេតុថា នៅដំណាក់កាលនេះ អង្គជំនុំជម្រះសាលាដំបូង មិនទាន់អាចកំណត់បាននូវកាលបរិច្ឆេទជាក់លាក់ពីការបញ្ចប់នីតិវិធីនៃការដេញដោលនៅឡើយ និងការបង្ហាញភស្តុតាងនោះ អង្គជំនុំជម្រះ នឹងធ្វើការកំណត់នូវការបែងចែកម៉ោង និងពេលវេលា សម្រាប់និយាយដល់ភាគីពាក់ព័ន្ធនានា ។ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់នូវចិរវេលាសមស្របមួយ សម្រាប់ភាគីក្នុងការសួរដេញដោលដល់សាក្សីនីមួយៗ។ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ទៅតាមករណីនីមួយៗនូវចិរវេលាសម

ស្របសម្រាប់ភាគី ក្នុងការសួរដេញដោលដល់សាក្សីនីមួយៗ ។

អង្គជំនុំជម្រះសូមជូនជាគំនិតដែលខ្លួនគិតថា ជាទូទៅ គឺសមស្របសម្រាប់ភាគីត្រៀមខ្លួនក្នុងការតាំងសំណួរដល់សាក្សី និងការធ្វើសេចក្តីសន្និដ្ឋាន ដូចតទៅ៖

ដំបូង ការតាំងសំណួរដល់សាក្សី ជាទូទៅ គឺពេលវេលាសាមសិបនាទី សម្រាប់ការិយាល័យសហព្រះរាជអាជ្ញា ។ សែសិបនាទីសម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ គឺទាំងបួនក្រុម និងសែសិបនាទីសម្រាប់ក្រុមមេធាវីការពារក្តី ។

ទីពីរ ការធ្វើសេចក្តីសន្និដ្ឋាន អង្គជំនុំជម្រះនឹងអនុញ្ញាតពេលវេលាពីប្រាំទៅដប់នាទី សម្រាប់ការតាំងសំណួរ និងសម្រាប់ធ្វើការបដិសេធ និងប្រាំនាទីទៀតសម្រាប់ធ្វើការឆ្លើយតប ។ ជាវិធានទូទៅចិរវេលា ដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងមិនអាចជាកម្មវត្ថុនៃការជជែកតវ៉ាដល់ភាគីដែលនាំឱ្យអូសបន្លាយដល់ពេលវេលានោះឡើយ ។ ការកំណត់ពេលវេលាសែសិបនាទី សម្រាប់មេធាវីទាំងអស់ហ្នឹង គឺសម្រាប់ទាំងបួនក្រុមយកទៅធ្វើការបែងចែកគ្នា ។ ហើយអង្គជំនុំជម្រះដំបូង សូមផ្តល់ជាយោបល់ថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមអាចធ្វើការជ្រើសតាំងតាមលក្ខណៈវិលជុំនូវមេធាវីខ្មែរម្នាក់និងមេធាវីបរទេសម្នាក់ តំណាងឱ្យមេធាវីទាំងបួនក្រុម ក្នុងការតាំងសំណួរដល់សាក្សីនីមួយៗ ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងសូមសង្កត់បញ្ជាក់ថា នេះគឺគ្រាន់តែជាយោបល់របស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ សម្រាប់ការបែងចែកពេលវេលាសែសិបនាទីនេះ ។

អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការផ្លាស់ប្តូរចំនួនថ្ងៃជំនុំជម្រះរបស់ខ្លួន ក្នុងគោលបំណងដើម្បីឱ្យមានពេលវេលាបន្ថែមមួយថ្ងៃទៀតក្នុងមួយខែ ។

នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះចង់ធ្វើការពន្យល់ដល់សាធារណជន និងធ្វើការបញ្ជាក់ថាកិច្ចការភាគច្រើនរបស់អង្គជំនុំជម្រះគឺធ្វើឡើងនៅក្រៅបន្ទប់សវនាការ រួមបញ្ចូលទាំងការរៀបចំសវនាការការពិភាក្សាលើបញ្ហាដែលស្នើឡើងដោយភាគី ការធ្វើសេចក្តីព្រាងលើសេចក្តីសម្រេចនានា និងការបកប្រែភាសា។ល។ កិច្ចការអស់ទាំងនេះ គឺមិនអាចបំពេញបានសមរម្យសម្រាប់ពេលវេលាដែលមាននៅចំពោះ មុនពេលនៅក្នុងអំឡុងពេល និងក្រោយពេលសវនាការនោះទេ ។

ជាទីបញ្ចប់ អង្គជំនុំជម្រះសាលាដំបូង ក៏ធ្វើការកត់សម្គាល់ផងដែរនូវបញ្ហាដែលបានលើកឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងលក្ខខណ្ឌការងារ កង្វះថវិកាឧបត្ថម្ភ និងភាពដែលអាចចូលរួមបានរបស់មេធាវីមួយចំនួន ពីខែសីហា ឆ្នាំ២០០៩ ទៅ ។

[០៩:៣១:៥៤]

តំណាងនៃការិយាល័យរដ្ឋបាលដែលបានចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការ បានធ្វើការកត់សម្គាល់ទៅលើសំណើទាំងពីរខាងលើនេះ ដែលបញ្ហានេះអង្គជំនុំជម្រះយល់ថា មិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលត្រូវដោះស្រាយនោះទេ ។ ទាក់ទងទៅនឹងសំណើទីបី គឺភាពដែលអាចចូលរួមបានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ពីខែសីហា ឆ្នាំ២០០៩ នោះ អង្គជំនុំជម្រះនឹងធ្វើទំនាក់ទំនងជាមួយអង្គភាពជនរងគ្រោះដើម្បីធានាថា អវត្តមានណាមួយរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមិនបង្កឲ្យមានការអាក់ខានដល់ដំណើរការសវនាការនោះឡើយ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមអញ្ជើញលោកមេធាវីក្រុមមួយ ។

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន តើលោកនឹងធ្វើការផ្លាស់ប្តូរនៅពេលនេះ ឬក៏ពេលក្រោយអំពីការចំនួនថ្ងៃដែលត្រូវធ្វើសវនាការនោះ? ថាតើនៅពេលណាទៅទើបយើងអាចដឹងអំពីការផ្លាស់ប្តូរកាលវិភាគសវនាការនេះ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៏៖**

សូមអរគុណលោក អាឡាំង វ៉ែនណឺ ។ អង្គជំនុំជម្រះនៅមានការគិតគូរមួយចំនួនទៀត ហើយវាជាលទ្ធផលអាចនឹងប៉ះពាល់ទៅលើការកំណត់កាលវិភាគសម្រាប់សវនាការ ។ ហើយយើងខ្ញុំនឹងធ្វើការប្រកាសឲ្យបានឆាប់ៗ ប្រហែលជាអាចនឹងធ្វើបាននៅចុងសប្តាហ៍នេះ ។

**សួរដោយប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ យើងចាប់ផ្តើមដំណើរការពិភាក្សាដេញដោលលើអង្គហេតុនៃប្រតិបត្តិការស-២១ ហើយរួមទាំងប្រតិបត្តិការនៅជើងឯកផង ។ ស-២១នេះ គឺយើងសង្កត់ធ្ងន់ទៅលើបច្ចុប្បន្ន ដែលយើងកំណត់ថាដាក់ឈ្មោះថ្មី ហៅថា "គុកទួលស្លែងនោះ" ។ ហើយចំណែកឯ អង្គហេតុផ្សេងទៀតដែលមានការពាក់ព័ន្ធដែរ គឺអង្គហេតុនៃមន្ទីរអប់រំកែប្រែព្រៃសនោះ យើងនឹងធ្វើសវនាការជាបន្តបន្ទាប់ក្រោយទៀត ។

**ស៖** លោក កាំង ហ្គេកអ៊ាវ តើលោកអាចនិយាយរៀបរាប់ប្រាប់ ដល់អង្គសវនាការបានដែរទេ អំពីសមាសភាពមនុស្សដែលបានចាប់ខ្លួនបញ្ជូនមក បញ្ចូលនៅក្នុងមន្ទីរស-២១ ។ តើមនុស្សប្រភេទណា

ខ្លះដែរ?

[០៩:៣៣:៥២]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មនុស្សដែលចូលមកក្នុងមន្ទីរស-២១ នេះ ខ្ញុំគិតថាគប្បីបែងចែកជាពីរដំណាក់កាលធំៗ ។ ដំណាក់ទីមួយ គឺនៅពេលដែលខ្ញុំបាទធ្វើជាអនុប្រធាន ហើយនិងដំណាក់ទីពីរ នៅពេលដែលខ្ញុំបាទធ្វើជាប្រធាន ។ នៅពេលដំណាក់កាលដែលខ្ញុំបាទធ្វើជាអនុប្រធាន មនុស្សដែលចូលមកស-២១ គឺភាគច្រើនជាអ្នករដ្ឋការចាស់ ជាអ្នកបច្ចេកទេសសង្គមចាស់ ដែលធ្វើការនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ នេះតាមបញ្ជីដែលយើងខ្ញុំមើលឃើញនៅសល់ ។ ចាប់តាំងពីខែមីនា ១៩៧៦មក ខ្ញុំឡើងកាន់កាប់ជាប្រធាន រដ្ឋការចាស់យូរៗមកមួយប៉ុន្តែមកពីជនបទឆ្ងាយមកទេ ដែលគេចាប់បាន ។ ដូច្នេះ ស្ទើរតែទាំងស្រុង គឺជាមនុស្សនៅក្នុងជួរបដិវត្តន៍ របស់កម្ពុជាប្រជាធិបតេយ្យហ្នឹង ។ នេះខ្ញុំសូមបែងចែកដោយសង្ខេបប៉ុណ្ណោះ ។ សូមអរគុណ ។

**ស៖** នៅក្នុងចំណោមមនុស្សនោះដែរ តើលោកអាចកត់សម្គាល់បានទេ ថាតើមានដូចជាបុរសស្ត្រី ឬក៏កុមារ ឬក៏កូនក្មេង អីចឹង តើមានការចែងចែកអីចឹងបានទេ លោកគត់សម្គាល់ពីប្រភេទមនុស្សរបៀបវ័យ ក្នុងការបែងចែកជាវ័យដែលត្រូវបញ្ជូនមកដល់មន្ទីរស-២១ ដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មនុស្សដែលចូលមក ដែលត្រូវគេបញ្ជូនមកស-២១ ឲ្យស-២១ ធ្វើទារុណកម្មយកចម្លើយ ហើយកម្ទេចនេះមានច្រើនប្រភេទ មានទាំងកុមារតូច មានទាំងកុមារធំ មានទាំងមនុស្សវ័យជំទង់ មានទាំងស្រី មានទាំងប្រុស មានទាំងមនុស្សចាស់ ។ នេះសូមសង្ខេបដោយអាយុប៉ុណ្ណោះ ។ សូមជម្រាបប្រសាសន៍លោកប្រធាន ។

**ស៖** តាមកត់សម្គាល់ឃើញរបស់លោក តើមនុស្សប្រភេទណាដែលមានចំនួនច្រើនជាងគេដែលត្រូវចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរស-២១ ជាអ្នករដ្ឋការចាស់ ជាកម្មាភិបាលនៃកម្ពុជាប្រជាធិបតេយ្យជាកងទ័ព ឬក៏ជាប្រភេទជនផ្សេងទៀតដែលមានចំនួនច្រើនជាងគេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! សរុបមនុស្សដែលចូលមកស-២១ យើងខ្ញុំអាចឆ្លើយបានថា អ្នកដែលចូលមកមានចំនួនច្រើនជាងគេ គឺយុទ្ធជននិងកម្មាភិបាលនៅក្នុងជួរបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងតែម្តង ។ នេះខ្ញុំសូមឆ្លើយប៉ុណ្ណោះ ។

**ស៖** អរគុណ ។ លោកមានបានកត់សម្គាល់ដែរទេថា នៅក្នុងចំណោមបុគ្គលដែលត្រូវចាប់ខ្លួនបញ្ជូលមកក្នុងមន្ទីរស-២១នោះ មានបុគ្គលិកមន្ទីរស-២១ ឬបុគ្គលិកនៃមន្ទីរអប់រំកែប្រែព្រៃស ដែល

ណាត បានកំណត់ឈ្មោះមួយទៀតថា ស-២៤ នោះដែរឬទេ?

[០០:២៣:០៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! បុគ្គលិកដែលកាន់កាប់កិច្ចការនៅព្រៃស ជាបុគ្គលិករបស់ស-២១ មានឋានៈស្មើគ្នា ខាងសិទ្ធិអំណាចដូចជាបុគ្គលិកនៅភ្នំពេញដែរ ។ នេះមួយផ្នែក ពិតជាមានចំនួនប៉ាន់ប្រមាណលើសពីមួយរយ ។ ឯចំណែក អ្នកដែលត្រូវអប់រំសាថ្មីឡើងវិញ នេះយើងខ្ញុំមិនចាត់ទុកជាបុគ្គលិកពេញលក្ខណៈ ពេញសិទ្ធិរបស់មន្ទីរស-២១ទេ ។ នេះក៏មានយកចូលមកភ្នំពេញដើម្បីធ្វើទារុណកម្មយកចម្លើយ ជួនពេលនាំទៅត្រង់ពីព្រៃសទៅជើងឯក ។ នេះចំនួនខ្ញុំអត់បានដឹងទេ ក៏ប៉ុន្តែពិតជាមាន ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ សូមអរគុណ ។

**ស៖** លោកបានកត់សម្គាល់ទេថា នៅក្នុងចំណោមមនុស្សដែលចាប់បញ្ជូនមកមន្ទីរស-២១ នោះមានជនជាតិភាគតិច ដែលរស់នៅលើទឹកដីកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន! ជាគំនិតខ្ញុំ ខ្ញុំសូមបែងចែកជនជាតិភាគតិចហើយនិងអាណិកជន ។ ពាក្យអាណិកជននេះ ខ្ញុំបាទសូមសំដៅ ចិន ហើយនិងវៀតណាម ឯជនជាតិភាគតិចខ្ញុំសូមសំដៅម៉ូស្លីមកម្ពុជា ហើយជនជាតិផ្សេងទៀតមាន ចារ៉ាយ ភ្នង អី១ហ្នឹង ។ នេះខ្ញុំសូមបែងចែកប៉ុណ្ណឹងសិន ។

ពួកអស់នេះ ខ្ញុំឃើញបញ្ជីនៅសល់មានជនជាតិភាគតិច ជាម៉ូស្លីម នេះបញ្ជីដែលនៅសល់ជំនាន់មុនខ្ញុំឡើងធ្វើជាប្រធាន មានពួកម៉ូស្លីមជា ចាម ជាអារ៉ាប់ ជាប៉ាគីស្ថានខ្លះ នេះមាន ពិតជាមាន ចំនួនប្រហែលជាសែសិបប៉ុណ្ណឹង ។ នេះខ្ញុំចាំស្រពិចស្រពិលណាស់ ចំនួនពិតប្រាកដ សូមពឹងផ្អែកលើបញ្ជីស-២១ ។ ឯចំណែកជនជាតិភាគតិចផ្សេងវិញ ខ្ញុំបានរាយការណ៍ជូនលោកចៅក្រមស៊ើបអង្កេតហើយ គឺពួក *ហ្ចារ៉ៃ* ទាំងអស់មកប្រាំនាក់ ចាប់តាំងពី ប៉ុល ពត គាត់ចាត់ទុកពួកនេះជាមិត្ត យើងខ្ញុំត្រូវតែដោះលែងជាបន្ទាន់បីនាក់ ។ ឯចំណែកក្រៅពីនោះ យើងខ្ញុំភ្លាប់អត់បានទេ ។ ដូចខ្ញុំបានជម្រាបរួចមកហើយកាលនោះ រូបខ្ញុំផ្ទាល់ទុកថា មនុស្សដែលអង្គការគេជឿទុកចិត្តជាងជនជាតិខ្មែរទៅទៀត ។ ឯចំណែកអាណិកជនចិន ឬអាណិកជនវៀតណាម មិនមែនចាប់ព្រោះគេជាអាណិកជនទេ គឺចាប់ព្រោះគេមានទោសជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ។ នេះមានចូល ពិត ។ នេះខ្ញុំសូមអរគុណ ។ សូមជម្រាបប៉ុណ្ណេះ។

**ស៖** លោក តាមការកត់សម្គាល់របស់លោក តើលោកកត់សម្គាល់ឃើញថា ជនក្នុងចំណោម

ជនដែលត្រូវចាប់បញ្ជូនបញ្ចូលមកមន្ទីរស-២១ ដែលយើងកំណត់ថា គុកទួលស្លែងបច្ចុប្បន្នដែលនិយាយភាសាទូទៅ ហៅថា "គុកទួលស្លែង" នោះ ។ តើមានជនជាតិបរទេសដែរឬទេ? ហើយក្នុងចំណោមជនជាតិបរទេសហ្នឹង មានជនជាតិអ្វីខ្លះទៅ ហើយជនជាតិណាដែលមានចំនួនច្រើនជាងគេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មនុស្សដែលបញ្ជូនចូលមក ស-២១ ជនជាតិដែលមានចំនួនច្រើនជាងគេគឺ ជនជាតិវៀតណាម តាមបញ្ជីដែលលោកជំទាវ ខាតរ៉ាយថ៍ ចៅក្រមជំនុំជម្រះលោកឲ្យខ្ញុំឃើញ បើតាមខ្ញុំចាំគឺមានរហូតទៅដល់៣៤៥នាក់ នេះជនជាតិវៀតណាម ។ បន្ទាប់ពីនោះមកជនជាតិតិចតួចណាស់ មានចិន អាណិកជនចិន នៅស្រុកខ្មែរហ្នឹងខ្ញុំមិនរាប់ជាជនជាតិបរទេសទេ ជាអាណិកជននៅស្រុកខ្មែរ ។ ឯចំណែក ជនជាតិបរទេសដែលជាពួកបស្ចិមប្រទេសមានបួននាក់ ខ្ញុំបានឃើញមុខម្នាក់ គឺជនជាតិអង់គ្លេស ក្រៅពីនោះមិនឃើញមុខទេ ប៉ុន្តែពិតជាមានបួននាក់ ។ នេះខ្ញុំសូមសរុបខ្លីប៉ុណ្ណេះ សូមលោកប្រធានជ្រាប ។

**ស៖** អរគុណ ។ ចំនួនសរុបនៃជនរងគ្រោះ តាមដីកាបញ្ជូនរឿងឲ្យមកជំនុំជម្រះ បានកំណត់ថាមានយ៉ាងតិច ១២.៣៨០នាក់ ដែលបានចាប់ខ្លួន នាំមកឃុំឃាំងនៅមន្ទីរស-២១ ចាប់តាំងពីពេលកកើតឡើងនូវមន្ទីរសន្តិបាលនោះ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។ នេះជាការដែលយើងឃើញនូវសំណោជាឯកសារផ្សេងៗ ដែលនៅក្នុងសំណុំរឿង ។ តើលោកទទួលស្គាល់ទេ ទទួលស្គាល់ទេថាចំនួនជនរងគ្រោះ ដែលបានមកដល់ទីនេះតិចបំផុត គឺមានចំនួនប៉ុន្មានហ្នឹង?

**ឆ៖** អរគុណលោកប្រធាន ។ តាំងពីឃើញបញ្ជីនេះមក ខ្ញុំអត់ដែលបានកែប្រែពាក្យទេ ខ្ញុំទទួលស្គាល់ចំនួននេះ ខ្ញុំទទួលស្គាល់ឈ្មោះទាំងអស់ក្នុងបញ្ជីនេះ អត់កែប្រែទេ ។ បញ្ហាដែលខ្ញុំចង់លើកឡើងសុំជូនយោបល់លោកប្រធាន គឺមានបញ្ជីប្រាំមួយទៀត ថ្មីៗនេះដែលទើបនឹងធ្លាក់មកដល់ដៃខ្ញុំ ដែលយើងហៅថា បញ្ជីដោះលែង ។ តែតាមពិត គឺជាបញ្ជីកម្ទេចទៅវិញទេ ។ ដូច្នេះ សូមលោកប្រធានពិចារណា តើឲ្យខ្ញុំរាយការណ៍ជូនអង្គជំនុំជម្រះនៅពេលនេះ ឬក៏នៅណាអំពីបញ្ជីប្រាំមួយនេះ ដែលមានរូបរាង ដែលយើងចូលយល់ច្រឡំថាជា បញ្ជីដោះលែង ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** អរគុណ ។ ឥឡូវនេះគឺអង្គជំនុំជម្រះចង់ដឹងអំពីព័ត៌មាន ដែលទាក់ទិនជាមួយបញ្ជីប្រាំមួយដែលថ្មីនេះ ថាតើមានលក្ខណៈយ៉ាងម៉េចទៅ ពាក់ព័ន្ធជាមួយនឹងចំនួនមនុស្សដែលត្រូវចាប់ខ្លួន បញ្ជូនមកមន្ទីរស-២១ ហើយត្រូវកម្ទេចនេះ អាចមានការភាន់ច្រឡំ ដើម្បីចង់ច្បាស់ថា តើបញ្ជីហ្នឹងវាជាការដោះលែង ឬក៏បញ្ជីកម្ទេច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បញ្ជីទាំងប្រាំមួយនេះសុទ្ធតែជាបញ្ជីកម្ទេច ។ បូកសរុបចំនួនមនុស្សនៅក្នុងបញ្ជីទាំងប្រាំមួយនេះ ខ្ញុំបានបូករួចហើយមាន១៦១នាក់។ បញ្ជីទីមួយ គឺបញ្ជី D159/4.10 បញ្ជីនេះផ្ញើយកមកឆ្លងខ្ញុំនៅថ្ងៃទី២៦ វិច្ឆិកា ១៩៧៧ នៅពេលដែលឃើញបញ្ជីនេះភ្លាមខ្ញុំបាទជាប្រធានដែលទទួលបញ្ជាពីលើមកច្បាស់លាស់ ទាញដក់មួយមកចារក្រហមនៅខាងចុងបញ្ជីនេះ ខាងស្តាំ ថាសម្រាប់ដក ពាក្យ "ដក" នេះជាពាក្យដែលខ្ញុំបាទប្រើ ស្មើនឹងពាក្យកម្ទេច ហើយក៏ស្មើនឹងពាក្យវាយចោលដែរ ។ ដូច្នេះ បានន័យថា "កម្ទេច" ។

ភស្តុតាងមួយទៀត នៅក្នុងបញ្ជីដដែលនេះ គឺនៅខាងចុងបញ្ជីនេះ មិត្តហ៊ី បានសរសេរថា "បានដកឈ្មោះដោះលែងនៅក្នុងបញ្ជីនេះអស់ហើយ" រួចគាត់ចុះថ្ងៃខែទៅ ថ្ងៃទី២ ខែធ្នូ ១៩៧៧ ។ សរុបមកពួកមិត្តអស់នេះ ជាយុទ្ធជន និងកម្មាភិបាលអនុសេនាធំនៃកងពល៩២០ គេបញ្ជូនមកដល់ស-២១ នៅថ្ងៃ២៣ ខែ១១ ១៩៧៧ ។ ដូច្នេះ មួយរយនាក់នេះ គឺពិតជាកម្ទេចតាមបញ្ជាពីខាងលើមកពិតប្រាកដ ។ ដូច្នេះ សូមលោកប្រធានមេត្តាឲ្យគេពិចារណាបញ្ជីនេះ ដើម្បីដាក់បញ្ចូលទៅក្នុងបញ្ជីគោលរបស់មន្ទីរស-២១ ។ នេះបញ្ហាបញ្ជីទីមួយ ។

បញ្ជីទីពីរ គឺបញ្ជីលេខ D57 បញ្ជីនេះ បើយើងមើលរូបភាពខាងក្រៅ វាជាបញ្ជីរបស់កងពល៧០៣ ដែលអនុសេនាធំ៤៤ គេធ្វើឡើងតាមពាក្យស្មោកភូតភរដែល ណាត បង្គាប់ថា ដោះលែងមានយុទ្ធជន និងកម្មាភិបាលទាំងអស់៤៩នាក់ និងប្រជាជនផង៤៩នាក់ ។ បញ្ជីនេះ ចុះហត្ថលេខាដោយមិត្តហិន លេខាវរសេនាតូច៩៩នៃកងពល៧០៣ ចុះហត្ថលេខានៅថ្ងៃទី២០ ខែធ្នូ ១៩៧៥ ។ បានជាខ្ញុំប៉ានអះអាងថា បញ្ជីនេះ ជាបញ្ជីកម្ទេច ព្រោះមានហេតុផលដូចតទៅ បញ្ជីនេះវាអត់នៅ៧០៣ទេ គណកម្មាធិការស្រាវជ្រាវ មើល៍! មិនដឹងគេហៅស្អីទេ គណកម្មាធិការសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ គេឃើញបញ្ជីនេះនៅស-២១ គេសរសេរ TSL នៅចុងទំព័រជាចំណាំស្រាប់ ដូច្នេះការដែលបញ្ជីនេះ ទោះបីជាវាមានផ្លាកថា ៧០៣ ក៏ដោយ តែវាមកនៅទួលស្លែងវាជាភស្តុតាងមួយហើយ ដើម្បីយើងយល់បញ្ហា ។

ទីពីរ ការដែលចុះហត្ថលេខានៅថ្ងៃ២០ ធ្នូ ១៩៧៥ និយាយពីរឿងដោះលែង គ្មាននរណាប៉ានដោះលែងទេ បែកការណ៍ៗ ព្រោះទូទាំងប្រទេសទាំងកម្មករ សហជីព គេមានចាត់តាំងជាពួកជាក្រុម ។ កសិករ សហករណ៍ គេមានចាត់តាំងជាពួក ជាក្រុម ។ កងទ័ពមានចាត់តាំងជាពួក ជាក្រុម ជាអង្គភាព។ មន្ទីរក៏មានចាត់តាំងជាពួកជាក្រុម ជាអង្គភាព តើយើងយកមនុស្ស៤៩នាក់ យកទៅឲ្យអ្នកណា?បើមិន

បែកការណ៍ដល់ខាងលើ ហើយមាគ៌ារបស់ខាងលើ គោលនយោបាយរបស់ខាងលើចំពោះខ្មាំងត្រូវតែកម្ទេច នេះហេតុផលទីពីរ ។ រហូតដល់ថ្ងៃ២០ ធ្នូ ១៩៧៥ ហើយគ្មានអ្នកណាប៊ានដោះលែងទេ បែកការណ៍កំបុតកខ្លួនឯង ។

ហេតុផលទីបី ជនរងគ្រោះនៅក្នុងលេខរៀងទី១៨ និងនៅក្នុងលេខរៀងទី៣៦ ជាជនរងគ្រោះដែលពាក់ព័ន្ធនឹងរឿងដែលខ្ញុំបានដឹង ហើយដែល ណាត ត្រូវមាត់មេរបស់យើងខ្ញុំ គឺលោកគ្រូ សុន សេន នៅនឹងមុខខ្ញុំ យ៉ាងធ្ងន់ចិត្ត ។ ឃើញបញ្ហានេះ ខ្ញុំនឹកដល់រឿងពីរពីមុនមក តាមដែរ យូ ប៉េងគ្រី ហៅ ម៉ុន ប្រាប់ខ្ញុំផង ហើយតាមដែល ណាត វាយការណ៍ជូនមេកែលម្អពីការដែលគាត់ចាប់ចងដោយមិនសុំយោបល់មេផង ធ្វើឲ្យខ្ញុំសន្និដ្ឋានបានថា បញ្ជីនេះ គឺជាបញ្ជីដោះលែងក្លែងក្លាយ ដែល ណាត សម្រេចអត្តនោម័តិ ។ បានន័យថា សម្រេចដោយខ្លួនគាត់តែម្នាក់ឯងដោយខ្លួនគាត់តែម្នាក់ឯង មិនសុំយោបល់មេ ចាប់មនុស្សទាំង៤៩នាក់នេះ ។ ហើយដល់ភ័យខ្លួនតាំងបង្កើតរឿងដោះលែងក្លែងក្លាយអ៊ីចឹង ។

ដូច្នេះ ខ្ញុំនៅតែជឿថា មនុស្សទាំង៤៩នាក់នេះ ជាមនុស្សដែល ណាត ដោះលែងក្លែងក្លាយ ។ រហូតមកដល់ពេលនេះ ខ្ញុំសូមជម្រាបលោកប្រធាន ដោយស្មោះត្រង់ថា មិនទាន់ឃើញដើមបណ្តឹងរដ្ឋប្បវេណីណា ដែលគេមកប្តឹងតវ៉ា ជំពាក់ជំពិនដល់ឈ្មោះទាំង៤៩នាក់នេះទេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណឹង ។ មិនទាន់មានសាក្សីអីបញ្ជាក់ថា មនុស្សអស់នេះស្លាប់ផុតអស់ទៅហើយ អត់មានដោះលែងអត់មានទេ ។ នេះបញ្ជីទីពីរ គឺបញ្ជីលេខ៥៧ ។

សូមនិយាយបញ្ជីផ្សេងទៀត ប្អូនរួមគ្នា ។ បញ្ជីទីមួយ គឺបញ្ជីលេខ E5/2.8 បញ្ជីនេះ ជាកំណត់ហេតុសួរចម្លើយ ដែលបង ម៉ម ណៃ តាមបញ្ជា ណាត សរសេរស្នើសុំអង្គការដោះលែង អត់មានចុះថ្ងៃខែទេ ហើយមិត្តហ៊ី បានសរសេរអក្សរថា ដោះលែងនៅថ្ងៃទី០៨ ខែមីនា ១៩៧៦ នេះក៏ជាការដោះលែងក្លែងក្លាយដែរ ជាឧបកិច្ចដែល ណាត ធ្វើ នេះបញ្ជីមួយ ។ បញ្ជីមួយទៀត វាបញ្ជីបី គឺឋិតនៅក្នុងសៀវភៅរបស់បង ម៉ង ណៃ កំណត់ដែររបស់បង ម៉ម ណៃ ដែល ណាត ណែនាំឲ្យសរសេរ ។ សៀវភៅរបស់បង ម៉ម ណៃ សូមបញ្ជាក់ជូនថាវាមានលេខរៀងពី ERN00077761 រហូតទៅដល់ 00078056 ក្នុងនេះទំព័រ ERN00077976 មានម្នាក់ដែល ណាត ឲ្យបង ម៉ម ណៃ សរសេរថា ស្នើសុំដោះលែង ។ ឯចំណែក នៅទំព័រ ERN00077978 មានប្អូននាក់ ដែលណាត ឲ្យបង ម៉ម ណៃ សរសេរថា ស្នើសុំដោះលែង ។ ហើយ ណាត ពីថ្ងៃ២៤ ខែធ្នូ និយាយច្របូកច្របល់ណាស់ ដល់ថ្ងៃ២៥ ខែធ្នូ សរសេរថា “ដោះលែង” ។ ឯចំណែកទំព័រ ERN00077979 មានប្អូននាក់ទៀត ដែលបង ម៉ម ណៃ តាមបញ្ជា

ណាត សរសេរ "ស្នើសុំដោះលែង នៅថ្ងៃ២៥ ខែធ្នូ ១៩៧៥" ។ ដូច្នេះ ឈ្មោះដោះលែង ទាំងដប់មួយនាក់នៅក្នុងបញ្ជី ដែលមាននៅក្នុងកំណត់ដៃរបស់បង ម៉ម ណៃ នេះមិនមែនជាដោះលែងពិតប្រាកដទេ គឺដោះលែងក្លែងក្លាយ ភស្តុតាងជាក់ស្តែង ។ ខ្ញុំសូមលើកបញ្ជាក់ជូនដូចតទៅ នៅក្នុងបណ្តឹងរដ្ឋប្បវេណីរបស់ E2/56 មានបណ្តឹងរបស់ E2/56 នៅត្រង់ចំណុច E2/51.1 ដើមបណ្តឹងរបស់គាត់ច្បាស់ហើយពាក្យបណ្តឹងរបស់គាត់ ។ ដល់ E2/56.2 គឺជាកំណត់សួរចម្លើយរបស់បង ម៉ម ណៃ ដែលបង ម៉ម ណៃ សរសេរនៅខាងចុងថា "ស្នើសុំអង្គការអនុគ្រោះដោះលែងឈ្មោះនេះ" ។ ស៊ីញ៉េគាត់អត់ស៊ីញ៉េគាត់ទេ គាត់ស៊ីញ៉េម-២១ៗ ហ្នឹង បានន័យថា មន្ទីររដ្ឋបាល គឺការិយាល័យរបស់លេខាធិការដ្ឋានរបស់ណាត ហើយដល់ទៅ ណាត ខ្លួនឯងស៊ីញ៉េតាងនាមក្នុងអង្គការ "យល់ព្រមដោះលែង" ។

ដូច្នេះ សរុបទាំងអស់មក បូករួមទាំងបណ្តឹងរដ្ឋប្បវេណីរបស់ E2/47 និង E2/55 ផង បញ្ជីទាំងបួននេះ វាបង្ហាញឲ្យឃើញថាបញ្ជីទាំងបួននេះ គឺជាការដោះលែងក្លែងក្លាយ រួមទាំងបញ្ជីមួយទៀតគឺបញ្ជី D57 នេះគឺជាការដោះលែងក្លែងក្លាយ ។ ហើយអារម្មណ៍នេះ វានៅជាប់ក្នុងគំនិតមិត្តហ៊ៃ បានជាមិត្តហ៊ៃ សរសេរនៅក្នុងបញ្ជី D159/4.10 នេះថាឈ្មោះដោះលែង ។ ដូច្នេះ ពាក្យដោះលែងនេះ នៅស-២១ ខ្ញុំសូមបញ្ជាក់ជូនតុលាការថា គ្មានទេ គឺជាការក្លែងក្លាយ។ នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណឹង ។ ដូច្នេះបូកសរុមក១៦១នាក់នេះ សូមលោកប្រធានមេត្តាពិចារណា ឲ្យគេពិចារណា តើដាក់បញ្ចូលទៅនឹងបញ្ជីមេរបស់ស-២១ ឬយ៉ាងម៉េច? សូមលោកប្រធានមេត្តាពិចារណា ដោយអនុគ្រោះ ។ សូមចប់ ។

**ស៖** អរគុណ ។ ក្នុងប្រតិបត្តិការចាប់មនុស្ស ដើម្បីនាំខ្លួនយកមកឃុំឃាំងនៅមន្ទីរស-២១ ជាទូទៅ តើមានការអនុវត្តយ៉ាងដូចម្តេចដែរ?

[០៩:៥៨:00]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! និយាយអំពីការចាប់ សិទ្ធិសម្រេចឲ្យចាប់ទាល់តែមនុស្សដែលមានសិទ្ធិសម្រេចឲ្យកម្ទេច ។ បើកាលណាពួកនេះវាសម្រេចហើយ ខាងក្រោមត្រូវតែចាប់ ទីមួយត្រូវតែចាប់ ។ ទីពីរ ចាប់ឲ្យបានកុំឲ្យតដៃកើត ។ ទីបី ចាប់ឲ្យស្ងាត់កុំឲ្យបែកការណ៍ ហើយនាំមកឲ្យដល់ស-២១ ។ ដូច្នេះ នេះជាគោលការណ៍ក្នុងអនុវត្ត ភាគច្រើនគឺគេចាប់បញ្ជូនមកស-២១ ហើយស-២១ ចាំទទួល ។ នេះជាសកម្មភាពអនុវត្តមួយបែបហើយមានលក្ខណៈទូទៅ ។ សកម្មភាពអនុវត្តមួយបែបទៀត មាន ក៏ប៉ុន្តែតិចតួច ។ ឧទាហរណ៍ ដូចចាប់ កុយ ធួន ។ ចាប់ កុយ ធួន គឺមិត្តប៉ង់, ឈឹម សំអោក ឈ្មោះដើម នាំមកឲ្យស-២១ ចាប់ នេះជាសកម្មភាពចាប់ កុំឲ្យបែក កុំឲ្យរត់រួច កុំឲ្យមនុស្ស

ដឹងខ្លួនមុន ។ យកមកដល់ស-២១ គេចាប់ ហើយបានគេចាប់បានហើយ ដាក់ខ្នោះហើយ ខ្ញុំចេញពីរាំងនន មកឆ្លងឆ្លើយជាមួយនឹង កុយ ធួន មួយម៉ាតពីរ ដូចបានជម្រាបហួរហែមកហើយ នេះមួយបែប ។ មួយបែបទៀត អចិន្ត្រៃយ៍សម្រេចចាប់ ប៉ង់ ខ្លួនឯងឲ្យ វ៉ន វេត មកប្រាប់ដំណឹងដល់ខ្ញុំ ខ្ញុំអ្នកទទួលភារកិច្ចអនុវត្ត ។ ហើយក្នុងការចាប់ ប៉ង់ តែលើសពីមនុស្សបីនាក់នេះ មនុស្សពីរនាក់របស់ស-២១នេះអត់បានទេ បែក ។ មនុស្សដឹងខ្លួន ព្រោះប៉ង់ ធ្លាប់ចូលមកស-២១ ឃើញទាំងខ្ញុំ ឃើញទាំងមិត្តហ៊ី ភាគច្រើនឃើញទាំងខ្ញុំ ឃើញទាំងមិត្តហ៊ី ប៉ុន្តែជាទូទៅ ឃើញខ្ញុំនៅហ្នឹងការិយាល័យហ្នឹង ។ ហើយដល់គាត់ចូលមកលើកនេះ គាត់ឃើញខ្ញុំ ហើយនិងមិត្តហ៊ី គាត់មិនភ្ញាក់ផ្អើរទេ ។ ដល់ចូលមកដល់អង្គុយស្រួលបួល ខ្ញុំលើកដៃចង្អុល លើកដៃអី? ប៉ង់ ស្រែកជេកចាច មិត្តហ៊ី ដាក់ខ្នោះបណ្តោយ ចប់ ។ ដូច្នេះ ក្នុងការអនុវត្តចាប់ចង មនុស្សសំខាន់ៗដែលអចិន្ត្រៃយ៍គេសម្រេចហើយ គេណែនាំពីយុទ្ធវិធីហើយ ពិតជាយកមកឲ្យស-២១ ចាប់ ។ ក៏ប៉ុន្តែពេលខ្លះ ដូចជាមាននៅក្នុងឯកសារចរចាគ្នាថ្ងៃ១៦កញ្ញា (សូមទោស) ខ្ញុំមិនចាំខែទេ ។ ដូចជាការចរចាគ្នារវាងមិត្តសុខ ខ្ញុំហើយនិងមិត្តតាត អំពីគេចាប់យកមនុស្សសែសិបនាក់ពីកងពល១៧០ និង ២៩០ ។ ដូច្នេះ វាមានការទៅពិគ្រោះគ្នា អំពីយុទ្ធវិធីចាប់ ។ អាហ្នឹងមានពួកស-២១ ចេញមែន ពិគ្រោះគ្នាហើយសហការគ្នា ហើយទៅចាប់នេះ ។ នេះជាកិច្ចដំណើរការហូរហែ ។ សរុបមកវិញ គ្រប់ការចាប់ចងសុទ្ធតែអចិន្ត្រៃយ៍សម្រេច ។

ទីពីរ បើកាលណាអចិន្ត្រៃយ៍សម្រេចហើយអ្នកណាមិនធ្វើមិនបាន ។ ស-២១ ក្តីអង្គភាពដើមក្តីត្រូវតែចាប់ឲ្យស្វាត់ កុំឲ្យគេរើរួចខ្លួន បើកាលណាអ្នកឯងធ្វើឲ្យមនុស្សរត់នៅកន្លែងណា អ្នកដែលនាំនោះទទួលខុសត្រូវដោយផ្ទាល់ខ្លួន ។ សូមចប់ប៉ុណ្ណេះ ។

**សះ** អរគុណ ។ និយាយអំពីកម្មាភិបាលបុគ្គលិកនៃមន្ទីរស-២១ មានដែលអនុវត្តន៍ចេញទៅចាប់ខ្លួនមនុស្សដែរឬទេ? ក្រៅពីករណីដែលលោកបាននិយាយមិញក្នុងករណីដែលពាក់ព័ន្ធនឹងកងពល ១៧០ និង២៩០ មានការពិភាក្សា អាហ្នឹងនោះជាសំណួរដោយឡែកមួយទៀត ប៉ុន្តែលោកបានឆ្លើយហើយចាំយើងពិនិត្យមើលថា តើយើងត្រូវសួរទៀត ឬក៏មិនចាំបាច់សួរទេ ។ សំណួរថា តើក្រៅពីករណីនៃកងពលទាំងពីរដែលមានការប្រជុំគ្នារវាងថ្ងៃទី១៦ហ្នឹង នៅក្នុងឆ្នាំ១៩៧៦ ដែលលោកបានលើកឡើងអម្បាញ់មិញនេះ ។ តើកម្មាភិបាលបុគ្គលិក ឬក៏កម្លាំងនៃមន្ទីរស-២១ មានចុះប្រតិបត្តិការក្នុងការចាប់ខ្លួនមនុស្សផ្សេងទៀតដែរឬទេ? ហើយបើចុះទៅចាប់ តើក្នុងករណីណាខ្លះ? ហើយការអនុវត្តប្រព្រឹត្តទៅដូចម្តេច?

**ឌ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមនិយាយពីត្រឹមតែថ្ងៃ ពីត្រឹមខែមីនា ឆ្នាំ១៩៧៦ ដែលខ្ញុំកាន់កិច្ចការជាប្រធាន ។ ការបញ្ជូនមនុស្សចេញទៅក្រៅមានពីរផ្លូវ ។ ផ្លូវលេខប្រាំទៅខាងពោធិ៍សាត់ បាត់ដំបង ហើយនិងផ្លូវលេខមួយសំដៅទៅខាង ព្រៃវែង និងស្វាយរៀង ហើយយ៉ាងតិចណាស់ក៏ត្រឹម អ្នកលឿងដែរ ។ ការបញ្ជូនកម្មាភិបាលកងពិសេសរបស់យើងខ្ញុំ របស់មន្ទីរស-២១ ទៅក្រៅនេះ ទៅ ខាងណាប៉ុន្មានៗ ខ្ញុំភ្លេចអស់ហើយ ព្រោះជាបញ្ហាដែលយើងខ្ញុំមិនយកចិត្តទុកដាក់ខ្លាំងពេក ។

**ស៖** សូមស្តាប់សំណួរឲ្យបាន ។ សំណួរខ្ញុំ ខ្ញុំសួរលោកថា តើមានករណីណាខ្លះផ្សេងទៀតទេ ក្រៅពីការពិភាក្សាលោកចូលរួមជាមួយនឹងកងពល១៧០ កងពល២៩០ ដែលមានការចូលរួមពីថ្នាក់ដឹក នាំមាន សុន សេន មានបង៨១ ដែលបានចូលរួមនោះ ហើយពិភាក្សាដោយសារមូលហេតុនៃការចាប់ ខ្លួនមនុស្សច្រើននាក់រហូតដល់ទៅសែសិបនាក់ឯណោះ ។ នោះគឺជាករណីមួយដោយឡែក ។ ប៉ុន្តែយើង សួរថា តើមានករណីណាផ្សេងទៀតទេ ដែលស-២១ កម្លាំងស-២១ បានចេញប្រតិបត្តិការដើម្បីអនុវត្ត ការចាប់ខ្លួនមនុស្សដូចជាតាមបណ្តាល ក្រសួង មន្ទីរ នានា នៅក្នុងក្រុងភ្នំពេញជាដើម ។ ខុសគ្នារវាង ការដែលចាប់ខ្លួន ហើយនិងប្រតិបត្តិការ និងការដឹកជញ្ជូន ។ ដឹកជញ្ជូនពីទីកន្លែងដែលគេចាប់រួចមក ទីក្រុងភ្នំពេញ ។ បញ្ហាសំណួរនេះ យើងនឹងរក្សាក្នុងការស្ពានភាព សួរដោយឡែកដើម្បីកុំឲ្យមានការ ច្របូកច្របល់គ្នា ។

**ឌ៖** អរគុណលោកប្រធាន ។ នៅក្រុងភ្នំពេញ បើតាមខ្ញុំចាំ ខ្ញុំមិនប៉ានតតាំងនឹងឯកសារទេ បើ មានឯកសារច្បាស់លាស់ អាហ្នឹងខ្ញុំអត់ប៉ានតតាំងទេ ទទួល ។ ក៏ប៉ុន្តែ បើតាមខ្ញុំចាំ ខ្ញុំមិនដែលបាន បញ្ចេញយុទ្ធជន ឬកម្មាភិបាលកងពិសេសទៅចាប់ពីអង្គភាពផ្សេងទេ ព្រោះតែចេញទៅមនុស្សប្លែក វា បែក ដូច្នេះសូមសង្ខេបខ្លីប៉ុណ្ណេះ ។ ឯចំណែកចេញទៅក្រៅ អាហ្នឹងផ្សេងចាំខ្ញុំរាយការណ៍ជូនលោក ប្រធាន ។

[១០:០៥:២៩]

**ស៖** អម្បាញ់មិញលោកបានលើកឡើងហើយអំពីការចាប់ខ្លួនករណីមនុស្សពីរនាក់គឺ កុយ ធួន ហើយនិង ឈឹម សំអោក ហៅ ប៉ង់ ដែលលោកបានលើកឡើងរួចហើយ ។ ប៉ុន្តែ សំណួរយើងសួរថា ក្នុងការចាប់ខ្លួនបុគ្គលដែលមានឋានៈតួនាទីសំខាន់ៗក្នុងជួរបក្សនិងរដ្ឋាភិបាលតាមបណ្តាក្រសួង ភូមិភាគ នានាទូទាំងប្រទេស តើគេប្រព្រឹត្តទៅយ៉ាងដូចម្តេចក្រៅពីមនុស្សពីរនាក់នេះ? ក្រៅពី ប៉ង់ ហើយនិង កុយធួន ដែលថ្នាក់លើសម្រេចបញ្ជូនខ្លួនមនុស្សហ្នឹងមកឲ្យជួបលោកនៅឯការិយាល័យរបស់លោក ហើយ

លោកប្រតិបត្តិការជាមួយនឹង ហ៊ី ក្នុងការចាប់ខ្លួនដែលលោកបានលើកឡើងរួចហើយ ។ ប៉ុន្តែ ដូចអ្នកផ្សេងទៀតដូចជា កង ចាប ដូចជា វ៉ន វេត ជាដើម ។ តើប្រតិបត្តិការចាប់ខ្លួនហ្នឹងប្រព្រឹត្តទៅដូចម្តេច?

**ឆ៖** អរគុណលោកប្រធាន ។ ការចាប់ខ្លួន កុយ ធួន ច្រើនគ្នា ឯចំណែកការចាប់ខ្លួន ប៉ង់ តែបីនាក់មែន តែពីរនាក់ខ្ញុំហើយនិងហ៊ី មែន ។ ឯចំណែក កង ចាប មិនដឹងជាគេចាប់ពីណាទេ គេបញ្ជូនមក ។ ឯចំណែក វ៉ន វេត ហើយនិង ចេង អន ចាប់នៅក្នុងមន្ទីរមជ្ឈិមវេលាល្ងាចបញ្ជូនទៅដល់ខ្ញុំព្រលប់ៗ ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** អ៊ីចឹង និយាយទូទៅទម្រង់ការនៃការចាប់ខ្លួនក្នុងការចាប់ខ្លួនបញ្ជូនមកស-២១ គឺអង្គភាពដើមរបស់គេទេ ដែលគេចាប់ខ្លួនបញ្ជូនមកនោះ ហើយស-២១ រង់ចាំតែទទួលទេ ។ លើកលែងតែករណីមួយចំនួនដែលលោកបានឆ្លើយរួចហើយអម្បាញ់មិញនេះមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន តាមការចងចាំរបស់ខ្ញុំគឺពិតជាអ៊ីចឹងមែន ។

**ស៖** ចុះការចាប់ខ្លួនបុគ្គលិកនៃមន្ទីរស-២១ និងមន្ទីរអប់រំកែប្រែព្រៃស ។ តើបុគ្គលណាជាអ្នកសម្រេច? ចាប់ខ្លួននេះ គឺចង់និយាយថា ការចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ដើម្បីគោលបំណងនៃការទារុណកម្ម សួរចម្លើយ ទារុណកម្ម និងកម្ទេច ។

**ឆ៖** ទីមួយខ្ញុំសូមជម្រាបលោកប្រធានអំពីសម្រេច ។ អ្នកដែលសម្រេច គឺអចិន្ត្រៃយ៍មជ្ឈិមមុនថ្ងៃ១៥ សីហា ឆ្នាំ១៩៧៧ លោកគ្រូ សុន សេន ជាអ្នកសម្រេច ក្រោយមក ពូនួន គាត់ជាអ្នកសម្រេច ។ អត់មានអ្នកណាហ៊ានសម្រេចដោយគ្មានការយល់ស្របទេ ។ សូមរាយការណ៍ជូនអំពីមូលហេតុដែលឈានទៅដល់សេចក្តីសម្រេច គឺបាតុភាពវាមានជាហូរហែ មិត្តហ៊ី រាយការណ៍ឲ្យខ្ញុំហូរហែនៅក្នុងពេលមួយជាកំណត់ដែល មិត្តហ៊ី យល់ថាយើងគួរតែរាយការណ៍ជូនទៅខាងលើហើយបង នៅពេលដែលនៅក្នុងករណីដែលខ្ញុំយល់ស្របបញ្ហានេះ ខ្ញុំរាយការណ៍ជូនខាងលើ សូមសេចក្តីសម្រេចពីខាងលើ ដល់កាលណាខាងលើមានសេចក្តីសម្រេចហើយ ខ្ញុំប្រាប់ថាខាងលើសម្រេចហើយមិត្តចាត់ចែងទៅ ។ ដូច្នេះខាងបច្ចេកទេសចាប់ចង គឺមិត្តហ៊ីទេ ជាអ្នកចាត់ចែងជាមួយនឹងកងពិសេសរបស់គេ។ ឯចំណែកខ្ញុំទទួលខុសត្រូវត្រឹមតែថា កុំឲ្យរត់រួច កុំឲ្យតដៃបាន ។ បើតដៃបានត្រូវរាយការណ៍ប្រាប់ខ្ញុំ នេះជារឿងពិត ។ សូមរាយការណ៍ជូនលោកប្រធានប៉ុណ្ណេះ ។

**ស៖** លោកមានបានគិតថា ការកត់សម្គាល់នៅចងចាំទេ ការកត់សម្គាល់អំពីកម្រិតនៃបាតុភាពឬក៏កំហុសរបស់គេដែលឈានឲ្យដល់ រហូតដល់ធ្វើការកត់សម្គាល់ ធ្វើសេចក្តីសន្និដ្ឋាន ឬក៏របាយ-

ការណ៍ជូនទៅថ្នាក់លើដើម្បីសម្រេចនោះ ។ តើកម្រិតនៃកំហុសដែលៗរហូតដល់ការចាប់ខ្លួន ឃុំឃាំង ស្សួរចម្លើយ ទារុណកម្ម និងកម្ទេច ដូចមនុស្សផ្សេងទៀតដែលមកពីខាងក្រៅដែលនោះ ចំពោះបុគ្គលិកមន្ទីរស-២១ និងព្រៃសនេះ ។ តើវាមានលក្ខណៈធ្ងន់ធ្ងរកម្រិតណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន រឿងដែលខ្ញុំអាចនឹកឃើញបានខ្លះ គឺរឿង នុន ហ៊ុយ មិត្តហ៊ុយ ជាសមាជិកគណៈកម្មាធិការមន្ទីរស-២១ របស់ខ្ញុំនេះ បាតុភាពមានជាហូរហែមកហើយ ខ្ញុំបានរាយការណ៍ជូនមេជាបណ្តើរៗដែរ តាមការឯកភាពរវាងខ្ញុំនិងមិត្តហ៊ី ។ ដល់ចុងបញ្ចប់ វាមានបាតុភាពមួយគឺរឿងគាត់បណ្តោយឲ្យកាន់តេអូរបស់គាត់រត់ ។ ធម្មតាកម្មាភិបាលទទួលខុសត្រូវលើមិត្តណាម្នាក់ កាលណាមិត្តនោះមានបាតុភាពដល់ថ្នាក់រត់ត្រូវតែមានទោសហើយ ដូច្នេះខ្ញុំរាយការណ៍ទៅខាងលើសូមយោបល់ពូនួន ។ ពូនួន សម្រេចឲ្យចាប់ ដូច្នេះ ខ្ញុំក៏បញ្ជាឲ្យមិត្តហ៊ី ចាប់ ។ សូមទោសនាពេលនោះ ខ្ញុំក៏ទៅដែរ ព្រោះបើកាលណាគ្មានខ្ញុំ មិត្តហ៊ុយ គាត់ពិតជាសង្ស័យ ដូច្នេះ ខ្ញុំទៅដែរ ។ នេះបាតុភាពមួយទៀតដែលខ្ញុំទើបតែនឹកឃើញ សូមទោស ។ ឥឡូវ ងាកទៅរកមូលហេតុវិញ ខ្ញុំស្រពេចស្រពិលហើយក៏ប៉ុន្តែមូលហេតុដែលធំមែនទែនរបស់ មិត្តហ៊ុយ គឺបណ្តោយឲ្យអ្នកកាន់តេអូរបស់គាត់រត់រួច ។ នេះសូមអរគុណ សូមរាយការណ៍ជូនប៉ុណ្ណេះ ។

**ស៖** សំណួរស្សួរថា បុគ្គលិកនៃមន្ទីរស-២១ ដែលយើងហៅថា គុកទួលស្លែងបច្ចុប្បន្នហើយនិងសាខាមួយទៀត គឺមន្ទីរអប់រំកែប្រែព្រៃសដែលត្រូវចាប់បញ្ជូនៗទៅស-២១ ដើម្បីកម្ទេច ។ ហើយលោកជាអ្នកធ្វើរបាយការណ៍អំពីសកម្មភាពបាតុភាពផ្សេងៗនៃបុគ្គលិកទាំងនោះ ដែលនៅក្នុងអង្គភាពរបស់លោក អ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺពិតជាខ្ញុំរាយការណ៍ទៅលើ ក៏ប៉ុន្តែអត់បានជាលាយលក្ខណ៍អក្សរទេ ។ គ្មានឯកសារនៅសល់ពីរឿងលាយលក្ខណ៍អក្សរទេ គឺរាយការណ៍ជាមាត់ទទេ ។

**ស៖** សំណួរស្សួរថា គ្រប់បុគ្គលដែលលោកបានធ្វើសេចក្តីរាយការណ៍ទៅលើអំពីបាតុភាពផ្សេងៗនៃបុគ្គលទាំងឡាយនៅក្នុងអង្គភាពរបស់លោកទាំងពីរអង្គភាព ដែលខ្ញុំបានលើកឡើងអម្បាញ់មិញ គឺនៅស-២១ បច្ចុប្បន្នគេហៅថា ជាទូទៅ ស្គាល់ទូទៅថា គុកទួលស្លែង ហើយនិងមន្ទីរអប់រំកែប្រែ ព្រៃសនោះ ។ ស្សួរថាតើមានអ្នកណាបានរួចខ្លួនមិនត្រូវបានថ្នាក់លើសម្រេចឲ្យចាប់ខ្លួនដែរឬទេ? ឬក៏គ្រប់បុគ្គលដែលលោកធ្វើរបាយការណ៍ទៅថ្នាក់លើនោះត្រូវបានទទួលដោយថ្នាក់លើសម្រេចឲ្យកម្ទេចទាំងអស់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មនុស្សដែលខ្ញុំនិងមិត្តហ៊ឹងឯកភាពគ្នាស្រួលបួលហើយរាយការណ៍ទៅលើ មិនដែលឃើញអ្នកណាមួយ ខ្ញុំមិនចាំ ពិតជាមិនចាំថាមានអ្នកណាមួយរួចខ្លួនដែលខាងលើសម្រេចបដិសេធសេចក្តីរាយការណ៍របស់ខ្ញុំនោះទេ អត់មាន ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** លោកបានឆ្លើយថា នៅក្នុងចំណោមជនជាតិ ជនបរទេសដែលត្រូវចាប់ខ្លួនបញ្ជូនមកស-២១ នោះ គឺមានជនបស្ចិមប្រទេស ពួកជនបរទេសខាងបស្ចិមប្រទេសថាមានបួននាក់ ។ ថាតើពួកបស្ចិមប្រទេសបួននាក់នោះ ដែលគេចាប់មកដល់ស-២១ នេះ គេចាប់បញ្ជូនពីកន្លែងណាមក?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ពួកនេះត្រូវកងជើងទឹកដែលយើងខ្ញុំធ្លាប់ហៅថា កងពល ១៦៤ របស់បង មុត នេះ បញ្ជូនពីកំពង់សោមមកឆ្លងតាមអចិន្ត្រៃយ៍មជ្ឈិម ហើយគេបញ្ជូនមកស-២១ ដូច្នេះពួកទាំងបួននាក់នេះមកពីរលើក ។ មួយលើកពីរនាក់ សុទ្ធតែពួកកងពល១៦៤ចាប់ទាំងអស់ហើយបញ្ជូនមកស-២១ តាមរយៈអចិន្ត្រៃយ៍មជ្ឈិម ឬតាមរយៈសេនាធិការ ។ សូមទោស សូមអរគុណ ។

**ស៖** នៅពេលចាប់មនុស្សបញ្ជូនមកដល់មន្ទីរស-២១ តើត្រូវមាននីតិវិធីអនុវត្តជាក់លាក់ ឬក៏ទៀងទាត់ដែរឬទេ? ឧទាហរណ៍ដូចជា នៅក្នុងអំឡុងពេលបញ្ជូនពីកន្លែងចាប់ខ្លួនមកស-២១ ត្រូវចងដៃទាំងពីរទៅក្រោយ ឬក៏ដាក់ខ្នោះដៃទាំងពីរទៅក្រោយ ឬក៏ត្រូវដាក់ខ្នោះជើងទាំងពីរ ត្រូវរុំមុខដោយក្រណាត់ជាដើមរហូតដល់ពេលនាំចូលដល់មន្ទីរស-២១ តើត្រូវបំពេញបែបបទយ៉ាងម៉េចទៀត មុននឹងធ្វើការបែងចែកទៅតាមបន្ទប់ឃុំឃាំងនីមួយៗ?

**ឆ៖** រឿងនីតិវិធី ឬក៏ហៅថាមាគ៌ាសកម្មភាព តាមភាសាជំនាន់នុ៎ង ខ្ញុំអត់ជាក់ស្តែងទេៗ អ្នកប្រតិបត្តិការទទួលខុសត្រូវចំពោះមុខខ្ញុំ ក្នុងឋានៈជាបក្សមន្ទីរធ្វើម៉េចកុំឲ្យតែរត់រួច ធ្វើម៉េចកុំឲ្យតែប្រតិកម្មតដៃបាន ។ បើសិនជារត់រួច ប្រតិកម្មតដៃបាន ត្រូវតែរាយការណ៍ឲ្យខ្ញុំ ដើម្បីឲ្យអ្នកប្រតិបត្តិការទទួលខុសត្រូវចំពោះមុខបក្ស ។ នេះខ្ញុំគិតតែប៉ុន្មាននុ៎ង ដូច្នេះនៅតែវិធីល្អិត អាច ។ ជាទូទៅដឹកមកពីចម្ងាយមានដាក់ខ្នោះដៃ ខ្នោះជើងផង បិទមុខ ហ្នឹងពីចម្ងាយ ។ នៅភ្នំពេញអាចត្រឹមតែចងមុខ ហើយដាក់ខ្នោះដៃ ក៏សឹងតែថាបាន ។ ក៏ប៉ុន្តែមានមួយចំនួន ឧទាហរណ៍ពួកមកពីក្រសួងការបរទេសម្នាក់ឈ្មោះ វ៉ែន ។ គាត់ធ្លាប់ស្គាល់ខ្ញុំ ចូលមក ខ្ញុំឃើញគាត់ គាត់ឃើញខ្ញុំ ទឹកភ្នែករៀងខ្លួន គេច ខ្ញុំគេច ។ ដូច្នេះពេលនោះ អត់ចងមុខទេ មានមួយចំនួនជាស្រីអត់ចងមុខមែន ។ ក៏ប៉ុន្តែ មិនដឹងជាមានប៉ុន្មាននាក់ទេ ឬក៏តែម្នាក់ឯង ឬជាយ៉ាងម៉េចទេ ខ្ញុំមិនដឹងទេ ក៏ប៉ុន្តែមាន ។

សរុបមក តួនាទីទទួលខុសត្រូវរបស់ខ្ញុំ ដែលគិតគូរបំផុត គឺតែប៉ុន្មាននុ៎ងឯង កុំឲ្យរត់រួច កុំឲ្យតដៃ

បាន ។ បើរត់រួច តដៃបាន ត្រូវតែរាយការណ៍ឲ្យខ្ញុំ ។ នេះខ្ញុំគិតតែប៉ុននុ៎ង ។ សូមចប់ សូមជម្រាបលោកប្រធានប៉ុណ្ណេះ ។

[១០:១៨:០៩]

**សៈ** ការចងរុំមុខហ្នឹង គឺប្រព្រឹត្តទៅរហូតដល់ពេលណាទើបស្រាយក្រណាត់រុំមុខចេញ ពីជនដែលត្រូវចាប់ឃុំឃាំងនេះ?

**ឆៈ** ខ្ញុំៗជម្រាបប្រសាសន៍លោកប្រធាន គឺខ្ញុំអត់ច្បាស់ទេ ប្រហែលជាថតរួច ឬក៏ចូលទៅដល់ក្នុងបន្ទប់ឃុំឃាំងក៏មិនដឹង យ៉ាងហោចណាស់ក៏ត្រឹមថតរួចដែរ ។ ខ្ញុំគិតថា ជាទូទៅអ្នកដែលចងមុខពីនាយ ប្រហែលជាទល់ទៅតែដល់កន្លែងឃុំឃាំង ដែលគេដាក់ខ្នោះជើង បានគេស្រាយមុខ ។ នេះគឺខ្ញុំវិភាគជូនដោយ វិភាគហើយនិងសន្និដ្ឋានជូនប៉ុណ្ណឹង ។

**សៈ** តើមានលក្ខណៈវិនិច្ឆ័យដូចម្ដេចដែរ រវាងមនុស្សត្រូវឃុំឃាំងក្នុងបន្ទប់ឃុំឃាំងរួម ហើយនិងមនុស្សត្រូវឃុំឃាំងក្នុងបន្ទប់ឃុំឃាំងតូចៗ ដែលយើងបានឃើញរូបភាពនៃកន្លែងឃុំឃាំងហ្នឹងកាលពីបង្កើត ស-២១ ឃើញមាននៅពីរប្រភេទ គឺបន្ទប់ឃុំឃាំងរួមធំ ហើយនិងបន្ទប់ឃុំឃាំងតូចៗ ។ យើងចង់ដឹងអំពីលក្ខណៈវិនិច្ឆ័យទេ ថាតើមនុស្សប្រភេទណាដែលគួរតែត្រូវបានឃុំឃាំងនៅបន្ទប់ឃុំឃាំងរួម ហើយនិងមនុស្សប្រភេទណា ដែលត្រូវឃុំឃាំងនៅក្នុងបន្ទប់តូចៗជាលក្ខណៈឯកជនម្នាក់ៗ ដែលយើងបានឃើញរូបភាពពីពេលមុនរួចហើយ?

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះខ្ញុំសូមបែងចែកជាបីប្រភេទ៖

ប្រភេទទីមួយ មនុស្សសំខាន់បំផុតដែលបក្សយកចិត្តទុកដាក់ចង់បានចម្លើយ ហើយសំខាន់បំផុតនេះ យើងកំណត់តាមឋានានុក្រមមិនបានទេ គឺសន្ធតតាមឋានានុក្រម ហើយនិងតាមពេលវេលាផង ។ ឧទាហរណ៍ សួស សុផាន ជាអនុលេខាកងពលទេ ក៏ប៉ុន្តែសម្រាប់ពេលគាត់ ដែលត្រូវចាប់ គាត់ហ្នឹងហើយសារសំខាន់ជាងគេ ។ ដូច្នេះ ពួកសារសំខាន់ជាងគេអត់ចូលទៅក្នុងមន្ទីរឃុំឃាំងដែលយើងប្រើនៅក្នុងវិទ្យាល័យពញាយ៉ាតទេ គឺស្ថិតនៅខាងក្រៅ គេហៅថា គុកពិសេស ហើយអ្នកសួរចម្លើយក៏យើងខ្ញុំប្រគល់ទៅឲ្យមិត្តប៉ុន ដែលជាអ្នកខ្ញុំជឿទុកចិត្តជាងគេសួរ ។ នេះមនុស្សពិសេស ។

មនុស្សដែលមានសារសំខាន់ជាទីពីរ យើងខ្ញុំបញ្ចូលទៅក្នុងបន្ទប់ឯកជនមួយៗៗ ដូចយើងឃើញទាំងបីជាន់សុទ្ធតែមានបន្ទប់ឯកជនហ្នឹង នៅពេលនេះដើម្បីកុំឲ្យឆ្លងឆ្លើយគ្នា ដល់សួរចម្លើយរួចបានយកទៅដាក់ក្នុងបន្ទប់រួម ។ ឯចំណែក អ្នកខ្លះដែលមានសារសំខាន់តិចតួច ខាងសំណួរចម្លើយ

យើង ខ្ញុំដាក់បន្ទប់រួម ។ ឧទាហរណ៍ដូចជាមនុស្សនៅក្នុងឯកសារ D159/4.10 មកដល់អត់ទៅបាន ដាក់ក្នុងបន្ទប់ដោយឡែកទេ ព្រោះអត់ត្រូវការសួរ ។

ដូច្នេះ អ្នកទោសដែលចូលមកចែកជាបីប្រភេទអ៊ីចឹង ។ សំខាន់ នៅគុកពិសេស, មនុស្សសំខាន់ធម្មតា នៅបន្ទប់ដាច់ដោយឡែក ហើយមនុស្សដែលគេមិនយកចិត្តទុកដាក់នឹងរឿងសួរនឹងរឿងអី នៅបន្ទប់ទូលាយ ឬអ្នកដែលសួររួចហើយ ក៏នៅក្នុងបន្ទប់ទូលាយដែរ ។ នេះសូមបញ្ជាក់ជូនលោកប្រធានប៉ុណ្ណេះ ។

**ស៖** អរគុណ ។ ពីមុនបានលើកឡើងបញ្ហានេះម្តងហើយ ប៉ុន្តែនៅពេលនេះខ្ញុំចង់ដឹងថា អំពីពេលវេលា ការរៀបចំបន្ទប់ឃុំឃាំងជាបន្ទប់តូចៗសម្រាប់ដាក់មនុស្សម្នាក់ៗហ្នឹង ចាប់ផ្តើមធ្វើរបៀបនេះពីពេលណាមក? ហើយអ្នកណាជាអ្នកផ្តើមគំនិតនាំឲ្យធ្វើដូច្នេះ?

**ឆ៖** ការដែលបញ្ចូលមនុស្សពីក្រៅទៅក្នុងបរិវេណវិទ្យាល័យពញាយ៉ាត ក៏ខ្ញុំជាអ្នកផ្តើមគំនិតហើយសូមអនុញ្ញាតមេ មេយល់ស្រប បានខ្ញុំប៊ានប្រើ នេះទីមួយ ។ ដល់កាលណាបានអនុវិទ្យាល័យពញាយ៉ាតនេះមកប្រើសម្រាប់ជាគុកហើយ ខ្ញុំជាអ្នកផ្តើមគំនិតប្រាប់ មិត្តហ៊ី ឲ្យធ្វើបន្ទប់តូចៗ អត់បានសុំយោបល់មេទេ នេះជាគំនិតផ្តើមរបស់ខ្ញុំ ហើយសម្រេច ខ្ញុំជាអ្នកសម្រេច ខ្ញុំជាអ្នកបញ្ជា ។ នេះសូមបញ្ជាក់ជូនលោកប្រធានប៉ុណ្ណេះ ។

**ស៖** អរគុណ ។ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនដោយផ្អែកទៅលើចម្លើយសារភាពរបស់អ្នកដទៃ តើអ្វីខ្លះទៅដែលជាកំហុសពិតប្រាកដ ដែលអាចទម្លាក់កំហុសទៅលើអ្នកដែលត្រូវចាប់ខ្លួន?

**ឆ៖** ការចាប់ខ្លួនដែលពឹងផ្អែកទៅលើសេចក្តីសារភាពរបស់អ្នកដទៃ តាមឯកសារដែលនៅសល់សូមសង្ខេបជូនដូចតទៅ៖

ទីមួយមនុស្សសំខាន់មែនទែន ដូច សួស នៅ ហៅ ឈូក លេខាតំបន់២៤ ដែលមានបង្អែកជាលេខាភូមិភាគបូព៌ា បងភឹម នោះ អចិន្ត្រៃយ៍ត្រូវការគិតគូរហ្មត់ចត់ធ្វើម៉េចទាមទារឲ្យ បងភឹម គាត់យល់ស្របអាហ្នឹងបានៗ ។ ដូច្នេះ ឯកសារច្រើនណាស់ ហើយប្រជុំអចិន្ត្រៃយ៍ពេញអង្គ សម្រាប់សម្រេចបញ្ហានេះ ។ ក៏ប៉ុន្តែ អ្នករាយរង ឯកសារដែលនៅសល់ ឃើញមួយ គឺបញ្ជីដែលខ្ញុំសរុប ដែលស-២១ សរុប យកចម្លើយប្រាំបួននាក់ទៅសរុប ថាតើប្រាំបួននាក់នេះឆ្លើយដាក់អ្នកណាខ្លះ? ដែលការិយាល័យសហព្រះរាជអាជ្ញាទើបនឹងបង្ហាញខ្ញុំ ។ នេះជាភស្តុតាងមួយទៀត របៀបធ្វើការក្នុងការដែលសេនាធិការសម្រេចចាប់ចងមនុស្ស ។

ហើយរឿងមួយទៀត គឺការប្រជុំ ដែលខ្ញុំទៅប្រជុំនឹងគេ ជាមួយនឹង១៧០ ហើយនិង២៩០ បានឯកសារទៅ យើងខ្ញុំបូកសរុបទៅជូនមេរួចហើយ ដល់ទៅមេសួរៗលេខាបក្សគេហ្នឹង លេខាអង្គភាពគេហ្នឹង "ម៉េចមិត្ត សុខ មនុស្សនេះល្អមទេ?" បើមិត្តសុខ គេថាល្អម សម្រេចចាប់ ។ នេះជាកិច្ចដំណើរការមួយបែបទៀត ។ បើគេថាទេកុំអាលបង អាហ្នឹងក៏មេមិនទាន់សម្រេចឲ្យចាប់ដែរ នេះជាកិច្ចដំណើរការមួយបែបទៀត ។

កិច្ចដំណើរការមួយបែបទៀត គឺមេ ជាពិសេសសេនាធិការ កាលណាគាត់អានហើយ គាត់ប្រគល់ជូន មិត្តពីន ពិនិត្យ ។ ដូច្នេះ ឃើញបញ្ជីឈ្មោះហ្នឹងប៉ុន្មាន ឲ្យខាង៧០៣ ដែលមាន បងពីន ធ្វើជាលេខាហ្នឹង សម្រេចទៅតាមចម្លើយនេះ ដូច្នេះមួយបែបទៀត ។

ដូច្នេះ បាតុភាពដែលអនុវត្តនៅក្នុងអង្គភាពផ្សេងៗនៅភ្នំពេញ យើងខ្ញុំឃើញរបៀបនេះ ហើយសូមសរុបរាយការណ៍ជូនលោកប្រធានតាមការចងចាំលើឯកសារដែលនៅមានសល់ ។ សូមអរគុណ ។ សូមបញ្ចប់ប៉ុណ្ណេះ ។

**ស៖** តើលោកធ្លាប់បានថ្នាក់លើពិគ្រោះយោបល់ជាមួយលោកអំពីការសម្រេចចាប់ខ្លួន និងរបៀបចាប់ខ្លួនមនុស្សដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រវាងខ្ញុំ ហើយនិងមេខ្ញុំ គឺសុន សេន ការងារស្អិតណាស់គាត់តាមដាន ។ ដូច្នេះ គាត់មិនពិគ្រោះទេ ក៏ប៉ុន្តែ ការងារសួរចម្លើយរបស់ខ្ញុំគាត់តាមដានក្រោយខ្ញុំរាយការណ៍ដល់ត្រឹមណា សុំយោបល់ប៉ុនណា យ៉ាងម៉េចអីយ៉ាងម៉េចគឺអ៊ីចឹង ។ ក៏ប៉ុន្តែ រឿងចាប់ គាត់ហៅខ្ញុំយកទៅប្រាប់ "អាហ្នឹងគេចាប់ហើយ មិត្តឯងរៀបចំយ៉ាងម៉េច? គេយកទៅប្រគល់ឲ្យ ឧទាហរណ៍គេយក កុយ ធួន ទៅប្រគល់ឲ្យ មិត្តឯងរៀបចំយ៉ាងម៉េច?" ខ្ញុំប្រាប់ថា "អានេះបន្ទប់ខ្ញុំ នៅផ្លូវនេះអ៊ីចឹងរៀបចំជូនគាត់"គាត់ថា "អឺ!បាន ឥឡូវម៉ោងប៉ុណ្ណេះ មិត្តប៉ុន ដឹក កុយ ធួន យកទៅប្រគល់ឲ្យហើយ"។

ដូច្នេះ វាមានការពិគ្រោះគ្នាអ៊ីចឹង ដើម្បីចៀសវាងកុំឲ្យខ្ញុំ ខាង ស-២១ បាត់ម្ចាស់ការ ។

**ស៖** ការដែលទៅដឹកជញ្ជូនមនុស្សពីខេត្តបាត់ដំបងមកកាន់មន្ទីរស-២១ មានប៉ុន្មានលើក? ហើយក្នុងមួយលើកៗដោយមធ្យោបាយអ្វីខ្លះ ដោយរថយន្ត? ហើយក្នុងមួយលើកៗហ្នឹងមានរថយន្តប៉ុន្មាន? ដឹកមនុស្សមកហ្នឹងប៉ុន្មាននាក់? ហើយរថយន្តហ្នឹងត្រូវរៀបចំយ៉ាងដូចម្ដេច ក្នុងការដឹកជញ្ជូនមនុស្សពីផ្លូវ ដែលមានចម្ងាយរហូតដល់បីរយគីឡូម៉ែត្រដូច្នេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មនុស្សដែលទៅទទួលពីខាងក្រៅ បើតាមខ្ញុំចាំមិនច្រើន

មិនច្រើនលើសរហូតទៅដល់ដប់នាក់ទេ ។ ដូច្នេះ មានខ្នោះជើងមួយទៅ ខ្នោះដៃខ្លះ ហើយប្រហែលជាសំពត់រុំមុខមួយផង ខ្លះទៀត ។ ដូច្នេះ ខ្ញុំសូមនិយាយដោយវិភាគ ហើយនិងសន្និដ្ឋានទេ ប៉ុណ្ណេះ ។ ដូច្នេះ រថយន្តដែលទៅទទួលនេះអត់មានរថយន្តស្អីទេ គឺអាកាត់ៗចិន បាំងដំបូលឲ្យស្រួលបួលទៅ ហើយខាងក្រោយគឺបាំងដែរ ជិត ។ នោះគឺរបៀបហ្នឹង ។

**សៈ** ទៅដឹកមនុស្សពីខេត្តបាត់ដំបងមក ស-២១ ហ្នឹងមានប៉ុន្មានលើកដែរ? លោកយល់ហើយបញ្ហាថា មួយលើកហ្នឹងអាចមានមនុស្សមិនដល់ដប់នាក់ទេ អ៊ីចឹងមិនអាចប្រើរថយន្តលើសពីមួយទេ ។ បានន័យថា មួយគ្រឿងជាការសមរម្យហើយ ។ ប៉ុន្តែ ដឹកជញ្ជូនប៉ុន្មានលើកដែរ?

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន! ដឹកមកហ្នឹង ប៉ុន្មានលើកខ្ញុំមិនចាំទេ នឹកមិនឃើញទេ គ្រាន់តែចាំបានថា ពួកកងពិសេសស-២១ ចេញទៅពីរផ្លូវ ពេលខ្លះចេញទៅតាមផ្លូវលេខមួយ ពេលខ្លះចេញទៅតាមផ្លូវលេខប្រាំ ប៉ុន្មានលើកៗខ្ញុំមិនដឹងទេ ។ ឯចំណែក លិខិតដើរផ្លូវពិសេសហ្នឹង មានតែពីរទេ មិនដឹងជាទៅទិសណាប៉ុន្មានៗខ្ញុំអត់ចាំទេ ។ នេះសូមជម្រាបបញ្ជាក់ដោយស្មោះត្រង់អ៊ីចឹង ។

**សៈ** អំមិញដូចជាលោកបានឆ្លើយខ្លះហើយ ប៉ុន្តែយើងចង់ដឹងច្បាស់ពីព្រោះចំណុចនេះជាចំណុចសំខាន់ យើងសួរថាការចាប់ខ្លួនមនុស្សផ្សេងទៀត ដូចជាសមាជិកគណៈកម្មការមជ្ឈិមបក្ស ឬក៏គណៈអចិន្ត្រៃយ៍មជ្ឈិមបក្ស តើបុគ្គលណាជាអ្នកសម្រេច? ហើយប្រតិបត្តិការក្នុងការចាប់ខ្លួនប្រភេទនេះប្រព្រឹត្តទៅយ៉ាងដូចម្តេច? បញ្ហានេះគឺលោកបានឆ្លើយហើយលើបញ្ហាជាក់លាក់មួយចំនួន ដូចជាករណីកុយ ធួន ករណី ប៉ង់ ជាដើម យើងមិននិយាយទេ ទីមួយសូមបញ្ជាក់ពីការសម្រេចលើមនុស្សដែលសំខាន់របៀបនេះ ។ ជាការពិតណាស់ គឺលោកបានឆ្លើយច្រើនលើកច្រើនសារហើយ ប៉ុន្តែនៅក្នុងអំឡុងពេលនោះ គឺជារឿងអនុវត្តគោលនយោបាយទូទៅ ។ ឥឡូវនេះ គឺការអនុវត្តជាក់លាក់នៅក្នុងប្រតិបត្តិការជាក់លាក់ តើការប្រព្រឹត្តិទៅយ៉ាងដូចម្តេច? គឺដូចជាករណី ឧទាហរណ៍ដូចជា វ៉ន វេត ដែលជាមនុស្សសំខាន់នៅក្នុងជួរបក្សដែរនោះ?

**ឆៈ** អំពីករណីចាប់ខ្លួន វ៉ន វេត មុននឹងឈានទៅដល់ការចាប់ខ្លួនឯកសារទៅពីស-២១ ដូចជាជាប់មួយឆ្នាំនោះ យូរដែរ ។ ហើយដើម្បីសម្រេចចាប់ខ្លួន ខ្ញុំអត់មានពត៌មានថាតើគេប្រជុំអចិន្ត្រៃយ៍ពេញអង្គដែរឬក៏អត់? ខ្ញុំអត់ដឹងទេ ។ ខ្ញុំដឹងថា គេចាប់ខ្លួន វ៉ន វេត នៅមន្ទីរមជ្ឈិម ពេលនោះល្ងាចហើយប្រហែលជាម៉ោងប្រាំមួយហើយ ឬក៏ជិតប្រាំមួយ ។ មិត្តលីន ទូរស័ព្ទទៅខ្ញុំ "បងឌុចអ្ហា! ចាំទទួលអីវ៉ាន់បីកញ្ចប់ធំៗ បើតាមខ្ញុំចាំមានបង វន ផង, មានបង គី ឈ្មោះដើម គង់ សុផល ផង

អនុលេខាភូមិភាគពាយព្យ ហើយនិងបង ចេង អន មួយផង ដូចបីនាក់ហ្នឹង ។ ទៅដល់ខ្ញុំលើកចុះពីឡាន គេៗ-- ថ្ងៃនុំងអត់ដាក់ខ្នោះទេ អាហ្នឹងខ្ញុំចាប់ច្បាស់នឹងភ្នែក ។ នឹកពេលណាឃើញពេលនុំង គេយក អាខ្សែរូតអាល្អឺម៉ង់អីទាញអ៊ីចឹងទៅ ហើយទាញថយក្រោយមិនបាន-- *(សំឡេងដួល)*

ដល់រួមអ៊ីចឹងទៅ ទាញថយក្រោយអត់បានទេ ពេលខ្ញុំទៅលើក វ៉ន វេត ចេញពីឡានមក ខ្ញុំ ឃើញអាខ្សែហ្នឹង ហើយឲ្យគេបណ្តើរគាត់យកទៅ ។ ដូច្នេះ ការចាប់ខ្លួនបងវន ជាក្នុងករណីពិសេស ដែលគេចាប់នៅក្នុងមន្ទីរ៨៧០ ឯណោះ ។ ហើយល្បឺមកក្រោយទៀត ក៏ឃើញបញ្ជាក់ថាចាប់នៅ៨៧០ មែន ។ នេះសេចក្តីសម្រេច ខ្ញុំអត់ដឹងទេ ។ ឯចំណែកការដែលស-២១ ទទួលបញ្ជាឲ្យប្រមូលឯកសារ អ្នកណាឆ្លើយដាក់បុគ្គលនុំង ខ្ញុំចាំបានធ្វើប្រហែលជាពីរដង ឬបីដងយ៉ាងច្រើន ។

ទីមួយដែលខំខ្លាំងមែនទែនគឺ ឈូក ហ្នឹងតែម្តង ខ្ញុំអត់ងងុយបីយប់បីថ្ងៃ ដឹកនាំការប្រមូល សំណុំរឿង ហើយក្រោយមកទៀត មិនដឹងជាចំពោះអ្នកណា ។ ក៏ប៉ុន្តែ ចំពោះករណី វ៉ន វេត អត់មាន វរល់អំពល់អីច្រើនទេ គឺសំណុំរឿងវាទៅអចិន្ត្រៃយ៍ហ្នឹងហូរហែទៅ ។ រួចដល់គាត់សម្រេចចាប់ គឺគាត់ សម្រេចនៅនុំង ឯករាជ្យពីស-២១ៗ អត់ដឹងទេ ។ នៅពេលដែលគេចាប់បានហើយ បានគេឲ្យស-២១ រង់ចាំទទួល។ កង ចាប ក៏អ៊ីចឹង គេឲ្យស-២១ រង់ចាំទទួល ។ លេខាភូមិភាគទាំងអស់សុទ្ធតែឲ្យស-២១ រង់ចាំទទួល ដែលជាសមាជិកមជ្ឈិម ស-២១ អត់ដឹងទេ ។ ដូច្នេះ សមាជិកមជ្ឈិម ដែលចាប់នៅនឹង ស-២១ បើតាមខ្ញុំចាំ គឺមានតែ កុយ ធួន ហើយនិង ឈឹម សំអោក ហៅ ប៉ង់ ហ្នឹង ដែលគេឲ្យដើរមក ឲ្យចាប់តែម្តង ប៉ង់ ។ នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

ដូច្នេះ ក្របខ័ណ្ឌណាសម្រេច ខ្ញុំក្តាប់អត់បានទេ ក្តាប់បានតែមួយគត់ ក្របខ័ណ្ឌសម្រេច គឺ អចិន្ត្រៃយ៍ពេញអង្គ ។

[១០:២៩:១១]

**ស៖** ចុះការដែលបញ្ជូនឈ្លើយសឹករបស់វៀតណាម និងជនស៊ីវិលវៀតណាម ពីតំបន់ជម្លោះ ដែលស្ថិតនៅតាមព្រំដែនកម្ពុជា-វៀតណាម ឬក៏តំបន់ជិតៗព្រំដែននោះ មកកាន់ ស-២១ ហ្នឹង តើមាន ការប្រតិបត្តិការដោយពេលណាមួយ ឬប្រតិបត្តិការដោយមន្ទីរស-២១ ទៅដឹកជញ្ជូនមនុស្សនោះមក កាន់មន្ទីរស-២១ដែរឬទេ? ឬក៏សុទ្ធតែអង្គភាពសាមី ដែលបានចាប់ខ្លួនមនុស្សទាំងនោះ ជាអ្នកបញ្ជូនមក ដល់ ស-២១ ឬ ស-២១ នៅរង់ចាំទទួលតែនៅក្រុងភ្នំពេញឯណោះទេ?

**ឆ៖** កន្លងមក ខ្ញុំនឹកមិនឃើញថា ខ្ញុំបានចាត់តាំងកម្លាំងឲ្យទៅទទួលនៅ ដល់ទៅខាងព្រៃវែង ឬក៏ស្វាយរៀងទេ ឬក៏អ្នកលឿងទេ ។ ប៉ុន្តែ ដល់គិតយូរទៅ យី! ក្រែងខ្ញុំចាំមិនច្បាស់ ។ ដូច្នេះ បានខ្ញុំ--រឿងនេះនិយាយស្ទាក់ស្ទើរសម្បើមណាស់ មិនដឹងជាយ៉ាងម៉េចពិតប្រាកដទេ? មិនដឹងជាបានបញ្ជូនទៅ ឬក៏អត់? បើបញ្ជូនទៅប៉ុន្មានលើក? នៅឆ្នាំ៧៧មានទេ? ឬក៏មានតែ៧៨? ខ្ញុំអត់ច្បាស់ទេ ។ ដូច្នេះ សូមទុកបញ្ហានេះជូនលោកប្រធាន ហើយនិងអង្គជំនុំជម្រះទាំងមូលបញ្ជាក់ មិត្តហ៊ុយ ហើយបើសម្ដីរបស់គេមានឈរលើឯកសារអីច្បាស់លាស់ ខ្ញុំទទួល ខ្ញុំចាំអត់ច្បាស់ទេ ។ ព្រោះខ្ញុំដូចជម្រាបអ៊ីចឹង អត់ទៅមានបានគិតគូរដល់ការចាប់ចងការអីទេ គ្រាន់តែធ្វើម៉េចអ្នកដែលចេញទៅប្រតិបត្តិការទទួលខុសត្រូវចំពោះមុខបក្សស-២១ "កុំឲ្យគេតដៃបាន កុំឲ្យរត់រួច" ខ្ញុំសូមរំឭកបញ្ហានេះដដែលឡើងវិញប៉ុណ្ណឹង ។ សូមចប់ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ ឥឡូវនេះ ដល់ម៉ោងត្រូវឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់សែសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលរបស់យើងតទៅទៀត ។

*[សវនាការសម្រាកពីម៉ោង ១០:២០នាទី ដល់ម៉ោង ១០:៤០នាទី]*

**សួរដោយប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។

**ស៖** លោក កាំង ហ្គេកអ៊ាវ តើក្នុងនាមលោកជាប្រធាននៃមន្ទីរ ស-២១ លោកធ្លាប់បានទទួលនូវរបាយការណ៍ផ្ទាល់ពីអង្គភាពរដ្ឋបាល ឬអង្គភាពយោធា អំពីការចាប់ខ្លួន និងការបញ្ជូនមនុស្សមកកាន់ ស-២១ ដោយផ្ទាល់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គ្រប់សេចក្ដីរាយការណ៍ពីអង្គភាពផ្សេងមក គឺត្រូវតែឆ្លងកាត់មេ ឆ្លងកាត់លោកគ្រូ សុន សេន ជៀសមិនរួច ។ យើងខ្ញុំមិនមានសិទ្ធិទាក់ទងគ្នាផ្ទាល់ ទាល់តែសោះ ។ សូមជម្រាបប៉ុណ្ណោះ ។

**ស៖** អំមិញមានសំណួរមួយយើងបានសួរទៅលោកហើយ អំពីការផ្អែកលើចម្លើយសារភាព ប៉ុន្តែ នៅក្នុងសំណុំរឿង ឯកសារជាច្រើន ហាក់ដូចជាបានបង្ហាញនូវ ពាក្យមួយដែលមានការ បញ្ជាក់នេះ ។ តើយើងសួរចំណុចនេះម្តងទៀត ដើម្បីឲ្យបានច្បាស់ ថាតើសេចក្តីសម្រេចឲ្យចាប់ខ្លួនគឺផ្អែកទៅលើចម្លើយសារភាពនៅ ស-២១ ដែលមានការឆ្លើយដាក់ថា "ជាជនក្បត់" តើការណ៍នេះពិតមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ការដែលចាប់ខ្លួនបញ្ជូនមក ស-២១ វាឈរលើចម្លើយការចាប់ខ្លួនបញ្ជូនមនុស្សមកស-២១ អចិន្ត្រៃយ៍មជ្ឈិម ឬក៏សេនាធិការ គេឈរលើចម្លើយរបស់ស-២១។ ទីមួយ ទាល់តែចម្លើយច្រើន ដែលគេវិភាគថា វាសមល្មមហើយ ហើយមានការព្រមព្រៀងគ្នារវាងលេខាសេនាធិការហើយនិងលេខាកងពល អាហ្នឹងគេបញ្ជូនមកមែន ។ នេះជារឿងពិត ។ ក៏ប៉ុន្តែ ក្នុងនោះវាបង្កប់ន័យមួយទៅហើយថា លេខាកងពលក៏គេគិតគូរដល់ការដែលគេមានសិទ្ធិអំណាចការពារតាមដានទទួលខុសត្រូវលើអង្គភាពគេ លើប្រវត្តិរូបរបស់មនុស្សម្នាក់ៗដែរ ។

សរុបមក បើយើងនិយាយថា ឈរលើឯកសាររបស់ស-២១ ត្រូវហើយ ប៉ុន្តែ ទាល់តែច្រើនចម្លើយផ្គុំគ្នា ហើយទាល់តែលេខាកងពលគេសុខចិត្ត ។ នេះខ្ញុំគ្រាន់តែសូមបន្ថែមប៉ុនទុំងឯង ថាទាល់តែច្រើនឯកសារ ហើយលេខាកងពលគេសុខចិត្ត ។ សូមបញ្ចប់ ។

**ស៖** សំណួរមួយទៀតពាក់ព័ន្ធនឹងការចាប់ខ្លួនដែរ ប៉ុន្តែមានលក្ខណៈពិសេសដោយឡែករបស់វា លោកបានឆ្លើយហើយថា បុគ្គលិក ស-២១ មួយចំនួនត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរអប់រំកែប្រែព្រៃស ដើម្បីកសាងខ្លួន ។ តើពួកគេមានកំហុសយ៉ាងណាខ្លះទៅ ដែលជាលក្ខខណ្ឌខណៈនាំឲ្យចាប់បញ្ជូនគាត់ទៅកាន់ព្រៃ-ស ដើម្បីកសាងខ្លួន? តើលោកអាចនិយាយប្រាប់អំពីបញ្ហានេះ ដល់អង្គសវនាការបានដែរឬទេ?

[១១:១០:៣៦]

**ឆ៖** មនុស្សដែលគណៈកម្មាធិការស-២១ បញ្ជូនពីមជ្ឈមណ្ឌលភ្នំពេញទៅព្រៃ-ស ខ្ញុំនៅចាំថាមានពីរករណី ។ ករណីទីមួយ មានសាច់ញាតិជិត ដែលត្រូវស-២១ ចាប់ ឬក៏អង្គភាពផ្សេងទៀតឆ្លាយចាប់ ហើយបញ្ជូនមកស-២១ ។ ដូច្នេះ ត្រូវបញ្ជូនទៅព្រៃ-ស រឿងដែលយើងខ្ញុំនៅចាំច្បាស់គឺទីមួយ មិត្តម៉េត ដែលមកធ្វើសាក្សីនេះ បងបង្កើតរបស់គាត់ឈ្មោះ មិត្ត ម៉េង ត្រូវចាប់ ។ ដូច្នេះគណៈកម្មាធិការស-២១ ជាស្វ័យតប្រវត្តិត្រូវអនុវត្តមាគ៌ាមួយដែលបក្សកំណត់ទុក សាច់ញាតិបងប្អូនរបស់ខ្មាំង ត្រូវតែ

ទុកនៅក្នុងកន្លែងអប់រំសាថ្មី តាមដានពិនិត្យមើលសកម្មភាពតទៅទៀត ។ នេះមិត្ត ម៉េត នេះមួយ បងប្អូនបង្កើតរបស់ មិត្តម៉េង ។ ឯចំណែកករណីទីពីរ ករណីដែលខ្លួនគេល្មើសវិន័យ អប់រំហើយមិនបានមិនស្តាប់ អាហ្នឹងក៏គណៈកម្មាធិការ ស-២១ បញ្ជូនទៅព្រៃសដែរ ទៅលត់ដំសាថ្មីឡើងវិញ ។ ករណីនេះខ្ញុំបាទ រកឈ្មោះនឹកមិនទាន់ទេ មិនដឹងជាអ្នកណាខ្លះទេ ភ្លេចវង្វេងអស់ហើយ ។ សូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** អ៊ីចឹងបានសេចក្តីថា ការណ៍លដែលសម្រេចបញ្ជូនបុគ្គលិកស-២១ ទៅកាន់មន្ទីរអប់រំកែប្រែព្រៃ-ស ដើម្បីកសាងខ្លួននុ៎ង គឺមិនមានត្រូវការសម្រេចពីថ្នាក់លើទេ បានន័យថា សម្រេចដោយគណៈកម្មាធិការ នៃមន្ទីរស-២១ ។ ជាការត្រឹមត្រូវទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពិតជាត្រឹមត្រូវហើយ ។

**ស៖** អរគុណ ។ ហើយចុះគ្រួសាររបស់គេ របស់អ្នកដែលត្រូវបានចាប់ បញ្ជូនទៅមន្ទីរអប់រំកែប្រែព្រៃ-សនោះ តើគ្រួសារគេ ខាងគណៈកម្មាធិការហ្នឹងចាត់ការយ៉ាងម៉េចដែរ?

**ឆ៖** បើចាប់ទៅប្តី ប្រពន្ធក៏ត្រូវតែទៅជាមួយនុ៎ងដែរ បើមានប្រពន្ធ ចៀសមិនរួចពីទៅទេ មានប្រពន្ធ មានកូន ទៅទាំងអស់គ្នាហ្នឹង ។

**ស៖** ចុះចំណែកឯអ្នកដែលមានកំហុសធ្ងន់ធ្ងរដូចជា លោកបានឆ្លើយថាមានការចាប់ខ្លួនបញ្ជូនមកចូលនៅក្នុងស-២១ ទាំងបុគ្គលិកស-២១ គឺគុកទួលស្លែងបច្ចុប្បន្ន ទាំងបុគ្គលិកធ្វើការនៅព្រៃ-ស ។ ចុះចំណែងគ្រួសារញាតិសន្តានរបស់គេ ដែលគេរស់នៅជាមួយនឹងអ្នកដែលត្រូវចាប់ខ្លួននោះត្រូវចាត់ការយ៉ាងម៉េចដែរ?

[១១:១៣:៤៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មនុស្សដែលត្រូវចាប់ខ្លួនយកមកដាក់ឃុំឃាំង ហើយធ្វើទារុណកម្មសួរចម្លើយដល់ទៅថ្ងៃក្រោយកម្ទេច គេទុកជាខ្មាំង ។ ដូច្នេះ ប្រពន្ធរបស់ខ្មាំង កូនរបស់ខ្មាំងត្រូវចាត់ទុកជាខ្មាំង ។ នេះជារឿងពិត ។ សូមជម្រាបប្រសាសន៍ប៉ុណ្ណេះ ។

**ស៖** យើងពិនិត្យឃើញជាទូទៅនូវការចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរស-២១ ត្រូវឆ្លងកាត់នូវដំណាក់កាលជាច្រើន ដូចជាការដំណាក់កាលនៃការឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម រួចនាំយកទៅរហូតដល់ពេលស្លាប់ ឬក៏រហូតដល់ពេលនាំទៅកម្ទេច ។ សំណួរសួរថាតើមានករណីផ្សេង ដោយឡែកពីនេះទេ បានន័យថា មនុស្សដែលចាប់បញ្ជូនមកដល់ស-២១ ហើយមិនចាំឆ្លងកាត់ដំណាក់កាលនេះៗទេ មកដល់

ភ្លាម ហើយមានការចាប់បញ្ជូនទៅកម្ទេចភ្លាមតែម្តង ដោយមិនឆ្លងកាត់ការសួរចម្លើយ ការទារុណកម្ម ឬក៏ការឃុំឃាំង តើមានករណីដូច្នេះដែរឬទេ?

**ឌុ៖** ជម្រាបប្រសាសន៍លោកប្រធាន! មានៗ បញ្ជីដែលខ្ញុំបាទរាយការណ៍ជូនលោកប្រធានអំមិញហ្នឹង បញ្ជីលេខ D159/4.10 គ្នាមកបានតែដប់ថ្ងៃទេនៅស-២១ ។ ដប់ថ្ងៃនេះ គ្រាន់តែដើម្បីមិត្តហ៊ី គេរៀបចំបញ្ជីមួយរយ ហើយនិងបញ្ជូនចេញទេ តែអចិន្ត្រៃយ៍គេសម្រេចឲ្យកម្ទេច មកដល់ភ្លាមឲ្យកម្ទេចភ្លាម ហើយដោយមិនបាច់សួរ ។ ហើយកន្លងមក ខ្ញុំបានរាយការណ៍ជូនហូរហែមកដែលខ្ញុំនៅចាំ គឺពួកបូព៌ាចុងក្រោយហ្នឹងប្រហែលជាបីរយនាក់ អត់មានបានសួរចម្លើយទេ មកដល់កម្ទេចៗ ពូនួនគាត់អ្នកបញ្ជាមកអ៊ីចឹង ។ នេះជារឿងពិត ដូច្នេះ វាមានអ្នកមកដល់ភ្លាមមិនបាច់សួរ យកទៅកម្ទេច ។ នេះករណីមកទាំងឈុតៗ ។ ឯចំណែកករណីមកតិចតួចៗជាប្រចាំហ្នឹង ជួនអីក៏យើងខ្ញុំឃើញមិនសំខាន់ មិនមានសារសំខាន់ ក៏សម្រេចឲ្យគេបញ្ជូនទៅកម្ទេច ។ នេះជាសភាពការណ៍ដែលមានឡើងនៅស-២១ អំពីបញ្ជាមកដល់កម្ទេច ។ នេះសូមរាយការណ៍ជូនប៉ុណ្ណេះ ។

**ស៖** តាមទំនងមនុស្សដែលត្រូវចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរស-២១ ដែលបច្ចុប្បន្នយើងហៅថាគុកទួលស្លែងនេះ មានស្ទើរតែរាល់ថ្ងៃ ពិតមែនដែរទេ?

**ឌុ៖** មិនៗជារាល់ថ្ងៃពេកទេ មានរយាលចន្លោះ ក៏ប៉ុន្តែ មិនដឹងជាប្រមាណយ៉ាងម៉េចទេ អានេះសូមជូនទុកឲ្យបញ្ជីវាជាអ្នករាយការណ៍ជូនអង្គប្រជុំចោះ ខ្ញុំមិនចាំទេ ។

[១១:១៧:០៩]

**ស៖** ករណីការបញ្ជូនមនុស្សត្រូវបានចាប់ខ្លួន បញ្ជូនមកដល់មន្ទីរស-២១ ដោយអង្គភាពសាមីរបស់គេ ដែលករណីនេះកើតឡើងភាគនៅក្នុងចំណោមមនុស្សដែលបានមកដល់មន្ទីរស-២១ ។ តើមន្ទីរស-២១ ត្រូវចាត់ចែងក្នុងការប្រគល់ទទួល មុននឹងចាប់បញ្ចូលទៅក្នុងអគារ ឬបន្ទប់ឃុំឃាំងយ៉ាងដូចម្តេចដែរ?

**ឌុ៖** ជម្រាបប្រសាសន៍លោកប្រធាន! មនុស្សដែលដឹកមកពីក្រៅ គេមកចូលទៅស-២១ តាមផ្លូវលេខ ៣៦០ ទៅដល់មានកន្លែងមួយ ជាកន្លែងសម្រាប់ទទួល ដែលនៅក្នុងផែនទី ខ្ញុំបានគូរជូនលោកចៅក្រមស៊ើបអង្កេតនោះ គឺខ្ញុំដាក់អក្សរ R, R ហ្នឹងកន្លែងទទួល ដែលឥឡូវនេះ តាមក្មេងៗវានិយាយនៅពេលទៅតទល់គ្នាហ្នឹង គេថាស្ថានីយវិទ្យុសម្បុកឃ្មុំ ទទួលត្រង់នុ៎ង ។ ទទួលត្រង់នុ៎ងធម្មតាវាតែងមានមិត្តហ៊ុយ នៅនុ៎ង ជាប្រចាំ ឬក៏មិត្តប៉េង ប៉ុន្តែជាក់ស្តែងមិត្តហ៊ុយ ប៉ុន្តែអាចមានមិត្តហ៊ី នៅត្រួតពិនិត្យ

ដែរនៅពេលមកដល់ ។ មើលសព្វមើលគ្រប់ ផ្ទៀងឈ្មោះ ផ្ទៀងអីមកសព្វគ្រប់ បានៗគេបញ្ជូនទៅឲ្យខាងក្នុងគេទទួលខាង មិត្តប៉េង ថតអីមុនមិនដឹង ចូលទៅដល់សិនសឹមថតក៏មិនដឹងទេ ខ្ញុំមិនច្បាស់ទេ ។ ក៏ប៉ុន្តែ កន្លែងទទួលដំបូង គឺត្រង់ដែលខ្ញុំសរសេរអក្សរ R ហ្នឹងឯង ។ នេះសូមបញ្ជាប់ជូនប៉ុណ្ណឹង ។

**ស៖** ចុះកម្លាំងដែលការផ្ទេរផ្ទេរគ្នាហ្នឹង ផ្ទេរផ្ទេរត្រឹមហ្នឹង តើកម្លាំងបន្តពីចំណុចR គឺតាមផ្លូវលេខ៣៦០ ហ្នឹង ចូលទៅដល់កន្លែងទៅក្នុងមន្ទីរឃុំឃាំងហ្នឹង កម្លាំងខាងណាទៅដែលជាអ្នកប្រតិបត្តិការក្នុងការនាំមនុស្សយកទៅខាងក្នុង?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធានកម្លាំងដែលនាំពី R ទៅដល់ចូលទៅខាងក្នុង គឺពួកកងពិសេស ។ សូមបញ្ជាក់កម្លាំងយោធាដែលមានសមត្ថកិច្ចខាងកាន់អាវុធ ខាងអន្តរាគមន៍ហ្នឹងមានពីរប្រភេទ ។ ទីមួយកងពិសេស ទីពីរ កងការពារមន្ទីរឃុំឃាំងហ្នឹង កុំអ្នកទោសរត់រួច ។ ដូច្នេះ ពីរប្រភេទហ្នឹងខុសគ្នា ។ សរុបមក អ្នកដែលបញ្ជូនពី R ទៅដល់គុក ទៅដល់កន្លែងចុះឈ្មោះ គឺពួកកងពិសេស ។ សូមបញ្ជាក់ប៉ុណ្ណេះ ។

[១១:២០:០០]

**ស៖** ពេលបញ្ជូនចូលទៅដល់ភ្លាមហ្នឹង តើប្រតិបត្តិការហ្នឹង ធ្វើយ៉ាងដូចម្តេចមុនគេ ហើយនឹងលំដាប់លំដោយមុននឹងបញ្ជូនបែងចែកទៅដាក់ឃុំឃាំងនៅក្នុងបន្ទប់ឃុំឃាំងរួម ឬក៏ដោយឡែកនោះ? តើមាននីតិវិធី ឬក៏របៀបធ្វើយ៉ាងម៉េចទេ ត្រង់ពេលដែលចូលដល់មន្ទីរហើយនោះ មុននឹងបញ្ជូនទៅមនុស្សនោះចេញទៅបន្ទប់ឃុំឃាំង?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ កន្លែងនេះខ្ញុំមិនល្អិតទេ មិនដឹងជាយកទៅដល់កន្លែងឃុំឃាំងសិន សឹមយកមកថតក្រោយ ឬក៏ថតមុនចូល ។ ដូច្នេះ អ្នកច្បាស់លាស់ជាងគេ គឺអ្នកកាន់បញ្ជីមកដល់គេនឹងរាយការណ៍ជូនអង្គជំនុំជម្រះហើយ គឺមិត្តធី សួស ធី ហ្នឹង ។ ហើយមិត្តហ៊ុយ ក៏អាចច្បាស់ដែរ ។ ដូច្នេះ គេច្បាស់ជាងខ្ញុំ ដូច្នេះ ខ្ញុំសូមជម្រាបបញ្ជាក់ប៉ុណ្ណឹង ដល់ទៅដល់កិច្ចប្រតិបត្តិការល្អិត ខ្ញុំមិនច្បាស់ជាក់ស្តែងទេ ។ សូមជម្រាបឆ្លើយដោយត្រង់ ។

**ស៖** បានជាយើងផ្ទៀងផ្ទាត់ចំណុចនេះ ដោយសារហេតុផលនៃបទរូបថតនៃជនរងគ្រោះទាំងឡាយដែលបានបន្សល់ទុកនៅៗក្នុងគុកទួលស្លែងបច្ចុប្បន្នហ្នឹង គឺមានទីមួយមិនមានការរុំមុខទេ ជាទូទៅ។ ទីពីរ គឺមានពាក់ផ្លាក់លេខផ្សេងៗ ហើយនៅក្នុងនីតិវិធីដែលយើងសួរនេះ គឺក្នុងគោលបំណងបញ្ជាក់លើនីតិវិធីនៃការចូលមកដល់នៃដំណើរការ។ហើយអរគុណដែលលោកបានឆ្លើយជូនដល់អង្គសវនាការ

ដូច្នេះ។

នៅពេលចូលខ្លួនមកដល់មន្ទីរស-២១ តើពួកគេ អ្នកដែលត្រូវចាប់ខ្លួនបញ្ជូនមកដល់ទាំងនោះ គេស្លៀកពាក់សម្លៀកបំពាក់ធម្មតាដែរឬទេ ឬក៏ត្រូវស្រាតសម្លៀកបំពាក់ផ្លាស់ចេញ? ដូចជា ស្រាតខោវែង ឬក៏ដោះអាវចេញទុកតែខោខ្លី ឬក៏ខោទ្រនាប់ជាដើម ។ ដោយហេតុថា នៅក្នុងកំណត់ហេតុ និងរូបភាពនៅមន្ទីរស-២១ គឺមានគំនរសម្លៀកបំពាក់ជាច្រើន ដែលមានបញ្ហាត្រូវផ្ទៀងផ្ទាត់អំពីព្រឹត្តិការណ៍នេះ ។

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ថ្វីត្បិតតែបញ្ហានេះ ខ្ញុំមិនជាក់ស្តែង ក៏ប៉ុន្តែខ្ញុំទទួលស្គាល់ថា លទ្ធភាពស្ទើរតែពិតទាំងស្រុងថា មកដល់គេដកខោអាវវែងៗ ក្រៅៗចេញ អំពីអ្នកទោសប្រុស ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១១:២៣:០៦]

**ស៖** អំពីការឃុំឃាំងវិញ ឬក៏យើងប្រើពាក្យនៅក្នុងឯកសារជាច្រើន គេប្រើពាក្យដាក់គុក ។ លោក កាំង ហ្គេកអ៊ាវ តើលោកអាចនិយាយប្រាប់ដល់អង្គសវនាការបានដែរឬទេ អំពីទិដ្ឋភាពទូទៅនៃការឃុំឃាំងមនុស្សក្នុងមន្ទីរស-២១? ដូចជាស្ថានភាពទីកន្លែង ដូចជាអគារបន្ទប់ឃុំឃាំង ការដាក់ខ្នោះ ឬក៏ដាក់ច្រវាក់ ឬក៏ឧបករណ៍ផ្សេងៗទៀតជាដើម ប្រសិនបើមាន ។

**ឆ៖** សូមអរគុណលោកប្រធាន ហើយសូមជម្រាបប្រសាសន៍លោកប្រធានបញ្ជាក់ថាគុករបស់មន្ទីរស-២១ មិនមែនជាគុក ដូចគុករបស់ប្រទេសនីតិរដ្ឋផ្សេងទេ ។ សូម្បីតែគុកនៅកម្ពុជាដែលខ្ញុំទៅជាប់ គុកធំភ្នំពេញ គេមានក្រុម១២ សម្រាប់ការពារសិទ្ធិអ្នកទោសនយោបាយ ។ ឯចំណែក គុករបស់មន្ទីរស-២១ ខ្ញុំយល់ស្របតាមសម្តីដែលគេសរសេរនៅក្នុងសៀវភៅបទ របស់ ដេវីដ ឆេនដ័ល័រ ។ គាត់ហៅអាហ្នឹងថា កន្លែងទុកមនុស្សមុននឹងយកទៅប្រហារជីវិត ។ ដូច្នេះ គេទុកគ្រាន់តែសម្រាប់សួរ ហើយន្ទាលនឹងគេប្រហារ ដូច្នេះអត់មានស្អីការពារសិទ្ធិគេទេ ។ ទុក្ខលំបាកវេទនាទាំងប៉ុន្មាន វាហូរហែសព្វបែបសព្វយ៉ាង ។ សម្តីដែលប្រើក៏ដូចជាសម្តីជាមួយខ្មាំង ដែលមានតម្លៃស្មើនឹងសម្តីសត្វ ។ ការហូបចុក ការថែទាំសុខភាពអីទាំងអស់វាទៅទាំងព្រម ។ មានន័យថា យើងខ្ញុំទុកគេជាមនុស្សស្លាប់រួចទៅហើយ ឆ្លងពេលសម្រាប់តែយកទៅសម្លាប់ប៉ុននុ៎ង ។ នេះខ្ញុំសូមបញ្ជាក់អំពីឧក្រិដ្ឋកម្មដែលមាននៅស-២១ ដោយឡែក ហើយក៏ជឿជាក់ថា ប្រហែលជាទូទាំងប្រទេសផងមិនដឹង ។ នេះ គឺខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះដោយស្មោះ សូមចប់ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមសួរទៅខាងសហព្រះរាជអាជ្ញា តើជំនួយការរបស់លោកអាចបញ្ចាំងនូវខ្សែវីដេអូ V00172621 បានដែរឬទេ?

**លោក វីលៀម ស្មីត៖**

គឺយើងអាចធ្វើបាននៅពេលនេះ លោកចៅក្រម ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍សូមភ្ជាប់នូវប្រព័ន្ធសោតទស្សន៍មកប្រព័ន្ធកុំព្យូទ័ររបស់ខាងផ្នែកសហព្រះរាជអាជ្ញា ។

[១១:២៦:៥១]

**លោក វីលៀម ស្មីត៖**

លោកចៅក្រម ប្រសិនបើយើងមានលេខERN ឡើងវិញ ហើយខ្ញុំសូមលើកឡើងដោយពិពណ៌នាដោយសង្ខេប ថាតើយើងត្រូវការសំឡេងរូបភាពនេះដែរឬទេ? ប្រសិនយើងត្រូវការ គឺអាចបញ្ចាំងសំឡេងចេញពីខាងកុំព្យូទ័ររបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

យើងមិនចង់បានសំឡេងទេ យើងចង់បានរូបភាព ហើយលេខនេះ គឺមានអត្ថាធិប្បាយនូវវីដេអូឈ្មោះបញ្ជីឌីវីឌី ដែលរៀបចំដោយសហព្រះរាជអាជ្ញា លេខមួយ ដែលអត្ថាធិប្បាយអំពីឧបករណ៍ធ្វើទារុណកម្ម និងរូបភាពផ្សេងៗ នៅក្នុងនោះគឺ មាន V00172621 ។ ឯកសារនេះយើងបានបញ្ចាំងម្តងហើយនៅកាលពីដំណើរការនៃការបង្កើតមន្ទីរស-២១ ។ ដោយសារឯកសារនេះ យើងចង់យកតែរូបភាពដែលមានការពាក់ព័ន្ធជាមួយបន្ទប់ឃុំឃាំង កន្លែងទទួលមនុស្ស ហើយនិងបន្ទប់ឃុំឃាំងតែប៉ុណ្ណោះ។

**លោក វីលៀម ស្មីត៖**

គឺយើងមានរូបវីដេអូនៅក្នុងអេក្រង់របស់យើងហើយ ដូច្នេះ សូមឲ្យផ្នែកសោតទស្សន៍ធ្វើការភ្ជាប់មកកាន់របស់ខាងសហព្រះរាជអាជ្ញា ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ភ្ជាប់នូវប្រព័ន្ធរូបភាពមកកុំព្យូទ័ររបស់ខាងសហព្រះរាជអាជ្ញា ។

មិនមែនឯកសារនេះទេ ។ ឯកសារបញ្ចាំងពីអគារនិងបន្ទប់ឃុំឃាំង ។

**លោក វីលៀម ស្មីត៖**

សូមអរគុណ គឺរូបភាពត្រង់នោះ គឺចេញពីខ្សែរូបភាពវីដេអូវៀតណាមនេះ ហើយដូច្នេះហើយ គឺយើងស្វែង នឹងត្រូវការពេលវេលាបន្តិច ដើម្បីធ្វើការរកកន្លែងដែលលោកចង់ លោកចៅក្រមចង់បាន នោះ ។

**ប្រធានអង្គជំនុំ៖**

បើរកមិនឃើញទេ សូមជួយរកសិនទៅ ដើម្បីនេះ ហើយអង្គជំនុំជម្រះបន្តនូវសំណួរពាក់ព័ន្ធ ជាមួយនឹងអង្គហេតុនៃការឃុំឃាំងនេះបន្តទៀត ។

**ស៖** ជាទូទៅ ការឃុំឃាំងមនុស្សប្រព្រឹត្តទៅចាប់តាំងពីពេលចាប់បញ្ចូលមកដល់មន្ទីរស-២១ រហូតពេលស្លាប់ ឬក៏ដល់ពេលនាំយកទៅកម្ទេច ដោយមិនដែលបានដោះលែងសោះ ។ តើពិតដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពិត ។

**ស៖** ជាទូទៅ តើការឃុំខ្លួនមនុស្ស?

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ ឥឡូវនេះ យើងរកឃើញចំណុចដែលលោក ជាខ្សែភាពយន្ត លោកចៅក្រមចង់បានហើយ ខ្ញុំចង់ធ្វើការបញ្ចាំងនៅពេលនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ សូមភ្ជាប់ប្រព័ន្ធជាមួយនឹងកុំព្យូទ័ររបស់ខាងសហព្រះរាជអាជ្ញា ។

*(ដំណើរការបញ្ចាំងវីដេអូ)*

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍សូមផ្តាច់ប្រព័ន្ធ ហើយមកប្រក្រតីភាពវិញ ។ រូបភាពទាំងនេះ នឹងអាចមាន ការពាក់ព័ន្ធនឹងសំណួរមួយចំនួន ដែលយើងនឹងសួរបញ្ជាក់នៅពេលបន្តបន្ទាប់នេះ ។

ជាទូទៅ តើការឃុំឃាំងមនុស្សត្រូវតែដាក់នៅក្នុងបន្ទប់ឃុំឃាំងតូចៗ ឬក៏បន្ទប់ឃុំឃាំងរួម ដោយចាក់សោរទ្វាពីក្រៅមួយជាន់ទៀត និងសុទ្ធតែត្រូវដាក់ខ្នោះជើងជាអចិន្ត្រៃយ៍ចំពោះបុរស លើក លែងតែមនុស្សចំនួនដែលរស់រានមានជីវិត ទុកឲ្យរស់រានមានជីវិត ប៉ុន្មាននាក់ ដោយសារមូលហេតុ ពន្យារកម្ទេច ដោយសារត្រូវប្រើប្រាស់ៗពួកគេ ។ ពិតមែនដែរឬទេ? ឬក៏មានតែនៅពេលនាំយកទៅ សួរចម្លើយតែប៉ុណ្ណោះ?

[១១:៣៥:00]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ការឃុំឃាំងនៅក្នុងមន្ទីរស-២១ ដាក់ខ្នោះជើងទាំងពីរ ឬក៏ដាក់ខ្នោះជើងតែមួយ ខ្ញុំផ្ទាល់ខ្លួន ខ្ញុំមិនច្បាស់ទេ ។ ក៏ប៉ុន្តែ ពិតជាដាក់ខ្នោះជើងម្ភៃបួនម៉ោងលើម្ភៃបួនម៉ោងជាប់ជាប្រចាំ លើកលែងតែពេលយកទៅសួរចម្លើយ នៅពេលបណ្តើរប៉ុណ្ណឹងឯង ។ ទៅដល់កន្លែងសួរចម្លើយដាក់ខ្នោះជើងមួយសាទៀត នៅនឹងតុ នៅនឹងកៅអីសួរចម្លើយហ្នឹង ។ នេះជារឿងពិត ខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** ចុះនៅពេលដែលជនរងគ្រោះ ឬក៏ជនជាប់ឃុំឃាំងមានជម្ងឺ តើត្រូវធ្វើដូចម្តេច? តើមានការដោះលែង ដើម្បីទទួលការការព្យាបាលដែរឬទេ?

**ឆ៖** បើតាមខ្ញុំចាំ ការព្យាបាលធ្វើឡើងគ្រាន់តែសម្រាប់ពន្យារពេល ដើម្បីសួរចម្លើយតែប៉ុណ្ណោះឯង នេះវត្ថុបំណង ។ ជាគោលការណ៍នៃការឃុំឃាំងនៅពេលនោះ គឺអ៊ីចឹង ។ នេះសូមជម្រាបដោយស្មោះ ។

**ស៖** អ៊ីចឹងបានន័យថា លក្ខខណ្ឌនៃការដាក់ខ្នោះម្ភៃបួនម៉ោងលើម្ភៃបួនម៉ោងនៅដដែល ។ ការព្យាបាលបានន័យថា ទៅព្យាបាលផ្ទាល់ ដល់ទីកន្លែង ដែលគាត់កំពុងតែជាប់ខ្នោះហ្នឹងតែម្តង ក្នុងករណីគាត់ឈឺ ឬគាត់មានរបួសនោះ អ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះខ្ញុំអត់ប្រកែកទេ ទោះបានឃើញ ឬមិនបានឃើញ វាពិតជាឧក្រិដ្ឋកម្មហ្នឹង វាធ្ងន់ដល់ប៉ុនន្ទុំង ពិតជាប្រាកដ ខ្ញុំទទួលអត់ប្រកែក ។

**ស៖** ចុះនៅពេលត្រូវហូបអាហារ ឬត្រូវបន្ទោបង់ជាដើម តើស្ថានភាពជាប់ខ្នោះដដែលហ្នឹង គឺនៅតែស្ថិតនៅក្នុងស្ថានភាព ដូចដែលលោកបាននិយាយថា ម្ភៃបួនម៉ោងលើម្ភៃបួនម៉ោងដូច្នេះមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! បញ្ហានេះ ក៏ពិតជាអ៊ីចឹង ឧក្រិដ្ឋកម្មហ្នឹង វាអ៊ីចឹង វាច្បាស់អ៊ីចឹង ។

[១១:៣៧:៤៤]

**ស៖** ជាទូទៅ អ្នកជាប់ឃុំឃាំងក្នុងស្ថានភាពដូចខាងលើនេះ ប្រសិនបើពួកគេស្រេកទឹក គេត្រូវការផឹកទឹក ។ តើគេត្រូវធ្វើដូចម្តេច?

**ឆ៖** បើតាមការវិភាគ ខ្ញុំយល់ទេ ខ្ញុំអត់បានទៅមើលឃើញទេ គឺស្រែកទារឲ្យអ្នកយាមនៅប្រចាំក្នុងបន្ទប់ហ្នឹង គេយកទឹកឲ្យ ។

**ស៖** ជាទូទៅ អ្នកជាប់ឃុំឃាំងក្នុងស្ថានភាពដូចដែលលោកបាននិយាយថា ត្រូវជាប់ខ្នោះជើង ២៤ម៉ោង លើ២៤ម៉ោង តើពួកគេដែលបានងូតទឹកដែរឬទេ? ហើយបើគេងូតទឹក តើរបៀបងូតទឹកហ្នឹង ប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំអត់បានទៅឃើញបញ្ហាហ្នឹងទេ ប៉ុន្តែនៅក្នុងពេលតទល់ពីសម័យ ពីជំនាន់នោះមក អង្កាល់ពីខែកុម្ភៈ ២០០៨ ធ្វើឲ្យខ្ញុំដឹងរឿងនេះ ច្បាស់មែនទែន គឺអត់មានអ្នកណាដោះខ្នោះជាងឲ្យទៅមុតទឹកទេ ។ កងការពារបាញ់ទុយយោពីក្រៅទៅ ជាការលាងបន្ទប់ផង ហើយឲ្យអ្នកទោសមានទឹកសើមនៅនឹងខ្លួនបន្តិចផង ។ បើតាមខ្ញុំយល់ ដូចអត់មានពេលដុសក្អែល ដុសអីផងហ្នឹង ។ ដូច្នេះ វាជារូបភាព វាជារូបភាពឧក្រិដ្ឋមួយដែលយើងខ្ញុំអត់ប្រកែកទេ ទទួល ។ រឿងនេះពិត ។

**ស៖** អ៊ីចឹងបានន័យថា នៅពេលពួកគេងូតទឹកដោយការបាញ់បញ្ចូលទឹកដោយទុយយោ ។ ចុះសម្លៀកបំពាក់របស់គេមានការផ្លាស់ប្ដូរដែរ ឬទេ? បើមានការផ្លាស់ប្ដូរៗយ៉ាងដូចម្ដេចដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះ ខ្ញុំជម្រាបដោយឈរលើការវិភាគ និងសន្និដ្ឋានទេ ប្រហែលជាគ្នានៅខោខ្លីទាំងសើម ទាំងស្ងួត ។ សើមក៏នៅនឹងខ្លួន ស្ងួតក៏នៅនឹងខ្លួនដែរ ។ ប្រហែលជាអ៊ីចឹង ។ នេះខ្ញុំសូមវិភាគ អត់បានឃើញទេ ប៉ុន្តែ សូមវិភាគជូនអ៊ីចឹង ។ អត់មាននរណា យកចិត្តទុកដាក់អំពីសុខមាលភាពអីរបស់អ្នកទោសទេ ។ សូមរាយការណ៍ជូនប៉ុណ្ណេះ ។

**ស៖** យើងអាចនិយាយបានទេថា បើមានលក្ខខណ្ឌដូច្នេះមែនហ្នឹង បានន័យថា គោលបំណងនៃការបាញ់ទឹកបញ្ចូលទៅក្នុងបន្ទប់ ដើម្បីសម្អាតបន្ទប់ជាជាងសម្អាតខ្លួនប្រាណអ្នកជាប់ឃុំឃាំង ។ ជាការពិតដែរឬទេ បើស្ថានភាពដូចលោកបាននិយាយយ៉ាងនេះ?

**ឆ៖** សេចក្ដីសន្និដ្ឋានបែបនេះ ពិត ។ សូមបញ្ជាក់ថា ពិត ។

**ស៖** អរគុណ ។ ចុះការដាក់ខ្នោះយ៉ាងដូចម្ដេច ចំពោះអ្នកដែលជាប់ឃុំឃាំងក្នុងបន្ទប់ឃុំឃាំងរួម? ហើយការដាក់ខ្នោះ ធ្វើឡើងអំពីដែក ឬច្រវាក់ជាស្ទួរ មួយស្ទួរៗមានមនុស្សច្រើននាក់ ឬក៏ដាក់ខ្នោះជើង ឬក៏ដាក់ខ្នោះច្រវាក់ដោយឡែកៗពីគ្នា? នេះយើងនិយាយអំពីបន្ទប់ឃុំឃាំងរួមសិន។ ស្ថានភាព និងទិដ្ឋភាពនៃការដាក់ខ្នោះហ្នឹងយ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ស្ថានភាពនៃការដាក់ខ្នោះនៅក្នុងបន្ទប់ឃុំឃាំងរួមនេះ ដាក់ខ្នោះជាចង្កាក់គ្នាពីមួយទៅមួយ ដេកទន្ទឹមគ្នាចាក់ធាង ហើយដាក់ខ្នោះជើង ។

**ស៖** ខ្នោះជើងមានតែមួយប្រភេទទេ គឺខ្នោះជើងធ្វើអំពីដែក ឬក៏មានការដាក់ជាប្រភេទច្រវាក់ ដាក់ជាប្រភេទច្រវាក់ ដាក់ជើងជាប់ៗគ្នាដែរ?

**ឆ៖** រឿងច្រវាក់ខ្ញុំមិនច្បាស់ទេ ។ ប៉ុន្តែ បើតាមចាំ ដូចជាមិនប្រើ មិនដឹងយ៉ាងម៉េចទេ-- សូមទោស ខ្ញុំមិនប៊ានសន្និដ្ឋានទេ ប៉ុន្តែ ខ្ញុំជឿខ្នោះជើងច្រើនជាង ។

**ស៖** តាមស្ថានភាពដែលលោកបានបង្ហាញខាងលើនេះ ជាទូទៅ តើពួកគេត្រូវបន្ទោបង់យ៉ាងដូចម្ដេចទៅ? បើគេជាប់ខ្នោះម្ភៃបួនម៉ោងលើម្ភៃបួនម៉ោងនោះ ។ តើមានការដោះលែងដើម្បីឲ្យគាត់បន្ទោរបង់ទេ ឬក៏គាត់បន្ទោបង់នៅទីកន្លែង ដែលគាត់ត្រូវជាប់ខ្នោះនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ការបន្ទោបង់ គឺនៅនឹងកន្លែងដែលគាត់សម្រាក ដែលគាត់ដេក ដែលគាត់រស់នៅ ។ បើកាលណាបន្ទោបង់លាមក ប្រហែលជាប្រើធុងគ្រាប់ អឹមសី ហើយបន្ទោបង់ទឹកនោម គឺត្រូវប្រើប៊ីដុងតូចៗ នេះគឺខ្ញុំសូមជម្រាបបញ្ជាក់បែបនេះ ។

**ស៖** យើងគិតមើលថា ជាទូទៅអ្នកជាប់ឃុំឃាំងក្នុងស្ថានភាពដូចដែលលោកបាននិយាយដូច្នេះ ប្រសិនបើនៅពេលមានមនុស្សណាស្លាប់នៅក្នុងចំណោម លោកប្រើពាក្យចង្កាក់អំមិញ គឺមួយខ្សែៗ ដែលមានជាប់មនុស្សច្រើននេះស្លាប់ តើបុគ្គលិកស-២១ ចាត់ចែងយ៉ាងដូចម្ដេច? ពិសេសមានមនុស្សស្លាប់នៅពេលយប់ ដែលនៅជាប់ខ្នោះក្នុងស្នួរជាមួយគ្នា តើចាត់ការយ៉ាងដូចម្ដេចដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ដោយខ្ញុំមិនបានជាប់នឹងដាក់ស្ដែងលើបញ្ហានេះ ហើយក៏មិនដែលបានដេញសួរគេអំពីបញ្ហានេះទេ មិនយកចិត្តទុកដាក់ នេះមកពីមិនយកចិត្តទុកដាក់ ។ ទោសកំហុសនៃការមិនយកចិត្តទុកនេះ វាជាឧក្រិដ្ឋកម្មមួយទៅហើយ ។ ក៏ប៉ុន្តែ បើតាមខ្ញុំសន្និដ្ឋាន កាលណាបើសម្លាប់ពេលយប់នៅក្នុងចង្កាក់នេះ គេអត់ធ្វើអីទេ ទាល់តែព្រឹកឡើងភ្លឺបានគេធ្វើ ភ្លឺច្បាស់ ដល់ពេលភ្លឺបានគេធ្វើ គេដោះ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១១:៤៥:២២]

**ស៖** ចុះអ្នកជាប់ឃុំនៅក្នុងបន្ទប់តូចៗ តើពួកគេមានដែលបានងូតទឹកដែរឬទេ? បើបានងូតទឹកពួកគេងូតទឹកយ៉ាងដូចម្ដេចដែរ? គឺនិយាយបន្ទប់តូចៗ គឺម្នាក់ៗ ដែលយើងឃើញនោះ ឃើញថាមានបន្ទប់ធំ និងបន្ទប់តូច ។ បន្ទប់ឃុំឃាំងរួម និងបន្ទប់តូច ។ តើមានការងូតទឹកដែរឬទេ? ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំអត់បានទៅជាប់ដាក់ស្ដែងទេ ។ ប៉ុន្តែ បើតាមការវិភាគស្រួលមិនស្រួលអត់ងូតទឹកទេ ឬក៏មួយអាទិត្យ មួយខែអីងូតម្ដង អាហ្នឹងមែន ។

**ស៖** អរគុណ ។ ក្នុងស្ថានភាពអ្នកជាប់ឃុំឃាំងដែលត្រូវបានដាក់ខ្នោះជើងមួយ ឬក៏ជើងទាំងពីរដូច្នេះ តើពួកគេអាចក្រោកឈរបានដែរឬទេ?

**ឆ៖** ក្រោកឈរបានក្នុងខណៈដែលកងការពារ គេនៅយាមហ្នឹង គេអនុញ្ញាត ទាល់តែសុំគេសិន បើមិនសុំគេ ឈរមិនបានទេ ។ អានេះសូមជម្រាបបញ្ជាក់ប៉ុណ្ណេះ ។ សូមបញ្ចប់ ។

**ស៖** ក្នុងអំឡុងពេលនៃការជាប់ឃុំឃាំង ជនជាប់ឃុំឃាំងទូទៅ អំមិញលោកបាននិយាយហើយម្ភៃបួនម៉ោងលើម្ភៃបួនម៉ោងប៉ុន្តែយើងចង់បញ្ជាក់ថា តើមានគោលការណ៍ ឬក៏មានការបញ្ចេញពួកគាត់ឲ្យមកក្រៅ ដើម្បីមកធ្វើលំហាត់ប្រាណ ឬក៏សំដិលនៅពន្លឺថ្ងៃដែរ ឬទេ?

**ឆ៖** បើតាមខ្ញុំយល់ ខ្ញុំជឿថា អត់ៗមានទាល់តែសោះ ។ លើកលែងតែពួកអ្នកដែលចេញមកធ្វើការងារ បម្រើពន្ធនាគារ ដែលបានចេញ ក្រៅពីនោះអត់ ។

**ស៖** បន្ទប់ឃុំឃាំងស្ត្រីត្រូវបានដាក់ដោយឡែកពីបុរស តើពិតមែនដែរឬទេ? តើស្ត្រីត្រូវបានគេដាក់ខ្នោះ ឬក៏ច្រវាក់ដូចបុរសដែរឬទេ? គាត់មានងូតទឹក ឬក៏មានការផ្លាស់ប្តូរសម្លៀកបំពាក់ដែរឬទេ?

**ឆ៖** រឿងនេះ អង្កាល់ដែលខ្ញុំនៅធ្វើជាប្រធានស-២១ ខ្ញុំអត់បានដិតដល់ គិតគូរទេ។ ប៉ុន្តែ តាមឯកសារដែលនៅសល់ ហើយនិងសម្តីខ្លះនៅពេលឆ្លងឆ្លើយគ្នានៅជើងឯក ខ្ញុំជឿថា ស្រីដាក់ដោយឡែកពីបុរស ។ ស្រីមិនត្រូវបានជាប់ខ្នោះទេ ហើយត្រូវបានចេញធ្វើការងារផងពេលខ្លះ ។ នេះខ្ញុំសូមជម្រាបប៉ុណ្ណេះ ។

**ស៖** តើគាត់មានការផ្លាស់ប្តូរសម្លៀកបំពាក់ទេ? បានន័យថា សម្លៀកបំពាក់របស់គាត់ ត្រូវទុកលទ្ធភាពឲ្យគាត់មានការផ្លាស់ប្តូរដែរឬទេ? ឬក៏មានសម្រាប់តែមួយសម្រាប់ គឺដូចបុរសដែរ បានន័យថាបុរសមានតែខោខ្លីស្លៀក ដោះខោវែងចេញ ប៉ុន្តែ ស្ត្រីយើងគឺយើងអត់ធ្វើអីចឹងទេ គ្រាន់តែមានមួយបន្លាស់ ។ គឺមានន័យថា មានតែមួយសម្រាប់ សម្រាប់ពាក់ហ្នឹងជារាងរហូតទៅ ឬក៏មានសម្លៀកបំពាក់ត្រូវផ្លាស់ប្តូរបានដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! បញ្ហានេះ ខ្ញុំនិយាយតាមវិភាគ និងសន្និដ្ឋានទៀតទើបទៅហើយ ។ តាមសន្និដ្ឋាន ប្រហែលជាមានសម្លៀកបំពាក់ពីរបន្លាស់ អាចផ្លាស់ប្តូរគ្នាបាន ។ ព្រោះគោលការណ៍នេះ ជម្រាបប្រសាសន៍ដោយត្រង់ ខ្ញុំអត់បានគិតគូរទេ បើការគិតគូរដល់ស្ត្រីភេទនេះ បើកម្រិតបែបនេះ វាជារឿងរបស់មិត្តហ៊ ទេ គេមានពិសោធរបស់គេ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ សូមបញ្ចប់ ។

**ស៖** នៅក្នុងអំឡុងពេលនៃការជាប់ឃុំឃាំងនៅទីនោះ ជនជាប់ឃុំឃាំងទាំងអស់ត្រូវស្ថិតក្រោមការឃាមកាមយ៉ាងតឹងតែងពីឆ្មាំគុកដែលមានអាវុធជាប្រចាំ ឆ្មាំគុកទាំងផ្នែកខាងក្នុង និងផ្នែកខាងក្រៅនៃមន្ទីរ ទទួលការណែនាំយ៉ាងតឹងរ៉ឹងអំពីថា ដើម្បីមិនឱ្យជនជាប់ឃុំទាំងនោះរត់គេចខ្លួនបាន ។ តើជាការពិតទេនូវបញ្ហានេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! នេះជាការពិត ។

**ស៖** អ្នកយាមខាងក្រៅ គឺសំដៅលើកងពិសេស អ៊ីចឹងមែនទេ? ហើយអ្នកយាមខាងក្នុងគឺសំដៅលើ លោកបាននិយាយថា ជាកងការពារ ដូច្នេះមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! អ្នកយាមនៅខាងក្រៅពិតជាកងពិសេសមែន ហើយអ្នកយាមនៅខាងក្នុង គឺសំដៅពួកកងការពារមែន ។

**ស៖** ចាប់តាំងពីពេលដែលបង្កើតមន្ទីរស-២១ តើអ្នកដែលចាប់ខ្លួនបញ្ជូនទៅក្នុងមន្ទីរស-២១ ហើយឃុំឃាំងហ្នឹង តើមានលទ្ធភាពណាអាចរត់គេចខ្លួនរួចចេញពីទីនោះបានដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ករណីរត់រួចមានតែម្តងគត់ទៅដល់អង្គភាព ម្ចាស់អង្គភាព គេចាប់បញ្ជូនមកស-២១ វិញ គឺអង្គភាពពួក១៧០ នេះម្តង ។ ក្រៅពីនោះមានរឿងឆក់កាំភ្លើងបានម្តង ហើយនិងលួចយកកាំភ្លើងបានម្តងបាញ់កងការពារ។ ទាំងអស់បីដង បាតុភាពដែលផ្តោះផ្តោយការផ្តោះ ផ្តោយមានបីដង ។ សូមបញ្ជាក់ជូនប៉ុណ្ណឹង ។ សូមចប់ ។

**ស៖** តាមស្ថានភាពដែលលោកបាននិយាយកន្លងមកនេះបង្ហាញឱ្យឃើញថា ជនជាប់ឃុំទាំងឡាយភាគច្រើនសុទ្ធតែត្រូវបានដេកផ្ទាល់នឹងឥដ្ឋ គ្មានកន្ទេល គ្មានមុង គ្មានខ្នើយ និងពេលបាញ់ទឹក ចូលម្តងៗត្រូវដេកលើឥដ្ឋទទឹកជាមួយនឹងខោខ្លីទទឹកជោក ដូច្នេះមែនទេ? នេះចំពោះបុរស ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងហ្នឹង ខ្ញុំសូមសន្និដ្ឋានពិត អ៊ីចឹងមួយរយភាគរយ ។

**ស៖** ចុះការឃុំឃាំងមនុស្សសំខាន់ៗមួយចំនួនដូចជា កុយ ធួន, វ៉ន វេត, កង ចាប ជាដើម តើបុគ្គលិកស-២១ អនុវត្តដូចគ្នានឹងករណីមនុស្សភាគច្រើនដែរឬទេ? ឬក៏មានការរបប ផ្តល់នូវគោលរបបផ្សេងៗដែលមានលក្ខណៈប្រសើរជាងករណីមនុស្សទូទៅដែលជាប់ឃុំនៅទីនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ចំពោះមនុស្សដែលស្ថិតនៅក្នុងគុកពិសេសនោះ មានការផ្តល់នូវលក្ខណៈសម្បត្តិឱ្យការរស់នៅស្រួលប្រសើរជាង ។ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំបានចូលទៅសួរចម្លើយ កុយ ធួន។ ខ្ញុំឃើញផ្ទាល់នឹងភ្នែក ។ រូបថតដែលនៅសល់នេះ បញ្ជាំងឱ្យឃើញ កុយ ធួន ជាប់ខ្នោះជើងភ្ជាប់

ទៅនឹងគ្រែផ្តៅមួយ ដែលគាត់សម្រាន្តនៅនុ៎ង នេះពិត ។ ហើយផ្ទះក៏ខ្ញុំនៅចាំដែរទាល់ឥឡូវ ។

ដូច្នេះសរុបមក អ្នកទោសពិសេសមានលក្ខណ:រស់នៅស្រួលសមរម្យ ហើយការនិយាយស្តីក៏អ្នកសួរគេគិតគូរច្រើនដែរ គេមិនហ្អែង អាមឹង ដាច់សាច់ទទឹងទទែងទេ ដូច្នេះមានការប្លែក ។ ហើយបើឈឺស្កាត់អី ក៏គេដោះស្រាយសមរម្យ ឧទាហរណ៍ដូច សួស សុផាន កាលដែលទៅជាប់ហ្នឹងអ្នកយាមប្រហែស សួស សុផាន ទៅរើសយកវីសមួយលេប ។ ដល់ក្រោយមក ស-២១ ដឹងថា អូ! លេបវីស ។ ខ្ញុំបញ្ជាឱ្យគេទៅ ទាក់ទងនឹងពេទ្យ៩៨ ដែលជាពេទ្យសេនាធិការហ្នឹងទៅអញ្ជើញពេទ្យវះកាត់ ឱ្យមកវះកាត់យកវីសហ្នឹងសិន ព្យាបាលជាហើយបានសួរតទៅទៀត។ ដូច្នេះ លក្ខណ:សម្បត្តិទាំងអស់ ដើម្បីបំរើការសួរចម្លើយឱ្យបានផល ។

សរុបមកវិញប៉ុណ្ណឹង ទោះបីអនុគ្រោះ ទោះបីមិនអនុគ្រោះធ្វើម៉េចបំរើការសួរចម្លើយឱ្យបានផល ។ នេះវាជារូបភាពមួយដែលនិយាយទៅវានៅតែដដែលទេ រឿងឧក្រិដ្ឋកម្មដែលយើងពិបាកហ្នឹងជឿ សតិអារម្មណ៍មនុស្សជំនាន់នេះពិបាកហ្នឹងជឿ ។ នេះខ្ញុំសូមជម្រាបបញ្ចាក់ដោយប៉ុណ្ណេះ ។ សូមចប់ ។

[១១:៥៥:១០]

**ស៖** លោកដែលពិនិត្យឃើញនូវទិដ្ឋភាពនៃខ្លួនប្រាណអ្នកជាប់ទោស អ្នកជាប់ឃុំឃាំងនៅក្នុងគុកនៃទួលស្លែងបច្ចុប្បន្នដែលយើងហៅក្នុងមន្ទីរស-២១ នៅសម័យនោះដែរ ឬទេ អំពីស្បែក សំបកស្បែករបស់គាត់ហ្នឹង តើមានស្ថានភាពយ៉ាងម៉េចទៅ? ដោយសារការបញ្ជាក់នេះ ពីព្រោះលោកបានឆ្លើយហើយមិញថា ការផ្គត់ផ្គង់នូវដូចជាកន្ទេល មុង ខ្នើយ គឺគ្មានទេ សូម្បីតែការបាញ់ទឹកដើម្បីសម្អាតបន្ទប់ហ្នឹងជាការសម្អាតខ្លួនប្រាណរបស់អ្នកជាប់ឃុំឃាំងផងនោះ គឺដេកទាំងទទឹក ទាំងឥដ្ឋទទឹក ទាំងខោទទឹក រហូតដល់ស្ងួតដោយឯងៗវិញ រហូតដល់មានការបាញ់លាងបន្ទប់ទឹក និងក៏ដូចជាការឱ្យអ្នកទាំងនោះបានងូតទឹកម្តងទៀត ។ នេះបញ្ជាក់ថា បញ្ហាស្ថានភាពនៃខ្លួនប្រាណរបស់គាត់ គឺយើងគិតទៅប្រាកដជាមានការទទួលរងនូវការមូសខាំយ៉ាងច្រើនហើយ ហើយជាអចិន្ត្រៃយ៍ទៀត ពីព្រោះទីនេះជាក្រុងភ្នំពេញ ហើយសម័យនោះកាន់តែច្បាស់ទៀតដោយសារព្រៃស៊ុបទ្រុបយ៉ាងច្រើន ។ តើលោកមានសង្កេតឃើញទេការមានស្ថានភាពនៃការមូសខាំលើស្បែករបស់ជនទាំងនោះធ្ងន់ធ្ងរទេ? ឬក៏សុះសាច់ទេបើតាមតែលោកសង្កេត?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមសារភាពដោយត្រង់ចុះ អ្នកដែលជាប់ឃុំឃាំងនោះខ្ញុំអត់ដែលបានទៅជិតស្និទ្ធទេ លើកលែងតែមនុស្សប៉ុន្មាននាក់គត់ ដែលខ្ញុំបានទៅជិតស្និទ្ធ ។ ទីមួយ បង តូច ភឿន ក្រោយដែលគេសួរចម្លើយហើយ ស្នាមដែលវ៉ៃ គេគត់គាត់ជាស្រឡះហើយ ខ្ញុំជួប ។ ទីពីរ ឌុកទ័រ វ័ន្ត គត់ ស្នាមដែលគេវ៉ៃ ស្រួលហើយបានខ្ញុំទៅជួបគាត់។ ទីបី ចៅ សេង ។ ចៅ សេង គាត់រស់នៅបាន យូរជាងគេ គាត់ទៅធ្វើការនៅការិយាល័យ ។ ខ្ញុំយកទៅទុកចោលនៅជាមួយបង ម៉ម ណៃ ហ្នឹង ឲ្យគេនិយាយគ្នាលេងទៅ ។ ឯចំណែក កុយ ធួន ខ្ញុំជួបហូរហែនៅពេលដែលខ្ញុំសួរ ។

ដូច្នេះ កុយ ធួន ខ្ញុំជួបមុនសួរ មុនពេលសួរ ។ ដល់ កុយ ធួន មិនមានទារុណកម្មអីចឹង ប៉ុន្តែគ្មានមុងទេៗ ។ ដូច្នេះ មុសនៅពេលនោះនៅស-២១ ខ្ញុំជម្រាបដោយស្មោះត្រង់ចុះ មិនតថ្លៃអីជាមួយនឹងសភាពការណ៍ដែលលោកប្រធានមានប្រសាសន៍អម្បាញ់មិញទេ។ ផ្ទាល់ខ្លួនខ្ញុំ ក៏ខ្ញុំមិនដែលដេកដាក់មុងដែរ ។ ក៏ប៉ុន្តែ មុសនៅស្រុកភ្នំពេញជំនាន់នោះវាមិននាំមេរោគគ្រុនចាញ់អីទេ ។ ក៏ប៉ុន្តែ ផ្ទាល់ខ្លួនខ្ញុំវាចាញ់មុស ខាំភ្លាម ហើមស្ពុល ទាល់តែយកប្រេងកូឡាលាប ។

ដូច្នេះ ដោយសារខ្ញុំមិនបានទៅជាប់ជិតស្និទ្ធជាមួយអ្នកទាំងអស់នោះ នៅពេលដែលរងទារុណកម្មខ្ញុំមិនដឹងជាតើគ្នាវាមានស្លាកស្នាមយ៉ាងម៉េច? ជាពិសេសស្លាកស្នាមវ៉ៃទេ ដែលធ្ងន់ជាងមូសខាំទៅទៀត ។ ហើយខ្ញុំដែលទៅជួបមនុស្សនោះ ទាល់តែគេវ៉ៃរួចហើយ ជាស្រួលបួលហើយ បានខ្ញុំសុខចិត្តទៅជួប ។ ព្រោះបើនៅស្លាកស្នាមខ្ញុំមិនប៊ានជួបទេ មិនដឹងនិយាយជាមួយគាត់ថាម៉េចទេ? ហើយចំណែកបង វន, វ៉ន វេត គាត់អញ្ជើញមកដល់ពីល្ងាច ខ្ញុំព្រឹកឡើងទៅជួបគាត់ ។ ហើយ ពីនុំងមកខ្ញុំអត់ប៊ានទៅជួបទៀតទេ ។ នេះសូមនិយាយដោយត្រង់ នេះចូលសាច់រឿងល្អិត ពាសវាល ពាសកាលហើយ។ ក៏ប៉ុន្តែសរុបមកវិញគឺសុខភាពខាងរូបរាងកាយ ជាសាច់ស្បែកអីរបស់ជនរងគ្រោះ ទាំងអស់ខ្ញុំអត់បានមើលទេ អត់បានសង្កេតទេ អត់បានយកចិត្តទុកដាក់ទេ ។ មនុស្សដែលខ្ញុំទៅជួបប៉ុន្មាននាក់ គឺជួបក្រោយពេលដែលរងទារុណកម្មហើយ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១១:៥៩:១៧]

**ស៖** ចុះអំពីស្ថានភាពនៃការឃុំឃាំងជនបរទេស លោកខាងលិចដែលលោកបានឆ្លើយពីដើមហើយថាមានចំនួនបួននាក់ ។ ប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ? តើមានភាពខុសគ្នា ឬភាពដូចគ្នាដូចម្ដេចរវាងការអ្នកជាប់ឃុំឃាំងទូទៅ ធៀបជាមួយនឹងជនបរទេសទាំងនោះ?

**ឆ៖** ជនបរទេសទាំងបួននាក់ ខ្ញុំសូមសរុបមកវិញមកជាពីរលើក មួយលើកដំបូងពីរនាក់ លើកក្រោយពីរនាក់ ។ លើកក្រោយពីនាក់នេះ ខ្ញុំបានទៅជួបតែម្នាក់ទេ គឺជនជាតិអង់គ្លេស ។ គាត់នៅគុកពិសេស ។ មិត្តប៉ុន ជាអ្នកសួរ ។ ដូច្នេះ ខ្ញុំទៅនិយាយជាមួយគាត់បានពីរបីម៉ាត់ទេ ព្រោះមិត្តប៉ុន មករាយការណ៍ថា យី! មនុស្សអង់គ្លេសនេះ ចេះគួរចេះសម រាបសារដូចខ្មែរយើងអ៊ីចឹងបង។ បងឯងទៅមើលមួយភ្លែតទៅ។ ខ្ញុំក៏សុខចិត្តទៅ ។ ជនអង់គ្លេសនេះ ពេលនោះ បើតាមខ្ញុំចាំមិនទាន់មានទារុណកម្មទេ ។ សភាពនៅធម្មតា នេះនៅក្នុងគុកពិសេស ប៉ុន្តែឱ្យខ្ញុំដឹងថា វាមានមុងឱ្យគេឬអត់ មានកន្ទេលឱ្យគេឬអត់ ខ្ញុំអត់បានយកចិត្តទុកដាក់ទេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណឹង ។ សូមចប់ ។

[១២:០០:៤៧]

**ស៖** អ៊ីចឹងអាចនិយាយបានទេថា ការឃុំឃាំងពួកបរទេស ពួកបស្ចិមប្រទេសហ្នឹង គឺមានការឃុំឃាំងហ្នឹងមានលក្ខណៈពិសេសដោយឡែកពីអ្នកទូទៅ អ្នកឃុំឃាំងទូទៅ ដែលយើងបាននិយាយពីខាងដើមមកហើយនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! តាមកាលដែលខ្ញុំឃើញម្តងនេះ ហើយតាមការដែលសភាពការណ៍ដំណើរនៅពេលនោះ ខ្ញុំអាចសន្និដ្ឋានជូនបានថា ជនបស្ចិមប្រទេសទាំងបួនរូបនេះរស់នៅក្នុងលក្ខខណ្ឌមួយដោយឡែក ខុសអំពីជនរងគ្រោះសាមញ្ញជាទូទៅរបស់ខ្មែរយើង ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**ស៖** ចុះតើស្ថានភាពនៃការឃុំឃាំងជនបរទេស ជាជនវៀតណាមវិញ ជាជនស៊ីវិលវៀតណាម ឬក៏ឈ្លើយសឹកវៀតណាម តើប្រព្រឹត្តទៅយ៉ាងដូចម្តេច មានភាពខុសគ្នា ឬក៏ភាពដូចគ្នាយ៉ាងដូចម្តេចពីអ្នកជាប់ឃុំឃាំងទូទៅ?

**ឆ៖** ជនជាតិវៀតណាមទាំងទាហាន ទាំងស៊ីវិល ដូចគ្នាជាមួយនឹងជានជាតិខ្មែរយើង ដែលគេចាប់យកមកឃុំឃាំង ហើយធ្វើទារុណកម្មសួរចម្លើយហ្នឹង គ្រាន់តែប្លែកៗត្រង់កម្រិតទារុណកម្មទៅលើជនជាតិវៀតណាម ខ្ញុំជឿថាមិនមានខ្លាំងក្លាទេ ពីព្រោះថាសំណូមពរ ចង់បានតែពាក្យគេយកទៅផ្សាយវិទ្យុប៉ុណ្ណឹងឯង ។ នេះខ្ញុំសូមចប់ប៉ុណ្ណេះ ។

**ស៖** អរគុណ ។ ដោយសារឥឡូវនេះ ដល់ពេលត្រូវសម្រាកពិសារអាហារថ្ងៃត្រង់ហើយ ។ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាន្ត ដើម្បីពិភាក្សាអាហារថ្ងៃត្រង់ ។ អង្គជំនុំជម្រះនឹងចាប់បន្តដំណើរការ សវនាការដេញដោលតទៅទៀត នៅវេលាម៉ោងមួយកន្លះរសៀលនេះ ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកសាលសវនាការវិញឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ហើយចំណែកឯភាគីដែលត្រូវចោលរួមក៏ដូច្នេះសូមអញ្ជើញមកចូលរួមដំណើរការនីតិវិធីនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។

*[សវនាការសម្រាកពីម៉ោង ១២:៣:នាទីដល់ម៉ោង ១៣:៣៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។ មុននឹងធ្វើការដេញដោល អង្គជំនុំជម្រះសូមឲ្យអ្នកបច្ចេកទេសខាងជំនួយការរបស់សហព្រះរាជអាជ្ញាធ្វើការបញ្ចាំងនូវរូបភាពមួយចំនួនដែលបានថតយករូបភាពចេញពីអគារឃុំឃាំងនៃមន្ទីរស-២១ដែលមាននៅក្នុងឯកសារជាភាសាខ្មែរដែលមានលេខERN00195373ដល់លេខ00195377 ។ ហើយជាភាសាអង់គ្លេសដែលមានលេខERN00189128, 00189130 តើអាចភ្ជាប់បានទេ លោកតំណាងសហព្រះរាជអាជ្ញា?

**លោក វាលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ យើងមានរូបភាពនោះហើយ ដូច្នេះយើងស្នើសុំខាងសោតទស្សន៍ឲ្យធ្វើការផ្លាស់ប្តូរចរន្តមកខាងចរន្តរូបភាពរបស់ខាងសហព្រះរាជអាជ្ញាវិញ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

យើងសុំអ្នកបច្ចេកទេសដែរ ឃើញថា យើងធ្វើតែរូបភាពត្រឹមតែរូបភាពលេខ39 ដល់លេខ 50 ប៉ុណ្ណោះ ។ ផ្នែកខាងសោតទស្សន៍ សូមភ្ជាប់ប្រព័ន្ធរូបភាពមកជាមួយនឹងកុំព្យូទ័ររបស់សហព្រះរាជអាជ្ញាដើម្បីបញ្ចាំងនូវរូបភាពនៃបន្ទប់ឃុំឃាំងរួមនិងឃុំឃាំងដោយឡែកនៃមន្ទីរស-២១ ។

បន្តៗទៅទៀត ។ សូមបន្តទៀត ។ បន្តទៀតៗ បន្តទៀតមិនយកទេរូបនេះ ។ បន្តទៀតៗៗៗ ។ សូមបញ្ចប់ត្រឹមហ្នឹងចុះ អ្នកបច្ចេកទេសសុំបង្វែររូបភាពផ្តាច់ពីប្រព័ន្ធជាមួយនឹងកុំព្យូទ័ររបស់សហព្រះរាជអាជ្ញាហើយមកប្រព័ន្ធធម្មតាឡើងវិញ ។

នេះជាការបញ្ចាំងអំពីរូបភាពមួយចំនួន នៃរូបភាពបន្ទប់ឃុំឃាំងដោយឡែកហើយនិងបន្ទប់ឃុំឃាំងរួមហើយនិងបន្ទប់ខ្លះមានគ្រែសម្រាប់អ្នកដែលជាប់ឃុំឃាំង ។ តើលោកកត់សម្គាល់ពីរូបភាពនេះ

ម៉េចដែរទេ? ឬក៏ទទួលស្គាល់ថា ជារូបភាពដែលមានថតនៅកន្លែងដែលនៅមន្ទីរនៅស-២១ បច្ចុប្បន្នហៅ គុកទួលស្លែង ពិតប្រាកដ?

[១៣:៣៩:២៧]

**ឆ៖** លោកប្រធានជាទីគោរព! រូបភាពនេះស្ទើរតែទាំងអស់វាជារូបភាពពិតនៃកន្លែងឃុំឃាំងរបស់ស-២១ មជ្ឈមណ្ឌលភ្នំពេញ ។ លើកលែងតែរូបភាពអគារធំហើយមានគ្រែ អង្កាល់ដែលខ្ញុំចូលទៅជួប បងវន អត់ឃើញមានគ្រែទេ ។ ដូច្នេះ ខ្ញុំជឿថារូបភាពដែលមានគ្រែនៅក្នុងបន្ទប់ធំនេះប្រហែលជាក្រោយថ្ងៃ០៣ មករា ដែលសល់យុទ្ធជនយ-៨ បួននាក់ ។ ម្ល៉ោះហើយគេដាក់មួយបន្ទប់ៗ គេដាក់គ្រែឱ្យ ដេក ដូច្នេះ ខ្ញុំសូមសរុបប៉ុណ្ណេះ ។ សូមលោកប្រធានជ្រាប ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ ជាកិច្ចបន្តនេះ តើលោកលោកស្រីជាចៅក្រមនៃអង្គជម្រះ តើមានសំណួរអ្វីត្រូវ សួរដល់ជនជាប់ចោទអំពីអង្គហេតុនៃប្រតិបត្តិការក្នុងការចាប់ខ្លួន ក្នុងការបញ្ជូន និងអង្គហេតុនៃឃុំឃាំងមនុស្សដែលត្រូវបញ្ជូននៅស-២១ នេះដែរឬទេ? បើមានសូមអញ្ជើញ ។

សូមអញ្ជើញលោកស្រី ចៅក្រម ។

**សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណលោកប្រធាន ។ កាលពីសប្តាហ៍មុនគឺយើងផ្តោតលើចំនួនជនជាតិអ្នកទោសវៀតណាម ដែលត្រូវបានចាប់ខ្លួននិងឃុំខ្លួននៅស-២១ ។ ហើយលោកបានយល់ស្របជាមួយនឹងចំនួនដែលមាននៅក្នុងបញ្ជីដាក់បង្ហាញជូនលោកកាលពីលើកមុននោះ ។ ខ្ញុំចង់សួរទៅកាន់លោកនាពេលនេះអំពីអ្នកទោសបរទេសដែលត្រូវបានចាប់ខ្លួនហើយត្រូវបានគេឃុំខ្លួននៅស-២១ ។

យោងតាមលេខ ERN ជាភាសាអង់គ្លេសគឺលេខ 00320844 រហូតដល់លេខ00320845 ។ យើងឃើញមានចំនួនប្រហែលជា៧៨នាក់ អ្នកទោសបរទេសចំនួនប្រហែលជា៧៨នាក់ត្រូវបានគេឃុំខ្លួននៅស-២១ ។ ឯកសារមួយនេះគឺមិនបានបង្ហាញថាបានបកប្រែជាភាសាខ្មែរ ឬក៏ជាភាសាបារាំងនោះទេ ។ ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយគឺវាមិនត្រឹមត្រូវនោះទេដោយសារតែចំនួនអ្នកទោសវៀតណាមនៅក្នុងបញ្ជីគឺយើងមានឃើញចំនួនតិចជាងចំនួនដែលលោកបានសារភាពកាលពីអាទិត្យមិន ។

ខ្ញុំចង់សួរលោកអំពីជាតិសាសន៍អ្នកទោសផ្សេងទៀតដែលមានជាតិសាសន៍ផ្សេងនោះ យោងតាមបញ្ជីដែលខ្ញុំលើកឡើងនាពេលនេះគឺមានជនជាតិអារ៉ាប់មួយរូប ជនជាតិឥណ្ឌាប្រាំរូប ដែលទាំងក្នុង

នោះមានជនជាតិមានបុរសទាំងស្ត្រី ។ ហើយម្ភៃប្រាំបួនជាជនជាតិថៃ ហើយមួយជាជប៉ុន ហើយអ្នកទោសបីនាក់មកពីសហរដ្ឋអាមេរិក បីមកពីបារាំង អ្នកទោសពីរនាក់ពីប្រទេសអូស្រ្តាលី ហើយមួយមកពីចក្រភពអង់គ្លេស ហើយមួយគឺជាជនជាតិឡាវ ហើយមួយគឺជាជនជាតិញូវហ្សេឡេន ណាវ៉ែលហ្សេឡង់ ហើយនិងមានជនជាតិបារាំង ឥណ្ឌា សញ្ជាតិឥណ្ឌា ។ ថាតើលោកទទួលយកមានអ្នកទោសបរទេសបែបនេះដែលត្រូវបានគេចាប់ខ្លួននិងឃុំខ្លួននៅស-២១ដែរឬទេ?

[១៣:៤៤:២០]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! អ្នកទោសដែលជាបស្ចិមប្រទេសដែលខ្ញុំនៅចាំ ហើយនៅក្នុងរយៈកាលដែលខ្ញុំធ្វើជាប្រធានស-២១ មានតែបួននាក់ទេ អង់គ្លេសម្នាក់ ។ ហើយសំណុំរឿងថ្មីៗនេះរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់ក្រុមគ្រួសារហាមីល ។ ហ្នឹងមានពិតជាជនជាតិញ៉ូវហ្សេឡេនធ្លាក់ខ្លួនមករងគ្រោះហើយស្លាប់នៅក្នុងស-២១មែន ។ ឯចំណែកផ្សេងទៀត ពីរនាក់ផ្សេងទៀត ខ្ញុំអត់ទាន់បានអានសំណុំរឿងដើមបណ្តឹងរដ្ឋប្បវេណីរបស់គេទេ ដូច្នេះខ្ញុំមិនទាន់ហ៊ានថាយ៉ាងម៉េចទេ ។

ឯចំណែកជនជាតិដែលជាអាស៊ី ដូចឡាវ ដូចថៃ អាចចូលមកក្រោយតាមព្រំដែន ។ នេះខ្ញុំអត់ទាន់បានឃើញបញ្ជី មិនហ៊ានបញ្ជាក់យ៉ាងម៉េចជូនលោកជំទាវទេ ប៉ុន្តែ សុំសន្និដ្ឋានថាអាចចូលមកតាមព្រំដែនឬក៏តាមសមុទ្រ ។ ឯចំណែកជនអារ៉ាប់ហើយនិងពួកខ្មែរអ៊ីស្លាមដែលខ្ញុំទើបតែហៅប៉ុន្មានថ្ងៃមុនថាមូស្លីមកម្ពុជានេះ ។ ខ្ញុំសន្និដ្ឋានថា ពួកនេះរស់នៅរកស៊ីដោយសុចរិតខាងការចិញ្ចឹមគោនៅកន្លែងមួយដែលគេហៅថាភូមិអារ៉ាប់នៅភ្នំពេញយើងនេះ ។ ដល់ក្រោយមកជម្លៀសហើយចុះឡើងៗគេចាប់មកដាក់នៅខាងតំបន់១៥ សិន បានៗធ្លាក់មកដល់គុកតាខ្មៅរបស់ ណាត ហើយបានៗយកកម្ទេចនៅស-២១ ។

នេះបើតាមការវិភាគរបស់ខ្ញុំ ពួកប៉ុន្មាននាក់នេះជា ហ៊ឺ! វាទៅជាខ្មែរអស់ហើយ ដូច្នេះវាមានពួកនេះ ។ ពិតប្រាកដ ពួកនេះគឺបើតាមខ្ញុំចាំ ខ្ញុំបានឃើញបញ្ជីម្តង ខ្ញុំជឿថាពួកនេះគឺពួកនៅភូមិអារ៉ាប់ ។ ឯចំណែកជនបស្ចិមប្រទេសផ្សេងទៀត ខ្ញុំអត់ដឹងទេ ក្តាប់អត់ទាន់បានដឹងជ្រុងជ្រោយឯណាទេ ដូច្នេះក្នុងករណីដែលមិនទាន់ឃើញឯកសារខ្ញុំសុំមិនទាន់មានមតិ ។ សូមលោកស្រីអធ្យាស្រ័យចំពោះបញ្ហានេះ ។

**ស៖** តើខ្ញុំនិយាយត្រឹមត្រូវដែរឬទេ? គឺលោកមិនជំទាស់ទេ ដែលអ្នកទោសបរទេសទាំងអស់នោះត្រូវបានគេចាប់ខ្លួននិងឃុំខ្លួននៅស-២១?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ដែលខ្ញុំមិនទាន់មានប៉ាន់មានមតិថាជំទាស់ក៏មិនថាៗមិនជំទាស់ក៏មិនថា តែពួកបស្ចិមប្រទេសទេ ។ ឯចំណែកពួកឡាវ ពួកថៃ ខ្ញុំជឿពិតថា ធ្លាក់ខ្លួនមកនៅក្នុង ស-២១ មួយចំនួនណាដោយសារចូលតាមព្រមដែនឬក៏ចូលតាមសមុទ្រ ។ ឯចំណែក ខ្មែរឬក៏ខ្ញុំហៅថាមន្ត្រីមកម្ពុជានោះ គឺពួកប្រជាជនកម្ពុជាដែលរកសុីដោយសុចរិតនៅភូមិអារ៉ាប់ ។ ហើយសូមបញ្ជាក់ឡើងវិញគឺពួកបស្ចិមប្រទេសខ្ញុំមិនទាន់ប៉ាន់សន្និដ្ឋានជូនលោកជំទាវទេ ។ ខ្ញុំសូមទុកបញ្ហានេះពិចារណាដោយឃើញឯកសារសិន ។ សុំៗបញ្ជាក់ជូនសាជាថ្មីប៉ុណ្ណោះ សុំអធ្យាស្រ័យ ។

**ស៖** សូមអរគុណ ។ ខ្ញុំសុំធ្វើការបំភ្លឺអំពីអ្នកទោសបរទេសទាំងអស់ ។

លោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

[១៣:៤៨:២៨]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអភ័យទោសលោកស្រីចៅក្រម ។ សូមឲ្យលោកស្រីធ្វើការអានលេខERNនៃឯកសារនេះឡើងវិញ ឬក៏លេខឯកសារយោងនៃឯកសារមួយនេះ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** គឺលេខE52 គូស4 ចុច 62 ដែលលេខមានERN00320844 ដល់លេខ00320845 ។ តើលោកមេធាវីមានសំណួរចង់ចោទសួរបន្ថែមទៀតទេ? ដើម្បីជាការបំភ្លឺ តើលោកអាចបញ្ជាក់ដែរឬទេថា អ្នកទោសបរទេសទាំងអស់ដែលត្រូវបានចាប់ខ្លួននិងឃុំខ្លួននៅស-២១ ទាំងអស់នោះ គឺត្រូវបានគេប្រព្រឹត្តក្នុងលក្ខណៈដូចគ្នាដូចអ្នកទោសជនជាតិកម្ពុជាផងដែរ? បានន័យថា ពួកគេត្រូវបានគេដាក់ខ្នោះដៃនិងខ្នោះជើង ត្រូវបានរុំមុខ រុំភ្នែក ឃុំខ្លួននៅក្នុងបន្ទប់នីមួយៗ ឬក៏បន្ទប់រួមនៅស-២១ ។

[១៣:៥០:០០]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ!

**ស៖** សូមជនជាប់ចោទដែលធ្វើការបន្តទៀត ។

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ជនជាតិកម្ពុជាក៏ដោយ នៅក្នុងការឃុំខ្លួននៅក្នុងបន្ទប់ហើយឬមួយជាប់ខ្នោះជើងតែម្ខាង ឬមួយជាប់ខ្នោះជើងទាំងពីរ ។ ខ្នោះដៃមិនមានទេ ហើយរុំមុខក៏ដោះដែរ ។ នេះប្រចាំថ្ងៃគឺអ៊ីចឹង ។ ជនបរទេសដែលជាបស្ចិមប្រទេសទាំងបួនរូប តាមខ្ញុំចាំលក្ខខណ្ឌនៃការឃុំខ្លួន និងសួរចម្លើយនៅក្នុងគុកពិសេស មានកន្ទេល មានមុងដេក អាចមានកន្ទេល អត់មុងទេ ។

មានកន្ទេលដេកត្រឹមត្រូវ មានហូបចុកស្រួលបួល ហើយអ្នកសួរក៏ពិសេសរបស់ខ្ញុំដែរ ។ ទារុណកម្មចៀសមិនរួចទេមាន នេះពិត ។

ដោយឡែក ជនជាតិផ្សេងទៀតដែលយើងខ្ញុំហៅថា មូស្លីមកម្ពុជា ដូចគ្នាជាមួយនឹងជនជាតិកម្ពុជាផ្សេងទៀតផង ។ ហើយបើតាមខ្ញុំចាំមូស្លីមកម្ពុជា ដែលរស់នៅភូមិអារ៉ាប់រកស៊ីចិញ្ចឹមគោនេះដូចជាគេយកមកមិនទាំងបានសួរផង ព្រោះខ្ញុំមិនដែលបានរាយការណ៍ចម្លើយពួកនេះទៅដល់ខាងលើទេ ឃើញតែបញ្ជីនៅសល់មានចំនួនប៉ុន្មាននាក់ហ្នឹង ឃើញតែបញ្ជីនៅសល់ទេ ។

សរុបមកវិញអ្នកដែលមិនដូចជនជាតិកម្ពុជា គឺមានតែពួកបស្ចិមប្រទេសដែលខ្ញុំបាទបានជម្រាបលោកជំទាវហើយ ជម្រាបសវនាការហើយបួននាក់ គឺពួកបស្ចិមប្រទេស ។ ឯចំណែក ក្រៅពីនោះ ដូចកម្ពុជា ដោយឡែកពួកអ្នកនៅភូមិអារ៉ាប់ដែលជាមូស្លីមកម្ពុជានេះ ខ្ញុំជឿថា អត់បានសួរចម្លើយផង មកដល់យកទៅក៏គេចាត់ចែងកម្ទេចទៅ ព្រោះខ្ញុំចាំ។ ខ្ញុំសូមនិយាយម្តងទៀត អានេះវាជាន់ដូចអំមិញហើយ។ ព្រោះខ្ញុំចាំថា អត់បានរាយការណ៍ចម្លើយនេះទៅដល់ខាងលើទេ ខ្ញុំផ្ទាល់ខ្លួន គឺសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ សូមចប់ ។

**ស៖** សូមអរគុណ ។ ក្រៅពីនេះ តើលក្ខខណ្ឌ ឬក៏ស្ថានភាពនោះមានសភាពដូចគ្នាដែរឬសម្រាប់ជនបរទេស? មានន័យថា ការព្យាបាលផ្នែកសុខហ្នឹងមានចំនួនតិចតួច មានកម្រិត ហើយម្ហូបអាហារហ្នឹងមានមិនគ្រប់គ្រាន់ ។ ហើយពួកគេមានសម្លៀកបំពាក់មិនគ្រប់គ្រាន់ ហើយនិងលក្ខខណ្ឌដូចគ្នាផងដែរ សម្រាប់ការត្រូវបត់ដែបត់ជើងនោះ ។ តើអ្វីដែលខ្ញុំលើកឡើងនេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវហើយ លើកលែងតែពួកបស្ចិមប្រទេសបួននាក់នុំងផ្សេងដាច់ដោយឡែក ។ សូមអរគុណ ។

[១៣:៥៣:២២]

**ស៖** សូមអរគុណ ។ ឥឡូវនេះ ខ្ញុំចង់និយាយពីប្រភេទអ្នកទោសមួយប្រភេទទៀតដែលត្រូវបានគេចាប់ខ្លួន និងឃុំខ្លួននៅស-២១ នោះគឺចង់និយាយពីស្ត្រី និងកុមារ ។ ដោយយោងតាមឯកសារ E68.8 ដែលមាន ERN ជាភាសាអង់គ្លេស 00331261 ចំនួនភាគរយនៃកុមារ ដែលគេទទួលស្គាល់ថា ត្រូវបានឃុំខ្លួននៅស-២១ នេះគឺចំនួនសរុប គឺ១.៧១ ភាគរយនៃចំនួនអ្នកទោសសរុបនៅស-២១ ហើយចំនួនសរុបនៃស្ត្រី គឺ២១.៨ ភាគរយនៃចំនួនអ្នកទោសទាំងអស់ ។ តើលោកមានឱកាសបានពិនិត្យមើលតារាងនៃការបែងចែកភាគរយអ្នកទោសនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំអត់បានពិនិត្យទេ ក៏ប៉ុន្តែខ្ញុំចាំ ។ មានឯកសារមួយនោះ កុមារត្រូវយកចេញ១៦០នាក់ៗ វាលើសពី១ភាគរយ នៃអ្នកទោសនៅទួលស្លែងទៅទៀត នៅក្នុងឯកសារដែលខ្ញុំបានឃើញ ខ្ញុំបានធ្វើអធិប្បាយរួចមកហើយ១៦០នាក់ ។

**ស៖** ខ្ញុំគិតថា លោកត្រឹមត្រូវហើយនៅក្នុងការវិភាគបែបនេះ ពីព្រោះតារាងនេះ គឺអាស្រ័យទៅលើកុមារដែលឈ្មោះរបស់ពួកគេត្រូវចុះបញ្ជីថា បានឃុំខ្លួននៅស-២១ ។ ដូច្នេះ គឺត្រូវមើលលើបញ្ជីនោះមុនសិន មានន័យថា បញ្ជីឈ្មោះរបស់កុមារដែលត្រូវបានឃុំខ្លួននៅទីនោះ ទៅតាមឯកសារលេខ E68.7 ដែលមានលេខ ERN ជាភាសាអង់គ្លេស 00331257 រហូតដល់លេខ 00331260 ។

លោក ហ្វ្រង់ស្វ័រ រូ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមទោសលោកស្រីចៅក្រម ។ តើយើងខ្ញុំអាចមានលទ្ធភាពសម្រាប់ឲ្យជនជាប់ចោទ បានទទួលឯកសារហ្នឹងដាក់នៅចំពោះមុខរបស់គាត់ នៅពេលដែលមានការនិយាយយោងទៅលើឯកសារណាមួយនៅពេលដែលសួរគាត់នោះ ។ ពីព្រោះអី គឺថាយើងទាំងអស់គ្នាអាចទទួលឯកសារនោះបានរយៈកុំព្យូទ័រ ប៉ុន្តែជនជាប់ចោទមិនអាចបើកមើលបានទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ទាក់ទងទៅនឹងបញ្ជីនេះ គឺថាខ្ញុំនឹងស្នើឲ្យដាក់បញ្ចាំងបញ្ជីនេះទៅលើអេក្រង់ ។ ក្រឡាបញ្ជី តើអាចរៀបចំដាក់តាំងបញ្ជីនេះទេ ឬក៏ខាងសហព្រះរាជអាជ្ញាអាចដាក់បញ្ចាំងបញ្ជីនេះតាមអេក្រង់បានទេ?

[១៣:៥៧:០៤]

**លោក វីលៀម ស្មីត៖**

ប្រសិនបើជាក្រឡាបញ្ជីមិនអាចធ្វើបានទេ ខាងសហព្រះរាជអាជ្ញាអាចធ្វើបាន ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំសូមស្នើផ្នែកសោតទស្សន៍ហ្នឹងបញ្ចាំងអេក្រង់របស់ខាងសហព្រះរាជអាជ្ញាហ្នឹង នៅលើអេក្រង់ធំ ។

ជាដំបូងខ្ញុំចង់ឲ្យលោកមើលនៅខាងក្រោមទំព័របន្តិច ដែលគេមានដាក់អាយុរបស់កុមារ ដែលជាអ្នកទោសអស់ទាំងនោះ ហើយនៅពេលដែលលោកមើលហើយ យើងអាចបន្តទៅទំព័រមួយទៀត ។

**ស៖** តើលោកមានពេលគ្រប់គ្រាន់ ដើម្បីពិនិត្យមើលក្រឡោនដែលបញ្ជាក់អាយុដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ!

**លោក វីលៀម ស្មីត៖**

បាទ គឺនៅសល់មួយទំព័រទៀត ។

**សួរដោចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

**ស៖** តើជាការត្រឹមត្រូវទេក្នុងការនិយាយថា ភាគច្រើននៃកុមារដែលអាយុរបស់ពួកគេត្រូវបានដាក់នៅក្នុងតារាងនេះ គឺមានអាយុចន្លោះពី១៥ ទៅ១៨ឆ្នាំនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវហើយបញ្ហានេះ ។

**ស៖** ហើយកុមារមួយចំនួនដែលមានឈ្មោះនៅក្នុងបញ្ជីនោះ ត្រូវបានគេចាត់ទុកថាជាគិញ ឬក៏ជាភ្នាក់ងារសម្ងាត់ ឬក៏ជាចោរព្រៃជាកុមារ តើលោកមានឱកាសបានពិនិត្យមើលក្រឡោនហ្នឹង ដែរឬទេ?

កុមារភាគច្រើននោះ ត្រូវគេចាត់ទុកថា ធ្វើការជាកម្មករនៅផ្នែកមួយ ឬក៏ជាយុទ្ធជន ឬក៏ពេទ្យ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ ត្រឹមត្រូវហើយ ។

**ស៖** មុននេះបន្តិច លោកបានយោងទៅលើឯកសារមួយ ដែលបាននិយាយអំពីកុមារចំនួន១៦០ នាក់ ខ្ញុំមិនចង់ពិនិត្យមើលឯកសារនោះនៅពេលនេះទេ ក៏ប៉ុន្តែ ខ្ញុំអាចសន្និដ្ឋានបានទេថា គឺមានកុមារច្រើនជាងនេះទៀត ដែលមានអាយុក្មេងជាងនេះដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅស-២១ នោះ ។ ហើយគឺកុមារភាគច្រើនទៀត ដែលមិនមានចុះឈ្មោះនៅលើឯកសារដែលយើងកំពុងតែពិនិត្យ មើលនាពេលបច្ចុប្បន្ននេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! កុមារ១៦០ នាក់ ដែលខ្ញុំជម្រាបអំមិញនេះ ប្រហែលមិនមានចុះឈ្មោះនៅក្នុងបញ្ជីស្រួលបួលទេ ព្រោះបើខ្ញុំចាំ ពួកនេះគឺដកយកចេញពីព្រៃស ។ ដូច្នេះ មានកុមារដែលដកចេញពីព្រៃសនោះភាគច្រើន គឺជាកុមារធំពីអាយុ៣ឆ្នាំ ៤ឆ្នាំ ឡើងទៅ ដូច្នេះមិនមែននៅជំទង់ហើយមានការងារនៅក្នុងជួរបដិវត្តន៍ដូចពួកដែលនៅក្នុងបញ្ជីនេះទេ ។ ដូច្នេះមាន ខ្ញុំជឿថានៅមានទៀតដែលមិនមានចុះឈ្មោះ ។ នេះសូមលោកជំទាវជ្រាប ខ្ញុំសូមរាយការណ៍ជូនប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ ដូច្នេះ គឺហាក់បីដូចជាអាចធ្វើការសន្និដ្ឋានថា កុមារដែលឈ្មោះនៅក្នុងបញ្ជីនេះ គឺជាកុមារដែលត្រូវបានចាប់ខ្លួន មកពីបានប្រព្រឹត្តបទល្មើស ឬក៏កំហុសអ្វីមួយ ។ មានន័យថាមិនមែនមកពីតែពួកគេជាកុមារនោះទេ តើអ្វីដែលខ្ញុំនិយាយត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! លោកជំទាវមានប្រសាសន៍ហ្នឹង ត្រឹមត្រូវហើយ ព្រោះអ្នកដែលជាប់ឈ្មោះជាប់ក្នុងបញ្ជីនេះ គឺមានកំហុសផ្ទាល់ហើយ ឯចំណែកអ្នកដែលតាមម្ដាយ ឬតាមឪពុកមក អត់មានឈ្មោះនៅក្នុងបញ្ជីនេះទេ ។

**ស៖** ហើយដើម្បីជាការបញ្ជាក់ឲ្យបានច្បាស់ ហេតុអ្វីបានជាលោកមិនខ្វល់ខ្វាយក្នុងការចុះឈ្មោះកុមារដែលមកជាមួយម្ដាយរបស់ពួកគេនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ក្នុងរឿងចុះកុមារដែលមកជាមួយម្ដាយ ឪពុកគេហ្នឹង វាជាការប្រតិបត្តិមួយដែលវារត់របត់ តាមខ្ញុំចាំរត់របត់តាំងពីមុនខ្ញុំមកកាន់កាប់ស-២១ ម្ល៉េះ ។ វាហូរហែមក ពីមុនមក ។ ហើយផ្ទាល់ខ្លួនខ្ញុំ ដូចខ្ញុំជម្រាបហើយជម្រាបទៀត ឥឡូវខ្ញុំ សូមបញ្ជាក់ជូនម្ដងទៀតចំពោះបញ្ហាកុមារនេះ ខ្ញុំចុះចាញ់ទស្សនៈរបស់បក្សហើយ មិនប៉ានការពារកុមារទេ ព្រោះខ្លួនឯងមានពិសោធចញ្ចឹមមិនរស់ ហើយគេថា មិត្តគិតទៅពង្រឹងទស្សនៈវណ្ណៈទៅ ប្រយ័ត្នដល់ធ្វើថ្ងៃក្រោយពួកនេះសងសឹក ។ ដូច្នេះ ខ្ញុំក៏សុខចិត្តចុះចាញ់ទស្សនៈគេ ។

[១៤:០៤:៥១]

សរុបមកវិញ បញ្ហាមានពីរ ។ ទីមួយ ការងារមិនចុះឈ្មោះកុមារ មិនខ្វល់ខ្វាយហ្នឹង វាជាមាគ៌ាមួយដែលមន្ទីរនគរបាលមុនរបស់៧០៣ គេធ្វើ ខ្ញុំក៏ធ្វើបន្តទៅទៀត ដោយទស្សនៈខ្ញុំក៏ឯកភាពហ្នឹងគេដែរ ។ សូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ ហើយជាពិតណាស់ ពីមុនក៏លោកបានពន្យល់ផងដែរថា លោកបានព្យាយាមចិញ្ចឹមក្មេងបីនាក់ ប៉ុន្តែមិនបានរស់ទេ ។ ហើយលោកក៏បាននិយាយផងដែរ និយាយប្រាប់ដល់សហចៅក្រមស៊ើបអង្កេតអំពីវិប្បដិសារីរបស់លោក ដែលលោកមិនបានព្យាយាមឲ្យបានប្រឹងប្រែងខ្លាំងពេកនោះ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវហើយ ខ្ញុំមិនយកលេសនេះ ហើយបិទបាំងឧក្រិដ្ឋកម្មរបស់ខ្លួនទៅលើកុមារទេ ។ ខ្ញុំចុះចាញ់គេវារឿងមួយ ប៉ុន្តែឧក្រិដ្ឋកម្មវារឿងមួយទៀត អត់ប្រកែកទេ ។

**ស៖** ហើយនៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលមានលេខ D52/1.4 ដែលមានលេខ ERN 00197738 ។ លោកបាននិយាយអំពីការអង្កេតមើល អ្នកដែលជាខ្មែរក្រហមផ្សេងៗទៀត ដែលចិញ្ចឹមកុមាររស់ ប៉ុន្តែ លោកសោកស្ដាយណាស់ ដែលថា ចិញ្ចឹមកុមារទាំងនោះមិនរស់នោះ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! វិប្បដិសារីនេះ ការខ្មាស់ខ្ញុំ-- ការដែលខ្ញុំខ្មាស់គេនេះ វានៅជាប់អត់ភ្លេចពេលណាទេ ។

**ស៖** បញ្ជីដែលនៅកំពុងតែបញ្ចាំងនៅលើអេក្រង់នេះ គឺនិយាយអំពីកុមារដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួន សម្រាប់បទល្មើសអ្វីមួយដែលពួកគេបានប្រព្រឹត្ត ។ តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ ថាពួកគេនោះត្រូវបានគេចាប់ខ្លួននិងឃុំខ្លួន ដោយដាក់ខ្នោះជើងនៅក្នុងបន្ទប់រួម ដោយមានស្ថានភាពដូចគ្នាទៅនឹងអ្នកទោសដទៃៗដែរនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ពិតហើយ ពិតជាដូចហើយ ។ ថ្វីត្បិតតែខ្ញុំមិនបានទៅមើលផ្ទាល់នឹងភ្នែកក៏ដោយ ក៏ខ្ញុំជឿថា វាពិតជាដូចគ្នា ។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយពីប្រភេទអ្នកទោសមួយទៀត ។ ត្រូវចាំថាពេលនេះ យើងកំពុងតែនិយាយអំពីការចាប់ខ្លួន និងការឃុំខ្លួននៅស-២១ តែប៉ុណ្ណោះ ។ ហើយយើងមិននិយាយអំពីការសួរចម្លើយ ឬក៏ការធ្វើទារុណកម្មនោះទេ ។ ខ្ញុំចង់ឲ្យលោកនិយាយយោងទៅលើឯកសារលេខ E68.6 ដែលមានលេខ ERN 00331192 រហូតដល់លេខ 00331256 ប្រហែលជាខាងសហព្រះរាជអាជ្ញាអាចធ្វើការបង្ហាញឯកសារនេះ នៅលើអេក្រង់បាន តែត្រូវចាំថាឯកសារនេះគឺមានច្រើនទំព័រណាស់ ។

[១៤:០៩:១១]

**លោក វីល្មៀម ស្មីត៖**

លោកស្រីចៅក្រម ពួកយើងកំពុងរកឯកសារនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អរគុណច្រើន អ៊ីចឹង ។

តើសុំឲ្យលោកបង្ហាញទំព័រចុងក្រោយ?

សូមអរគុណ ។ ឯកសារនេះ គឺមានចំណងជើងថា "អ្នកទោសដែលត្រូវបានគេកំណត់ថាជាស្ត្រី" ហើយលោកឃើញហើយនៅក្នុងលេខចុងក្រោយនៃទំព័រចុងក្រោយនេះ គឺមានចំនួន១.៦៩៨ អ្នក

ទាំងអស់នេះ ជាស្ត្រី ហើយត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅស-២១ ។ ថាតើលោកអាចមានយោបល់អ្វីលើកឡើង ចំពោះចំនួនតួលេខនេះដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកស្រី លោក លោកស្រីចៅក្រម! វាជាចំណុចសំខាន់ក្នុងការបញ្ជាក់ នូវចំណងជើងដែលលោកស្រីបានលើកឡើង គឺវាមិនមែនជាចំណងជើង ដែលវាកំណត់ដោយស-២១ ទេ ។ បញ្ជីនេះ ត្រូវបានបង្កើតឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ។ ដូច្នេះហើយ គឺគេមានបញ្ជាក់អំពីចំណងជើងសម្រាប់កំណត់ហេតុ ដូច្នេះ ហើយចំណងជើងនេះ គឺផ្តល់ឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ដូច្នេះវាមិនមែនជាឯកសារដើមដែលមានប្រភពចេញមកពីស-២១ នោះទេ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណ ។ ឯកសារនេះ និងឯកសារពីរ ដែលខ្ញុំបានបង្ហាញក្នុងថ្ងៃនេះ ហើយនិងតារាងនិងបញ្ជី ដែលទាក់ទងទៅនឹងអ្នកទោសវៀតណាមត្រូវបានគេចាប់ខ្លួន និងឃុំខ្លួននៅស-២១ ។ ឯកសារទាំងអស់នេះ គឺដកស្រង់ចេញមកពីបញ្ជីរួមទាំងអស់នៃអ្នកទោស ហើយត្រូវបានបំបែកជាផ្នែកផ្សេងៗ ហើយការងារនេះ គឺត្រូវបានធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ។ យើងត្រឡប់ចូលមកឯកសារនេះវិញ ។ លោក កាំង ហ្គេកអ៊ាវ តើលោកមានឃើញចំនួនតួលេខ១.៦៩៨ នេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ ខ្ញុំឃើញ នៅ*កូឡោន* ទីមួយ ។

**ស៖** ដូច្នេះ យើងសូមពិនិត្យមើលនៅលើទំព័រចុងក្រោយនេះ ប្រសិនបើយើងពិនិត្យទៅលើតួនាទីដែលស្ត្រីនេះគាត់ធ្វើ ។ តួនាទីមួយចំនួន គឺវាបានរៀបរាប់គឺមានជាកូនស្រីរបស់ ខ្លះបានបង្ហាញថាជាកូនស្រីរបស់បុគ្គលផ្សេងៗ ហើយជាយុទ្ធជនស្ត្រី យុទ្ធនារី ហើយនិងអ្នកកាសែត មកពីកាសែតជប៉ុន អ្នកមកពីខាងភស្តុភារ ។ ដូច្នេះ ស្ត្រីជាច្រើន និងតួនាទីដែលគេមាន និងអ្នកទាំងអស់នោះដែលត្រូវបានឃុំខ្លួននៅស-២១ ថាតើពួកគេមានជាប់ទាក់ទងទៅនឹងអ្នកទោសផ្សេងទៀតដែរឬទេ? គឺស្ត្រីដែល ឬក៏ស្ត្រីទាំងអស់នេះ ត្រូវបានគេឃុំខ្លួន ដោយសារបញ្ហាពួកគេផ្ទាល់ខ្លួន?

[១៤:១៤:១៥]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ភាគច្រើនស្ត្រីទាំងអស់នេះដែលជាប់នៅស-២១ ជាប់មកដោយសារប្តី ។ បីខាងដើមនេះ ប្រពន្ធ ខ្វា លាង, ប្រពន្ធ អាសល, ប្រពន្ធ កុយ ធួន សុទ្ធតែក្នុងនាមជាប្រពន្ធគេ ។ ដូច្នេះ ភាគច្រើនអ្នកដែលមកជាប់នេះ ក្នុងឋានៈជាប្រពន្ធគេ ហើយស្ត្រីផ្សេងទៀត ជាប់មក

ក្នុងឋានៈជាកូនរបស់គេ ហើយអ្នកខ្លះអាចជាម្តាយគេថែមទៀតហើយ ។ ខ្ញុំមើលអំមិញ ដូចមានអ្នកម្តាយមួយម៉ាត់ដែរ ។ នៅក្នុងទំព័រដដែលដែលនៅនឹងមុខខ្ញុំបាទ អ្នកដែលមានតួនាទីរបស់គេ គឺមានតែនៅក្នុងលេខរៀងទី៤ទេ ឈ្មោះ យ៉ុង អេង ។ លេខរៀង៥ យុទ្ធនារីមន្ទីរម-១៧ ។ លេខរៀងទី៦ (អំ សុំទោស) ១, ២, ៣, ៤, ៥, ៦, ៧, ៨, ៩, ១០, លេខរៀងទី១១ ឈ្មោះ យូ ទូច នៅខាងភស្តុភារ ហើយលេខរៀងទី១៧ អ្នកយកាសែតជប៉ុន អ្នកយកការណ៍ឲ្យកាសែតជប៉ុន ឈ្មោះ យុន ហួរ ហៅ លើន ក្រៅពីនោះប្រពន្ធគេ ហើយនិងកូនគេទាំងអស់ ។

ដូច្នេះសរុបមក ស្ត្រីភាគច្រើនមកជាប់នៅស-២១ ដោយសារមានតួនាទីជាប្រពន្ធគេ ជាកូនគេ មួយចំនួនណាតូចជាម្តាយ ។ ក៏ប៉ុន្តែ ក្នុងនោះមានមួយចំនួនដែលត្រូវចងចាំដែរ មានតួនាទីរបស់ខ្លួននៅក្នុងជួរបដិវត្តន៍ ឬនៅក្នុងសង្គមចាស់ ។

**ស៖** ដូច្នេះ វាមានស្ត្រីដែលមានឋានៈខ្ពស់តិចតួចប៉ុណ្ណោះ ដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅ ស-២១ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! គឺពិតជាត្រឹមត្រូវហើយ ។

**ស៖** ដូច្នេះ ចំនួនភាគច្រើននៃស្ត្រីដែលត្រូវបានចាប់ខ្លួននោះ គឺពួកគេមិនបានប្រព្រឹត្តកំហុសអ្វីនោះទេ ។ ក្នុងនាមលោកជាប្រធាន ស-២១ ដែលបានដឹងអំពីបញ្ហានោះតើត្រឹមត្រូវដែរឬទេ?

[១៤:១៦:៤៨]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវហើយ ខ្ញុំជឿថាលើសពីពាក់កណ្តាលនៃស្ត្រីដែលចាប់ខ្លួនមកស-២១ មិនមានកំហុសអីផ្ទាល់ទេ ។

**ស៖** លោកបានរៀបរាប់អំពីស្ថានភាពនៅស-២១ ចំពោះអ្នកទោសបុរស ។ លោកបានលើកឡើងថា ស្ត្រីគឺអនុញ្ញាតឲ្យស្លៀកពាក់ ហើយពេលខ្លះគឺឲ្យធ្វើការនៅខាងក្រៅ ។ ថាតើស្ត្រីទាំងអស់នោះទទួល បានអាហារគ្រប់គ្រាន់ដែរឬទេ នៅពេលដែលពួកគេត្រូវបានឃុំនៅស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! អាហារខ្ញុំសូមជូនជាការសន្និដ្ឋានទៀតហើយ ខ្ញុំអត់ច្បាស់ទេ ខ្ញុំសូមជូនការសន្និដ្ឋានមួយម៉ាត់ថា មិនគ្រប់គ្រាន់ ដូចមនុស្សមានសេរីភាពទេ សូម្បីតែមនុស្សមានសេរីភាពយ៉ាងម៉េចនៅជំនាន់នោះ ក៏គង់ខ្វះអាហារហូប ។ ដូចខ្ញុំបានជម្រាបអង្គសវនាការពីមុនអីចឹង សូម្បីតែ ម្តាយខ្ញុំហ្នឹងក៏ដោយ ក៏ខ្វះអាហារហូបដែរជំនាន់នោះ នេះសូមបញ្ជាក់ជូនអីចឹង។ ដូច្នេះ អ្នកទោសនៅ ស-២១ គ្មានអាហារអីគ្រប់គ្រាន់ទេ ស្ត្រីក៏ដោយ កុមារក៏ដោយ ។

**ស៖** ថាតើត្រូវបានគេដាក់ខ្នោះដៃ ខ្នោះជើង ឬក៏រុំមុខក្នុងពេលដែលគេត្រូវបានឃុំខ្លួននៅស-២១ នោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! រឿងនេះខ្ញុំដឹងក្រោយមកទេ គឺអត់មានដាក់ខ្នោះជើងទេ ពេលយប់ក៏ដោយ ពេលថ្ងៃក៏ដោយ ដូច្នេះក៏គ្មានរុំមុខដាក់ខ្នោះដៃអីដែរ អត់មានទេ ។

**ស៖** យើងដឹងថា យ៉ាងហោចណាស់ស្ត្រីមួយចំនួននោះ គឺមានកូនតូចៗនៅជាមួយគាត់នៅពេល ដែលពួកគេត្រូវបានចាប់ខ្លួន តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ប្រាកដជាត្រឹមត្រូវ ជម្រាបប្រសាសន៍ ។

**ស៖** ហើយក្មេងៗតូចៗទាំងអស់នោះ គឺតាមការសន្និដ្ឋានគឺ មានអាយុប្រហែលជា១០ទៅដល់ ១២ ឆ្នាំ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** មានអាតូចជាងនោះទៅទៀតក៏មានដែរ ជម្រាបប្រសាសន៍លោកជំទាវ ។ មានអាយុមួយឆ្នាំអីៗហ្នឹង ដូចជារូបនៅក្នុងហ្នឹងដែរ មួយឆ្នាំ នៅបី មិនដល់មួយឆ្នាំផងក៏មាន ។

**ស៖** កូនក្មេងតូចៗទាំងអស់នោះ ថាតើគេទុកឲ្យនៅជាមួយម្តាយនៅក្នុងបន្ទប់នោះតែមួយ ឬក៏យ៉ាងម៉េច?

[១៤:២០:០០]

**ឆ៖** ខ្ញុំមិនច្បាស់ទេ ប៉ុន្តែឮល្បីមកលើកក្រោយថា គេបំបែក មកដល់គេបំបែកកូនចេញពីម្តាយ។ លួចយកកូនទៅកម្ទេច យកកូនចេញទៅកម្ទេច ។ បើចាំបាច់ទុកម្តាយឲ្យសួរគេធ្វើអីចឹង ។

**ស៖** ថាតើលោកធ្វើដំណើរជុំវិញគុកទេជារៀងរាល់ថ្ងៃនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បើសិនជាកន្លែងគុកនេះ និយាយឲ្យចំទៅខ្ញុំទៅបានតិចតួចនៅគុកពិសេស ។ ក៏ប៉ុន្តែ ដល់គុកជាទូទៅគឺមិនចូលទៅមើលក្នុងអគារគុកនេះទេ ។ ដល់ក្រោយមកដែលខ្ញុំស្អុគស្អាញ ខ្ញុំទៅអង្គុយសំកុកនៅកន្លែងគូរផ្គាក់នេះមែន ។ ខ្ញុំសូមជម្រាបប៉ុណ្ណោះ ។

**ស៖** នៅពេលដែលលោកៗដើរនៅជុំវិញជារៀងរាល់ថ្ងៃ ។ តើលោកបានឮកូនក្មេងដែរ ឬទេ ដែលស្រែកអីផ្សេងៗនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំដូចជម្រាបរួចមកហើយ ។ ខ្ញុំអត់ដើរទេ មិនងាយបានដើរជុំវិញគុកនោះទេ ។ ចៀសទៅយូរៗម្តង ទៅក្នុងមួយជីវិតស-២១ នោះ ខ្ញុំទៅចូលគុកពិសេសហ្នឹងបានប្រហែលពីប្រាំទៅដប់ដងទៅចុះ ប៉ុណ្ណឹង ។ ក្រៅពីនោះគុកធម្មតាហ្នឹងអត់បានចូលទេ ចូលៗទៅនឹង

ទីចាត់ការហ្នឹងដែលជាកន្លែងជារោងជាងគូរហើយនិងឆ្លាក់ ខ្ញុំចូលទៅអង្គុយសំកុកនៅនុ៎ង មានមែន ។ ដូច្នេះ ក្មេងក៏មិនដែលឃើញរត់ ប្រហែលជាគេបំបែកយកទៅព្រៃ-ស ឬក៏លួចយកទៅកម្ទេច សម្លាប់មិនឲ្យម្ដាយដឹង អាហ្នឹងមែន ។ ត្រង់ឮស្រែកយំអីៗខ្ញុំមិនឮទេ នេះជម្រាបដោយស្មោះ ។

**សៈ** តើខ្ញុំអាចសួរដែរឬទេថាស្ត្រី ឬក៏កូនក្មេងនោះមានការព្យាបាលផ្នែកសុខភាពដែរឬទេ ទោះបីជាពួកគេមិនត្រូវបានគេសួរចម្លើយនោះ?

**ឆៈ** បើតាមខ្ញុំពិចារណាស្ត្រី ហើយនិងកូនក្មេងណាដែលគេត្រូវការប្រើ ការយកចិត្តទុកដាក់ខាងសុខភាពមានកម្រិតជាងជាស្ត្រីដែលគេមិនត្រូវការប្រើ ហើយស្ត្រីដែលគេមិនត្រូវការប្រើហ្នឹងប្រហែលគេប្រញាប់យកទៅដើងឯកហើយ គេមិនទុកយូរទេ ។ នេះសូមជម្រាបប្រសាសន៍ប៉ុណ្ណេះ ។

**សៈ** ថាតើអ្នកទាំងអស់នោះ គឺមានបន្ទប់សម្រាប់បត់ដៃបត់ជើងគ្រប់គ្រាន់ដូចបុរសដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍ ខ្ញុំអត់ច្បាស់ទេរឿងហ្នឹង ប៉ុន្តែ ដូចជាមិនបត់ជើងបត់ដៃ ក្នុងសភាពមួយដែលបាត់បង់លក្ខណៈស្ត្រីភេទ ខ្ញុំជឿថាអ៊ីចឹង ។ ដូចជាមានបន្ទប់កន្លែងណាមួយដែលគេទុកឲ្យស្ត្រីប្រើប្រាស់ ឲ្យខ្ញុំច្បាស់ ខ្ញុំអត់ច្បាស់ទេ នេះជម្រាបដោយស្មោះត្រង់ប៉ុណ្ណឹង ។

[១៥:២៣:៥៥]

**សៈ** ថាតើមានការរៀបចំសម្រាប់ភាព តម្រូវការផ្នែកសុខភាពអនាម័យសម្រាប់ស្ត្រីនិងកូនក្មេងដែរឬទេ?

**ឆៈ** ស្ត្រីហើយនិងកូនក្មេងមិនមានអីជាពិសេសជាងអ្នកធម្មតាទេ ។ ដូចខ្ញុំបានជម្រាបលោកជំទាវរួចហើយ ។ ក្មេងដែលកុមារតូច ហើយនិងកុមារធំភាគច្រើនៗតែមកដល់គេបំបែកពីម្ដាយហើយគេទៅកម្ទេចទៅ ។ ដូច្នេះ គ្មានរឿងអីជាការរៀបចំទេ ។ ឯចំណែក ស្ត្រីបើសិនជាគេត្រូវការសួរចម្លើយគេទុកយូរបន្តិច បើគេមិនត្រូវការសួរចម្លើយទេ គេមិនសូវជាទុកទេ ហើយជាពិសេសគេមិនតែផងគេយកចេញទៅហើយ ។

**សៈ** យើងដឹងថា ក្នុងអំឡុងពេលមួយនោះ អ្នកយាមស្ត្រីឬក៏អ្នកសួរចម្លើយស្ត្រីត្រូវបានគេយកមកប្រើប្រាស់ ហើយពេលខ្លះទៀតអ្នកទោសជាបុរសធ្វើការយាមកាមទៅលើអ្នកទោសស្ត្រី ។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! អ្នកសួរចម្លើយជាភេទស្រី ហើយសួរចម្លើយអ្នកទោសស្រីមានចាត់តាំង ថ្ងៃខែខ្ញុំមិនចាំទេ តែខ្ញុំជាអ្នកចាត់តាំង មាន ។ ឯចំណែកការយាមកាម គ្មានអ្នកយាម

ស្រី យាមៗអ្នកទោសស្រីទេ គ្មានទេ គឺអ្នកទោសប្រុសយាមស្រី នេះសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** ដូច្នេះ ការថែទាំនិងភាពឯកជន គឺលោកមិនបានគិតពិចារណានោះទេក្នុងនាមលោកជាប្រធាននៅស-២១ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ប្រាកដហើយ ការងារនេះយើងខ្ញុំទុកៗឲ្យគេធ្វើ ចាត់ទុកជាការងារផ្ទាល់របស់គេ សម្រាប់គេ ។ គេទទួលខុសត្រូវចំពោះខ្ញុំ តែធ្វើម៉េច ទីមួយកុំឲ្យរត់រួច ទីពីរកុំឲ្យតដៃបាន ហើយទីបី កុំយកមនុស្សណាដែលកំពុងសួរទៅវ៉ៃ យកទៅជើងឯកឲ្យដាច់ចម្លើយ នេះគឺខ្ញុំដឹងប៉ុណ្ណឹង គេទទួលខុសត្រូវចំពោះមុខប៉ុណ្ណឹង ។ ហើយការថែទាំយ៉ាងម៉េចអីយ៉ាងម៉េច គេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១៤:២៦:៣៧]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន គឺខ្ញុំអស់សំណួរទៀតហើយ ។ ដូច្នេះ តារាងនេះគឺអាចដកចេញពីរូបភាពអេក្រង់របស់យើងហើយ ។

**ប្រធានអង្គជំនុំ៖**

អស់លោកចៅក្រម តើមានសំណួរអ្វីសួរដល់ជនជាប់ចោទអំពីអង្គហេតុនៃការដែលយើងដាក់ពិភាក្សានៅពេលនេះទេ? បើមានសូមអញ្ជើញ ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** គឺមានការចង្អុលយោងទៅលើចំនួនអ្នកទោសនៅស-២១ ជាពិសេសចំពោះអ្នកទោសបរទេស ។ ខ្ញុំចង់ចូលទៅដល់ចំណុចមួយគឺទាក់ទងទៅនឹងអ្នកទោសចិន ។ លោកបានលើកឡើងថាមានអ្នកទោសចិន តើលោកអាចពន្យល់ដែរឬទេ? ហេតុអ្វីបានជាគេមានការឃុំខ្លួនអ្នកទោសចិននៅស-២១ នោះ?

**ឆ៖** ចំពោះអ្នកទោសដែលជាជនជាតិចិន ខ្ញុំនៅចាំបានថា ទីមួយគឺអាណិកជនចិននៅក្នុងចំណោមប្រជាជនកម្ពុជា ជាផ្នែកមួយនៃប្រជាជនកម្ពុជា ។ ដូច្នេះ គេចាប់មកដោយសារកំហុសនៅក្នុងរដ្ឋអំណាចកម្ពុជា ។ ហើយទីពីរ មានអាណិកជនចិនមួយចំនួនចូល មានអាណិកជនចិនមួយចំនួនបម្រើបក្សកុម្មុនីស្តកម្ពុជា ហើយបានចូលបក្ស ។ ក៏ប៉ុន្តែ គេចាប់មកដែរ ដោយមានពិរុទ្ធភាពនៅក្នុងការងាររួមផ្សំនឹងចម្លើយទៅពី ស-២១ គេចាប់មក ។

ឧទាហរណ៍ អាណិកជនចិនម្នាក់ ដែលប្រែឈ្មោះមកជាខ្មែរសុទ្ធហើយ ង៉ែត យូ ហៅ ហុង ។ ង៉ែត យូ, ង៉ែត យូ អ៊ិន-ហ្សេ-អ៊ិន-តេ អ៊ីការិក-អូ-អ៊ុយ ។ បង ង៉ែត យូ ក៏គេចាប់មក ហើយចាប់អាណិកជនពីរនាក់ទៀតដែលធ្វើការជាមួយនឹងគាត់ គឺ សូ ជា ហើយនិង សូ យក់ ។ សូ ជា ៗ អេស-អូ-សេ-អាស-អឺ-អា ។ សូ យក់ អេស-អូ អ៊ីការិក-អូ-កា ។ អាណិកជនចិនទាំងបីនាក់នេះ ជាមនុស្សដែលនៅក្នុងជួរបដិវត្តន៍កម្ពុជា ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។ ទីមួយប្រជាជន ទីពីរក្នុងជួរបក្ស ។

**ស៖** តើពួកគេទទួលបាននូវការប្រព្រឹត្តមកលើដូចគ្នាដែរ ឬក៏ពួកគេទទួលបាននូវការប្រព្រឹត្តិពិសេសមួយខុសពីអ្នកទោសដែលជាជនជាតិខ្មែរ ឬមួយក៏ការប្រព្រឹត្តនោះគឺដូចគ្នាបេះបិទ ឬមួយក៏ដោយសារពីគេមានជាតិសាសន៍ជាជនជាតិចិន? ដូច្នេះ ពួកគេត្រូវបានចាត់ទុកថា ជាខ្មាំងរួចទៅហើយនោះ ឬក៏យ៉ាងម៉េច?

**ឆ៖** ច្បាប់ទូទៅ ពួកអាណិកជនចិនចាត់ទុកជាប្រជាជនកម្ពុជា ។ មិនមានស្នាមអីឲ្យឃើញថាអាណិកជនចិនគេប្រកាន់ទោសជាងខ្មែរទេ ។

**ស៖** កាលពីព្រឹកមិញលោកបាននិយាយអំពីចំនួនមនុស្សដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅស-២១ ហើយក៏បាននិយាយយោងផងដែរទៅលើចំនួនដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយលោកក៏បានពន្យល់ផងដែរ ទៅតាមការយល់ដឹងត្រឹមត្រូវរបស់ខ្ញុំចំពោះអ្វីដែលលោកលើកឡើងនោះ ។ គឺលោកនិយាយថា អំពីបញ្ជីឈ្មោះអ្នកទោសដែលត្រូវដោះលែង ហើយបានជាខ្ញុំយល់ឲ្យបានត្រឹមត្រូវទៀតនោះលោកបាននិយាយថា ការបង្ហាញបែបនេះនៅលើឯកសារបែបនេះ គឺជាចំណុចក្លែងក្លាយទេ ជាព័ត៌មានក្លែងក្លាយទេ ។ តើអ្វីដែលខ្ញុំយល់នេះត្រឹមត្រូវទេពីអ្វីដែលលោកបាននិយាយកាលពីព្រឹកមិញនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពាក្យដែលខ្ញុំនិយាយទាំងប៉ុន្មាននេះលោកចៅក្រមស្តាប់បានខ្លឹមសារទាំងស្រុងហើយ ។

**ស៖** លោកបានយោងទៅលើឯកសារជាច្រើនហើយប្រហែលជាខ្ញុំអត់មានលេខ ERN គ្រប់ឯកសារអស់ទាំងអស់ទាំងនោះទេ ។ ប៉ុន្តែ លោកក៏បាននិយាយអំពីសៀវភៅរបស់អ្នកស៊ើបសួរ អ្នកសួរចម្លើយម្នាក់នោះដែរ។ ខ្ញុំមិនច្បាស់សោះ ហេតុអ្វីបានជានៅក្នុងសៀវភៅកំណត់សម្គាល់របស់គាត់អ៊ីចឹងគាត់មានការលើកឡើងអំពីការចោទប្រកាន់អំពីការដោះលែងអ្នកទោសនោះ តើលោកអាចពន្យល់បានទេទៅលើចំណុចនេះ ។

**ឆ៖** ខ្ញុំសូមបញ្ជាក់ទីមួយអំពីសៀវភៅកំណត់ដៃនេះ ។ សៀវភៅកំណត់ដៃនេះជាសៀវភៅកំណត់ដៃរបស់បង ម៉ម ណៃ ហៅ ចាន់ ។ ដើមឡើយ ណាត គាត់ប្រើបង ម៉ម ណៃ ហៅ ចាន់ នេះទុកដូចជាស្មៀនគាត់ ។ អត់*អាកស៊ីស្តង់* ទេ ជាស្មៀនៗ ជាលេខា ហើយក៏ចាត់តាំងបង ម៉ម ណៃ នេះឲ្យមានឈ្មោះថា ជាប្រធានម-២១ ដែលមិនមានអ្នកណាគេទទួលស្គាល់ពីខាងលើមកទេ ។

[១៤:៣៥:១៦]

នៅក្នុងទំព័រ បីទំព័ររបស់សៀវភៅនេះ មានឈ្មោះមនុស្សដប់មួយនាក់ ។ បីទំព័រ១១ ។ មានឈ្មោះមនុស្សដប់មួយនាក់ ដែលចារថា "សុំដោះលែង" ហើយក្រោយមក ណាត ប្រាប់ថាយល់ស្របដោះលែង ។ ដើម្បីច្បាស់លាស់ បើសិនជាលោកចៅក្រមចង់បញ្ជាក់ ខ្ញុំសូមឲ្យគេបញ្ចាំងទំព័រទាំងនេះនៅលើអេក្រង់ ។

**ស៖** តើលោកមានលេខយោងឯកសារនេះដែរឬទេ? ខ្ញុំមិនប្រាកដថាតើយើងគួរតែចំណាយពេលវេលាច្រើនទៅលើចំណុចនេះទេ ពីព្រោះអីយើងនឹងស្តាប់សក្ខីកម្មសាក្សីម្នាក់ក្នុងចំណោមអ្នកអស់ទាំងហ្នឹង ។ ហើយខ្ញុំចង់បន្តទៀតអំពីការយោងទៅលើឈ្មោះ ណាត របស់លោក ។

តើហេតុអ្វីបានជាឯកសារសរសេរជាលាយលក្ខណ៍អក្សរបែបហ្នឹងមានការសរសេរអំពីអ្នកដែលត្រូវបានគេដោះលែងនោះ? តើនោះគឺជាការសម្តែងចេញដោយប្រើជាលេខកូដ ជាលេខសម្ងាត់ឬមួយថាពួកគេហ្នឹងឯងត្រូវបានគេសម្លាប់ហើយ ដែលតាមពិតខាងក្រៅគេប្រើពាក្យថា ពាក្យ "ត្រូវបានដោះលែងនោះឬ?"

**ឆ៖** ពាក្យដែលណាតប្រើថា "ដោះលែងនេះ" គឺជារបាំងសម្រាប់បិទបាំងបទល្មើសរបស់គាត់ដែលគាត់ល្មើសនឹងមាគ៌ាចាត់តាំងរបស់បក្ស ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** ដូច្នេះនេះមានន័យថា អ្នកអស់ទាំងហ្នឹងគឺត្រូវបានគេប្រហារជីវិតហើយ ដែលមិនត្រូវបានគេសួរចម្លើយទេ ។ តើនេះគឺជាអ្វីដែល ណាត បានប្រព្រឹត្តល្មើសនោះ តើគាត់ប្រព្រឹត្តខុសមកលើមាគ៌ានោះតាមរបៀបណា?

**ឆ៖** តាមគោលការណ៍ដែលខ្ញុំចេះ ខ្ញុំដឹង ខ្ញុំធ្វើតាំងពីម-១៣ មក គ្មានអ្នកណាមានសិទ្ធិចាប់មនុស្សទេ ទាល់តែខាងលើគេចាប់ប្រគល់ឲ្យមក បានមន្ទីរនគរបាលត្រូវទទួល ។ ក៏ប៉ុន្តែ ណាត ផ្ទាល់ខ្លួនគាត់ គាត់សម្រេចចាប់មនុស្សៗដោយខ្លួនចិត្តគាត់ហ្នឹង ដែលធ្វើឲ្យគាត់ភ័យខ្លួន ។ ដូច្នេះ គាត់ប្រើពាក្យដោះលែងហ្នឹង ដើម្បីលបដាន ។

[១៤:៣៩:១៥]

**សៈ** តើលោករកឃើញអំពីការភូតកុហកបែបនេះយ៉ាងដូចម្តេចទៅ ដែលថា ណាត គាត់ភរកុហកនេះ?

**ឆៈ** ទីមួយ នៅពេលដែលខ្ញុំធ្វើជាអនុប្រធានគេនៅឡើយ ខ្ញុំឮ យូ ប៉េងគ្រី ហៅ ម៉ុន ប្រាប់ខ្ញុំ ។ ប្រាប់ថា ណាត ឈ្លាសវៃណាស់ មនុស្សដែលប៉ងធ្វើឃាតគាត់ទាំងប៉ុន្មាន គាត់ចាប់ទាន់ពេលវេលា ។ ហើយ យូ ប៉េងគ្រី ប្រាប់ខ្ញុំទៀតថា វាបើកឡានបុកឡានអង្គការទាំងស្រស់ ។ ចំពោះ យូ ប៉េងគ្រី ពាក្យដែលយូ ប៉េងគ្រី ហៅអង្គការហ្នឹង គឺសំដៅ ណាត ហ្នឹងតែម្តង ។ នេះទីមួយដាច់ដោយឡែកទៅ ។

ទីពីរ ខ្ញុំឮដំណឹងហ្នឹង ខ្ញុំអត់សប្បាយចិត្តទេ ។ ខ្ញុំគិតថា ការចាប់មនុស្សល្មើសនឹងគោលការណ៍បែបនេះ គង់ថ្ងៃណាអង្គការដឹង ។ ហើយតែកាលណាអង្គការដឹង គេចាប់ ណាត វាដោយទាំងខ្ញុំពីបទស៊ុមគ្រលុំ ។ ដូច្នេះ ខ្ញុំពេលស្ងាត់តែពីរនាក់ សាកល្បងជួយមតិ ណាត ។ ខ្ញុំប្រាប់ ណាត ថា “បងអ្ហា! យើងសម្រេចខ្លួនឯងចាប់មនុស្សគ្រោះថ្នាក់ណាស់” ។ ណាត ឆ្លើយមកខ្ញុំភ្លាមថា “អ្ហឺ! រកធ្វើឃាតហើយ មិត្តថាមិនធ្ងន់? ខ្ញុំថាធ្ងន់ណ៎ា” ។ ពីរបីថ្ងៃក្រោយមក សុន សេន ហៅទៅធ្វើការទាំងពីរនាក់ ។ នៅរបៀបវារៈចុងក្រោយ ចប់ម៉ោងធ្វើការហើយ ណាត រាយការណ៍ជូនមេៗ ថាមានគេរកធ្វើឃាតគាត់ គាត់បើកឡានទៅឃើញ ឃើញរត់ចែកជើងគ្នា គាត់ជាន់ហ្គាឲ្យភ្លើងកាន់តែភ្លឺ ដល់កាលណាគាត់បើកភ្លើងឡានទៅ ក៏ឃើញមនុស្សពីរបីនាក់រត់ចែកជើងគ្នាព្រាត ។ ដល់អ៊ីចឹងទៅគាត់រាយការណ៍មិនទាន់ចប់ផង លោកគ្រូសុន សេន មេខ្ញុំ មេណាត ទាំងពីរនាក់ហ្នឹង ស្តីឲ្យតែម្តង វាហាក់ដូចជាគាត់ដឹងរឿងស្អីពីមុនមក។ គាត់ថា “ចាប់គេ សម្រេចចាប់គេដោយមូលហេតុសុវត្ថិភាពផ្ទាល់ គឺមហាបុគ្គល”ប៉ុណ្ណឹង ណាត ក៏ស្ងាត់នៅមិនហ៊ានតមាត់ ខ្ញុំក៏នៅស្ងៀម ។ តាំងពីថ្ងៃនោះមកខ្ញុំអត់មាត់អត់កទេ ព្រោះខ្ញុំដឹងថារឿងនេះមេជ្រាបហើយ ខ្ញុំអត់ភ័យទៀតទេ បើទោះថ្ងៃក្រោយយ៉ាងម៉េច ក៏គង់មេដឹងថាខ្ញុំអត់មានចូលជើងចូលដៃទេ ។

សាមសិបឆ្នាំក្រោយមកនៅពេលដែលសួរចម្លើយខ្ញុំ សហចៅក្រមស៊ើបអង្កេតសួរថា ទីមួយគាត់សួរថា “ពីខែដប់ពីរ ទៅដល់ខែបីមានប្រធានមួយឈ្មោះ សែន ?” ខ្ញុំជម្រាបលោកចៅក្រមលោកចៅក្រមថា “សែន គឺ ណាត” ។ ទីពីរគាត់សួរខ្ញុំទៀតថា “ជំនាន់ សែន គេមានដោះលែងមនុស្សប៉ុន្មាននាក់ ដប់ប្រាំបីនាក់ឯណោះណា ម៉េចទៅ?”

អត់ *កាត់ត្រឹវាំង* ទេណា ដប់ប្រាំបីៗនាក់ *(ជនជាប់ចោទ កែតម្រូវអ្នកបកប្រែ)*

[១៤:៤៥:២៤]

ដល់ទៅខ្ញុំឆ្លើយជម្រាបលោកចៅក្រមថា "អេ្ហ! ខ្ញុំមិនដឹងជា ហ៊ុយ វណ្ណៈ ហ្នឹងឈរលើឯកសារអី ដើម្បីនិយាយអ៊ីចឹងទេ" ។ ឮលោកចៅក្រមសួរអ៊ីចឹង ខ្ញុំនឹកឃើញដល់រឿងហ្នឹងហើយ ប៉ុន្តែវាអត់មានឯកសារអីជម្រាបបញ្ជាក់ជូនលោកចៅក្រម ។ ចៅក្រមស៊ើបអង្កេតទេ មិនមែនលោកចៅក្រមឡាវែន៍យើងនេះទេ ។ ដល់អ៊ីចឹង ខ្ញុំក៏នៅស្ងៀម ដល់ថ្ងៃក្រោយមក មានៗនៅក្នុងកំណត់ហេតុសួរចម្លើយលោកចៅក្រមប្រគល់ ហើយបន្ទាប់មកទៀតនៅក្នុងកំណត់ហេតុសួរចម្លើយខ្ញុំដែរ លោកចៅក្រមប្រគល់កំណត់សរសេររបស់បង ម៉ម ណៃ មកឲ្យខ្ញុំ ។ ដល់ប្រគល់សៀវភៅរបស់ ម៉ម ណៃ មកឲ្យខ្ញុំ ខ្ញុំបើកៗទៅ ថ្ងៃក្រោយមកខ្ញុំបើកទៅឃើញ ឃើញនៅទំព័រប៉ុន្មានៗដែលខ្ញុំសូត្រហ្នឹង ។

ខ្ញុំឃើញនៅទំព័រ ០០០៧៧-- ទំព័រហ្នឹងគឺទំព័រ ERN 00077978 ឃើញមានឈ្មោះមនុស្សប្រាំនាក់ មានស៊ីញ៉េ ណាត ច្បាស់លាស់នៅនុ៎ង ។ ខ្ញុំថា "អុញ! បានភស្តុតាងហើយ" ។ ដល់ក្រោយមកថ្មីៗនេះខ្ញុំបានទទួលបណ្តឹងរដ្ឋប្បវេណី គឺបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមរាប់ឈ្មោះម្តងទៀតចុះ បណ្តឹងរដ្ឋប្បវេណី E2/47 បណ្តឹងរដ្ឋប្បវេណី E2/55 ហើយនិង E2/56 ។ គាត់ថា ប្អូនកូនគាត់ គាត់ថា កូនគាត់-- គាត់និយាយថា "កូនគាត់ឈ្មោះ មិន កាន មានឈ្មោះថាដោះលែង ម៉េចក៏បាត់ដំណឹង?" ហើយ E2/55 គាត់ថា "បងគាត់ថា បងគាត់ឈ្មោះ បេង ពុំ ម៉េចក៏បាត់ដំណឹង បើដោះលែង?" ហើយ E2/56 គាត់ប្តឹងទៀត "គាត់ថា ឈ្មោះ យន់ លឿង ក្មួយកម្សត់របស់គាត់ ថាដោះលែងដែរ ម៉េចក៏អត់ឃើញ?" ។ ឥឡូវនេះឯកសារក៏មានហើយ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលចូលមកប្តឹងនេះ ខ្ញុំចាត់ទុកគេដូចជាសាក្សីអ៊ីចឹង ។ ដោះលែងតែបាត់គេ ។

សរុបមក ទិដ្ឋភាពនេះមួយដែលខ្ញុំសូមសន្និដ្ឋានថា ដោះលែងក្លែងក្លាយ តាមពិត គឺសម្លាប់គេចោលបាត់ហើយ ។ គ្មាននរណាប៊ានដោះលែងមនុស្សដែលគេចាប់ហើយ ចូលនគរបាលហើយៗគេចាត់ទុកជាខ្មាំងហើយ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអរគុណ ។ ឥឡូវម៉ោងសម្រាក អង្គជម្រះប្រកាសម្ភៃនាទីរហូតដល់ម៉ោងបីប្រាំនាទី អញ្ជើញចូលមកវិញ ដើម្បីបន្តសវនាការដេញដោល ។

*[សវនាការសម្រាកពីម៉ោង១៤:៥១ ដល់ម៉ោង១៥:១៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការ ។ សូមអញ្ជើញសហមេធាវីអន្តរជាតិ ។

**លោក វីល្យៀម ស្មីត៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមធ្វើការបញ្ជាក់ជូនដោយសង្ខេបទាក់ទងទៅនឹងការរៀបចំផែនការតាំងសំណួរទៅដល់ជនជាប់ចោទពីភាគី ចំពោះការយល់ឃើញរបស់ភាគី ។ ខ្ញុំចង់សុំសួរលោកចៅក្រម ទាក់ទងទៅនឹងការតាំងសំណួរទៅកាន់ជនជាប់ចោទ ទាក់ទងទៅនឹងស-២១ និងជើងឯករួមគ្នា ឬក៏អង្គហេតុទាំងពីរនេះ យើងតាំងសំណួរដាច់ដោយឡែកពីគ្នា ដើម្បីឲ្យយើងរៀបចំផែនការយើងបាន ។ ហើយខ្ញុំក៏ស្នើសុំសួរដែរ ប្រសិនបើការតាំងសំណួរនោះធ្វើការដាច់ចេញពីគ្នាហើយជនជាប់ចោទត្រូវសួរលើស-២១ មុនពេលទៅដល់ស-២៤ នោះ ។ ដូច្នេះ គឺយើងខ្ញុំជាភាគីចង់ធ្វើការលើកឡើងនិងសួរទៅដល់លោកចៅក្រមថា តើមាន-- ថាតើយើងខ្ញុំមានរយៈពេលប៉ុន្មាននៅក្នុងការតាំងសំណួរដើម្បីស្វែងរកការពិត?ដោយយើងចាំតែលើចំណុចសំខាន់នៃអង្គហេតុនេះ គឺទាក់ទងទៅនឹងប្រតិបត្តិការប្រចាំថ្ងៃរបស់ស-២១ ។

សហព្រះរាជអាជ្ញាក៏ស្នើសុំសួរដែរថា ប្រសិនបើអាចធ្វើទៅបាននោះ នៅពេលដែលលោកលោកស្រីចៅក្រមបញ្ចប់ការតាំងសំណួរ គឺវានឹងចំណាយរយៈមួយថ្ងៃដើម្បីធ្វើការពិនិត្យលើសំណួរដែលលោកលោកស្រីចៅក្រមបានសួររួច ដើម្បីឲ្យយើងខ្ញុំអាចធ្វើការតាំងសំណួរទៅកាន់ជនជាប់ចោទនៅក្នុងវិធីមួយដែលអាចទៅបានត្រឹមត្រូវ ។ ដូច្នេះ ការកម្រិតទៅលើរយៈពេលកំណត់ទាក់ទងទៅនឹងការតាំងសំណួរនោះគឺយើងត្រូវការមានការឈប់សម្រាករយៈពេលមួយចំនួន ដើម្បីធ្វើការពិនិត្យទៅលើសំណួរដែលបានតាំងហើយ ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

អរគុណ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានចោទសួរនូវសំណួរនេះឡើង ។ ហើយនេះក៏ជាបញ្ហានៅក្នុងចំណោមបញ្ហាដែលយើងប្រឹងប្រែងក្នុងការលើកឡើងមកពិភាក្សាជជែកវែកញែកគ្នានៅក្នុងអំឡុងពេលនៃការប្រជុំពិភាក្សារៀបចំសវនាការកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩មកដែរ ។ ប៉ុន្តែ ការពន្លាតនៃការជជែកនោះ ដោយសារពេលវេលាយើងមិនបានជជែកឲ្យអស់នូវបញ្ហានេះទេ ។

[១៥:២១:៣៨]

ទីពីរ ការគិតគូររបស់អង្គជំនុំជម្រះដោយសារដំណើរការប្រព្រឹត្តអម្បាញ់មិញនេះផង ហើយនិងមានសំណួរជាច្រើនដែលមានការពាក់ព័ន្ធចង់ឲ្យច្បាស់ហ្នឹងបញ្ហានេះផងនោះ ។ ជាក់ស្តែង គឺពេលនេះគឺលោកព្រះរាជអាជ្ញា តំណាងព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងអំពីបញ្ហានេះ ។ អ៊ីចឹង វាស្របជាមួយនឹងការគិតរបស់ខាងអង្គជំនុំជម្រះសាលាដំបូងដែរក្នុងគោលបំណងរិះរកមធ្យោបាយថាមធ្យោបាយណាដែលល្អ ដែលមានបែបផែនក្នុងការឈានទៅរកភាពយុត្តិធម៌ហ្នឹងបានល្អប្រសើរហើយនិងឆាប់រហ័ស។

ប៉ុន្តែ ដោយសារលក្ខខណ្ឌនៃបញ្ហានេះក៏មានលក្ខណៈស្មុគស្មាញដែរ នៅក្នុងការកំណត់របៀបរបបនៃការធ្វើដំណើរការសវនាការទៅមុខនេះ ។ អ៊ីចឹង អង្គជំនុំជម្រះសុំពេលថានៅចុងម៉ោងនេះបានន័យថាចប់ទៅ អង្គជំនុំជម្រះនឹងបើកកិច្ចប្រជុំផ្ទៃក្នុងម្តងទៀតដើម្បីជជែកវែកញែកជាផ្លូវការ ហើយនិងជូនព័ត៌មានដល់ភាគីនិងសាធារណជនទាំងអស់អំពីទម្រង់ការ ដែលយើងនឹងធ្វើការទៅមុខទៀតនៅក្នុងដំណើរការសវនាការនៃអង្គហេតុទាំងពីរ ។ គឺអង្គហេតុស-២១ ព្រមទាំងជើងឯក ហើយនិងអង្គហេតុស-២៤ ថា តើធ្វើយ៉ាងម៉េច?

បញ្ហាទីពីរ យើងនឹងបញ្ជាក់តាមសំណួររបស់លោកថា ប្រសិនបើតុលាការធ្វើតាមអង្គហេតុដែលបានកំណត់រួចហើយដោយមិនការកែប្រែទេថា រយៈពេលដែលទុកឲ្យភាគីនីមួយៗសម្រាប់សួរនោះយ៉ាងដូចម្តេច?

ប៉ុន្តែ តាមការគិតរបស់អង្គជំនុំជម្រះគឺបានកំណត់រួចហើយថា ដំណើរការសវនាការនេះគឺនឹងប្រព្រឹត្តទៅរហូតដល់អង្គជំនុំជម្រះ ការសួរដេញដោលចប់នូវអង្គហេតុនីមួយៗហើយទើបបានផ្តល់លទ្ធភាពជូនទៅភាគីដើម្បីមានឱកាសក្នុងការសួរ ។ ធ្វើដូច្នេះ អង្គជំនុំជម្រះគិតថានឹងបានឆាប់រហ័ស ហើយភាគីនឹងគឺបានកត់ត្រាទុក តាមដាននូវអ្វីដែលជាសំណួរឬក៏ឯកសារណាដែលខ្លួនយល់ឃើញថា នៅខ្វះចន្លោះដែលអាចបំពេញបន្ថែមឲ្យកាន់តែច្បាស់លាស់នៅក្នុងដំណើរការនេះ ។

នេះជាការគិត បញ្ហាគិតមួយទៀតនោះគឺបញ្ហាពេលវេលាទេ តើធ្វើយ៉ាងម៉េចសមស្រប ព្រោះការណែនាំអំពីព្រឹកមិញ យើងបានធ្វើការណែនាំនោះគឺក្នុងគោលបំណងនៃការស្តាប់សក្ខីកម្មរបស់សាក្សីទេ មិនមែនជាការស្តាប់ទៅលើជនជាប់ចោទចំពោះអង្គហេតុ ។ ដូចជាការសួរដេញដោលនេះ អង្គហេតុមានលក្ខណៈវែង មានលក្ខណៈធំ ។ អ៊ីចឹង បើយើងយកពេលវេលាព្រឹកមិញយកមកឆ្លើយតបជាមួយនឹងអង្គហេតុរបៀបនេះក៏មិនត្រូវដែរ ។ តែក៏យើងត្រូវគិតពិចារណា គួរតែគប្បីកំហិតពេលវេលាយ៉ាង

ម៉ែចឲ្យបានសមស្រប ។ អ៊ីចឹង គឺទទួលសំណូមពរនេះ ហើយនិងស្អែកអង្គជំនុំជម្រះនឹងប្រកាសជម្រាបជូនពីលទ្ធផលនេះ បន្ទាប់ពីសវនាការល្ងាចនេះអង្គជំនុំជម្រះនឹងបើកកិច្ចប្រជុំរបស់ខ្លួនហើយ ។

អញ្ជើញលោកមេធាវី ។

[១៥:២៤:៣៩]

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំនឹងឡើងមក ខ្លីទេ ។ ហើយខ្ញុំសូមជម្រាបដល់លោកប្រធានថា តំណាងឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ។ កាលពីថ្ងៃព្រហស្បតិ៍ លោកស្រីចៅក្រម ខាតវ៉ាយថ៍ បានសួរសំណួរដល់ក្រុមរបស់យើង ពួកយើងបានប្រជុំពិភាក្សាគ្នា ហើយបានលើកឡើងនូវចំណុច ទោះបីជាមិនបានឯកភាពគ្នាមួយរយភាគរយក៏ដោយ ។ គឺថាយើងខ្ញុំនឹងអាចបង្ហាញអំពីការសម្រេចរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា តើគួរតែបង្ហាញនៅពេលនេះ ឬក៏បង្ហាញនៅពេលសវនាការអសាធារណៈ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ចំពោះការលើកបង្ហាញដែលថាលោកបានជួបប្រជុំក្នុងចំណោមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពិភាក្សា អំពីសំណួរដែលបានលើកឡើងនៅក្នុងអំឡុងពេលសវនាការអសាធារណៈនៃកិច្ចប្រជុំលើការរៀបចំសវនាការ ។ នឹងអាចជាប្រយោជន៍ បើសិនជាលោកអាចប្រាប់ពួកយើងថាតើលោកបានឯកភាពគ្នាដល់កម្រិតណាហើយ? ហើយខ្ញុំក៏បានបង្ហាញផងដែរថា ខាងសហព្រះរាជអាជ្ញានិងមេធាវីការពារក្តី នឹងមានព័ត៌មានសម្រាប់ផ្តល់ឲ្យជូនដល់អង្គជំនុំជម្រះពីលទ្ធផលនៃការប្រជុំនោះ ប៉ុន្តែ ពួកគេមិនទាន់បានសម្រេចឲ្យបានចប់សព្វគ្រប់ក្នុងការផ្តល់ព័ត៌មានមកឲ្យខាងដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយទេ ។ បើសិនជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់ព័ត៌មានបាននេះគឺជាកាប្រសើរ។

[១៥:២៧:០២]

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកស្រីចៅក្រម ។ ដូចដែលលោកស្រីបានប្រាប់មកពួកអ៊ីចឹង គឺទាក់ទងទៅនឹងសេចក្តីសម្រេចចិត្តចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ដោយមិនបញ្ចូលទៅលើអ្នកដែលនៅរស់រានមានជីវិតនោះ ។ ក្រុមទាំងបួនរបស់យើងដែលជាក្រុមដើមបណ្តឹងរដ្ឋប្បវេណីនេះមានបំណងព្យាយាមកោះ

ហៅដើមបណ្តឹងរដ្ឋប្បវេណីចំនួនម្ភៃប្រាំបួននាក់ ។ ហើយមានសំណុំពាក្យមួយដែលនៅសល់នៅឡើយទេពីក្រុមទៅបួនរង់ចាំសេចក្តីសម្រេចពីអង្គជំនុំជម្រះ ។ ហើយនៅពេលប្រជុំយើងបានពិចារណាទៅលើចំណុចនេះ គឺពេលនោះយើងមានដើមបណ្តឹងរដ្ឋប្បវេណីចំនួនម្ភៃមួយ ដោយមិនរាប់បញ្ចូលអ្នកដែលនៅរស់រានមានជីវិត គឺប្រាំសម្រាប់ក្រុមទីមួយ ប្រាំបួនសម្រាប់ក្រុមទីពីរ បួនសម្រាប់ក្រុមទីបី និងបីសម្រាប់ក្រុមទីបួន ។

ព័ត៌មានដែលបានផ្តល់នៅមុនសេចក្តីសម្រេចចិត្តរបស់លោកស្រីចៅក្រមនោះ គឺនៅកាលពីខែកុម្ភៈ ការវាយតម្លៃនៅពេលនោះ យើងធ្វើការវាយតម្លៃថានឹងអាចមានត្រូវការចំណាយពេលហុកសិបម៉ោង ។ គឺម្ភៃប្រាំបីសម្រាប់ក្រុមទីមួយ ហើយសម្រាប់ក្រុមទីបីនឹងត្រូវស៊ីពេលម្ភៃប្រាំមួយម៉ោង ។ ប៉ុន្តែដោយៗយើងគិតថា យើងអង្គុយក្នុងសវនាការប្រាំម៉ោងក្នុងមួយថ្ងៃ មានន័យថាសម្រាប់ប្រាំគឺម្ភៃប្រាំងម៉ោង ។

ដូច្នេះកាលពីចុងសប្តាហ៍ពួកយើងបានពិនិត្យមើលឡើងវិញ ដើម្បីព្យាយាមកាត់បន្ថយឲ្យបានទៅតាមលទ្ធភាព ។ ខ្ញុំនិយាយនេះ គឺខ្ញុំនិយាយតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមហ្នឹង អ៊ីចឹងគឺយើងចុះពីហុកសិបម៉ោងមកនៅសល់សាមសិបម៉ោង ។ ដប់មួយម៉ោងក្រុមទីមួយ ដប់ប្រាំម៉ោងសម្រាប់ក្រុមពីរ និងក្រុមបី បួន ហើយនិងដប់មួយសម្រាប់ក្រុមទីបួន ហើយយើងគិតថាយើងមិនអាចកាត់បន្ថយម៉ោងឲ្យទាបជាងនេះបានទៀតទេ ពីព្រោះដើមបណ្តឹងរដ្ឋប្បវេណីគឺនិយាយតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួនកៅសិបបីនាក់ ។ ហើយនៅសម្រាប់ក្រុមទីបីហ្នឹង ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន គឺមកពីប្រទេសបារាំង ។

ដូច្នេះ យើងមិនអាចគិតថា យើងអាចកាត់បន្ថយពេលឲ្យក្រោមសាមសិបប្រាំពីរម៉ោងនោះទេ ។ អ៊ីចឹង នេះគឺជាការឯកភាពគ្នាមួយ ទោះបីជាមិនមួយរយភាគរយក៏ដោយក៏យើងអាចជម្រាបជាព័ត៌មានដល់លោក លោកស្រីចៅក្រមនៅពេលនេះ ។ ហើយបើសិនជាមានព័ត៌មានបន្ថែមទៀត យើងអាចបន្ថែមជូនទៅលោកស្រីដើម្បីឲ្យលោកស្រីធ្វើសេចក្តីសម្រេច ។

**ចៅក្រម ស៊ីលវ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណមេធាវី អាឡាំង វ៉ែនណឺ ។ តំណាងឲ្យអង្គជំនុំជម្រះ យើងនឹងពិចារណាទៅលើព័ត៌មានដែលបានប្រគល់ឲ្យនេះ ហើយនឹងជូនដំណឹងអំពីទស្សនៈរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងព័ត៌មាននេះ ។ ហើយយើងសូមអរគុណ ដែលថាដើមបណ្តឹងរដ្ឋប្បវេណីទាំង៤ក្រុម បានសម្រេចរហូត

មកដល់ត្រឹមនេះ ។

**ប្រធានអង្គជំនុំ៖**

មុននឹងបន្តកិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីឲ្យបានជ្រាបថា អង្គជំនុំជម្រះបានទទួលសំណូមពររបស់លោកមេធាវី ព្យែរ អូលីវីយេស័រ ដែលសុំឲ្យជំនួយការរបស់គាត់ឈ្មោះ ស៊ីសស៊ីកា ហ្វីណែល អង្គុយស្ដាប់នៅក្នុងបន្ទប់សវនាការ ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមការស្នើសុំនេះចាប់ពីពេលតទៅ ។ អ៊ីចឹង សូមជូនព័ត៌មាននេះដល់ក្រុមដែលមានលោក ព្យែរ អូលីវីយេស័រ ជាមេធាវីអន្តរជាតិ អាចចាត់ចែង លៃលក គឺឲ្យជំនួយការរបស់គាត់អាចចូលស្ដាប់និងកត់ត្រាព័ត៌មានផ្សេងៗនៅដំណើរការសវនាការ ដើម្បីផ្ដល់ជូនទៅលោកមេធាវី ព្យែរ អូលីវីយេស័រ តាមសំណូមពរហើយ ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមបន្តកិច្ចពិភាក្សា ដោយប្រគល់វេទិកានេះជូនទៅលោក។ អញ្ជើញមកទេ? គាត់អញ្ជើញមកទេ?

**លោក ហុង គីមសួន៖**

សូមជម្រាបលោកប្រធាន គាត់នៅអង្គុយបន្ទប់សាធារណៈខាងក្រៅនោះ ។ អ៊ីចឹង ស្អែកតទៅគាត់នឹងចូលអង្គុយ ។ អរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ ជាកិច្ចបន្តនេះសូមអញ្ជើញ ប្រគល់វេទិកានេះទៅចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តសំណួរដល់ជនជាប់ចោទអំពីអង្គហេតុដែលបានធ្វើសវនាការនេះ ។ សូមអញ្ជើញលោកចៅក្រម ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ឥឡូវនេះយើងនិយាយអំពីសំណួរទាក់ទងទៅនឹងការចាប់ខ្លួនទៀត ។ នៅពេលដែលយើងនិយាយអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយមានការយោងជាច្រើនទៅលើភាពសម្ងាត់ ការលាក់ការណ៍ ហើយសេចក្ដីសម្រេចក្នុងការចាប់ខ្លួនហ្នឹង គឺត្រូវបានធ្វើឡើងជាមុន ។ ហើយខ្ញុំចង់សួរទៅលោកថា តើមានការរៀបចំជាក់លាក់យ៉ាងណា? ដើម្បីធានាថា ការចាប់ខ្លួន និងអ្នកដែលត្រូវបានចាប់ខ្លួន ត្រូវបានធ្វើឡើងជាសម្ងាត់ ។ តើព័ត៌មានមិនពិតត្រូវបានប្រគល់ទៅឲ្យអ្នកនឹងត្រូវបានចាប់ខ្លួនឬ? តើអ្នកដែលត្រូវបានចាប់ខ្លួន ត្រូវបានផ្ដល់ព័ត៌មានក្លែងក្លាយឬ ដើម្បីបិទបាំងនូវការចាប់ខ្លួនរបស់ពួកគេនោះ?

[១៥:៣៣:៣៨]

**ឆ៖** លោកចៅក្រមជាទីគោរព! សំណួរលោកខ្ញុំយល់មិនបានគ្រប់ជ្រុងជ្រោយទេ ។ ខ្ញុំសាកល្បងជម្រាបជូនថា គោលការណ៍សំខាន់ គឺធ្វើម៉េចកុំឱ្យបែកការណ៍សម្ងាត់ ហ្នឹងជារឿងពិត ។ ឯចំណែកសាមីខ្លួនដែលត្រូវគេចាប់ចងនោះ អត់ដឹងខ្លួនទេ ។ ឯចំណែកសេចក្ដីសម្រេចចិត្តសុទ្ធតែខាងលើសម្រេច ។ ខាងក្រោម កាលណាខាងលើសម្រេចហើយ ខាងក្រោមត្រូវតែអនុវត្តឱ្យបានគត់មុត ។ និយាយថា ធ្វើម៉េចកុំឱ្យបែកការណ៍ ធ្វើម៉េចកុំឱ្យរត់រួច ធ្វើម៉េចកុំឱ្យតដៃបាន ។ ខ្ញុំគ្រាន់តែសូមបញ្ជាក់បន្ថែមមួយម៉ាត់ថា អ្នកណាដែលគ្មានសមត្ថកិច្ចកម្ទេចទេ អ្នកឯងហ៊ានសម្រេចចាប់ អ្នកឯងត្រូវមានរឿង ។ ហេតុដូច្នេះហើយបានជា ណាត សម្រេចចាប់មនុស្សទទឹងទទែងមិនសុំយោបល់ខាងលើ គាត់ត្រូវតែកាយកប់លុបដាន ។ ហើយជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលនៅមានហ្នឹងក្នុងឯកសារនេះបង្ហាញឱ្យឃើញថា គាត់ត្រូវខាងលើចាប់អារម្មណ៍ ។ ប៉ុន្តែ បើសិនជាខ្ញុំជម្រាបរឿងនេះដល់លោកចៅក្រមឥឡូវនេះ ខ្ញុំសង្ស័យវាចាកប្រធាន ដូច្នេះខ្ញុំសូមមិនទាន់ជម្រាបទេ ។ កាលណាលោកចៅក្រមសួរបញ្ជាក់ ខ្ញុំនឹងជម្រាប ។ ក៏ប៉ុន្តែ ដូច្នេះខ្ញុំសូមបញ្ចប់ចម្លើយខ្ញុំប៉ុណ្ណេះ ហើយបើខ្វះខាតយ៉ាងម៉េច សូមលោកចៅក្រមមេត្តាសួរបន្ថែម ។

**ស៖** មានចំនួនអ្នកដែលត្រូវបានចាប់ខ្លួនជាច្រើន គឺអ្នកដែលត្រូវបានចាប់ខ្លួនតែឯកឯង ឬអ្នកដែលមានឋានៈខ្ពស់ ដូចដែលលោកបាននិយាយអ៊ីចឹង អ្នកខ្លះត្រូវបានចាប់ខ្លួននៅឯងផ្ទះរបស់លោក ហើយក៏មានករណីខ្លះដែលមនុស្សជាច្រើនត្រូវបានចាប់ទាំងឈុតតែម្ដង គឺខ្ញុំនិយាយយោងទៅលើអ្នកដែលត្រូវបានចាប់ខ្លួននៅក្នុងកងពលរបស់យោធា ឬក៏នៅក្នុងកងវរសេនាធំ ដែលមនុស្សជាច្រើនត្រូវបានចាប់ខ្លួននៅពេលដំណាលគ្នា ។ តើលោកអាចផ្ដល់ឧទាហរណ៍ឱ្យយើងបានខ្លះបានទេ និងបញ្ជាក់ប្រាប់ឱ្យស្ដាប់បានខ្លះទេថា តើការរៀបចំជាក់លាក់ណាមួយត្រូវបានធ្វើឡើង ដើម្បីធានាថា ព័ត៌មានទាក់ទងទៅនឹងការចាប់ចងទាំងនេះ គឺថាព័ត៌មានទាំងអស់ហ្នឹង មិនត្រូវបានផ្សព្វផ្សាយដល់សមាជិកគ្រួសារអ្នកដែលត្រូវបានចាប់ខ្លួន ឬក៏ទាហានដែលមានឋានន្តរសក្តិនោះ?

[១៥:៣៨:០១]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំយល់ឃើញថា សំណួររបស់លោកចៅក្រមសំដៅអំពីការឃាត់ខ្លួនជាទូទៅ ។ ការឃាត់ខ្លួនជាទូទៅត្រូវតែធ្វើតាមក្របខ័ណ្ឌអំណាច នៅក្នុងកងទ័ពមជ្ឈិម គឺលេខាសេនាធិការជាអ្នកសម្រេច ។ ដល់កាលណាគេសម្រេចហើយ អ្នកខាងក្រោមធ្វើយ៉ាងម៉េច

ខំណាស់កុំឲ្យវាបែកការណ៍ ។

ឧទាហរណ៍ ការសម្រេចទៅទទួលមនុស្សពីកងពល១៧០ និង២៩០ ។ ដល់កាលណាយកចេញមក គឺខាងណោះគេអ្នកដោះស្រាយហើយ សម្ងាត់នៅក្នុងអង្គភាពគេ សំខាន់ស្រេចតែគេមិនមាត់ ។ នេះជារឿងការសម្ងាត់ដែលគេរក្សានៅក្នុងអង្គភាពគេ ។ ឯចំណែកខាង ស-២១វិញ រក្សាសម្ងាត់ គឺមិនឲ្យកងការពារ ពួកអ្នកសួរ ទាក់ទងជាមួយនឹងអង្គភាពផ្សេងទៀត ។ ដូច្នេះ ការទាក់ទងរបស់អង្គភាពណាក៏ដោយ ជាពិសេសស-២១ ជាមួយនឹងអង្គភាពផ្សេងទៀត ជារឿងដែលហាមឃាត់ ។ អ្នកណាដែលចេញទៅទាក់ទងធ្វេចធ្វាច ខុសបែបបទសុទ្ធតែត្រូវសង្ស័យ ។ នេះ គឺសូមជម្រាបបញ្ជាក់ច្បាស់លាស់អ៊ីចឹង ។

**ស៖** ថាតើមានលេសណាឲ្យមានយល់ដល់ការយល់ច្រឡំនៅក្នុងចំណោមប្រជាជន ដើម្បីចាប់ពួកគេដែរឬទេ? ឧទាហរណ៍ថា លោកទៅចូលរួមវគ្គអប់រំ ឬក៏ទៅជួបបុគ្គលណាមួយ គឺថាលេសនោះគឺនាំឲ្យមានការយល់ច្រឡំ នេះជាការអនុវត្តទូទៅ ឬយ៉ាងម៉េច?

**ឆ៖** ដែលលោកមានប្រសាសន៍សួរថា យកលេស ក្លែងក្លាយ នេះជារឿងពិត បក្សកុម្មុយនីស្តកម្ពុជា គេហៅអាហ្នឹងថាយុត្តិវិធី។ ។ គេប្រើរហូតអាយុទ្ធវិធីហ្នឹង ដូច ប៉ង់, ឈឹម សំអោក ហៅ ប៉ង់ គាត់ដើរមកឲ្យស-២១ ចាប់តាមបញ្ជា នួន ជា ។ គាត់ឲ្យ ប៉ង់ យកឯកសារចម្លើយសារភាពមួយមកសួរបញ្ជាក់ខ្ញុំ ។ រួចខ្ញុំបានដឹងដំណឹងថា បើ ប៉ង់ មកម៉ោងប៉ុណ្ណេះ គឺពិតជាត្រូវចាប់ ។ កុយ ធួន មក ប៉ង់ ក៏មកដែរ ។ ប៉ុន្តែ មិនដឹងកាលណោះ គេលើពាក្យស្លោកម៉េចទេ កុយ ធួន ចូលមកដល់ ពួកស-២១ចាប់គ្រឹប ។ ជាទូទៅ គេលើកពាក្យស្លោកឲ្យហៅយកទៅរៀន ជួនអីហៅទៅធ្វើការ ។

ដូច្នេះ សរុបមក របៀបបង្វែងដានគេធ្វើរហូតគ្មានដែលនិយាយត្រង់ទេ ។

**ស៖** ដូច្នេះ និយាយជាទូទៅបុគ្គលទាំងអស់ត្រូវបានការចាប់ខ្លួន ហើយមានការភ្ញាក់ផ្អើល។ នៅពេលដែលពួកគេត្រូវបានគេចាប់ខ្លួន តើគេមានប្រាប់អ្នកទាំងអស់នោះថាហេតុអ្វីបានជាត្រូវគេចាប់ខ្លួន?

[១៥:៤៤:០៨]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! មិនដែលប្រាប់ទេ។ អ្នកសួរចម្លើយដែលយើងខ្ញុំប្រគល់មនុស្សទៅឲ្យសួរហ្នឹង ក៏មិនប្រាប់ ។ វាគ្រាន់តែខ្លះគេកាន់កាប់សំណុំរឿងនេះពីមុនមក គេយល់ជ្រុងជ្រោយ ។

**ស៖** ហើយនិយាយជាទូទៅការបញ្ជូនអ្នកទោសពីកន្លែងដែលចាប់ខ្លួនចូលមកស-២១ ថាតើការបញ្ជូននិងដឹកនោះ គឺធ្វើឡើងនៅពេលដែលមានមនុស្សតិច? ថាតើវាធ្វើនៅយប់ ឬក៏ធ្វើឡើងនៅពេលថ្ងៃ ហើយវាមានការធ្វើការឲ្យបែកការណ៍ដែរឬទេ?

[១៥:៤៥:២៥]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បញ្ហានេះ ខ្ញុំភ្លេចអស់ហើយ មិនអាចឆ្លើយមួយម៉ាត់បានទេ ប្រហែលជាអាចគិតដល់ពេលណាដែលស្ងាត់មែន ។ សូមបញ្ជាក់ថា ភ្នំពេញជំនាន់នោះស្ងាត់ណាស់ អត់មានមនុស្សអ៊ូអែនៅតាមផ្លូវទេ ។

**ស៖** យើងចូលទៅដល់ចំណុចមួយទៀត ទាក់ទងទៅនឹងស្ថានភាពនៃការឃុំខ្លួន ។ លោកបានលើកឡើងម្តងនោះថា នៅពេលដែលអ្នកទោសចូលមកស-២១ អ្នកទាំងអស់នោះត្រូវបានគេប្រាប់ឲ្យដោះខោអាវ ហើយបន្ទាប់មក គឺពួកគេនៅសល់តែខោខ្លី ហើយតើចាំបាច់មានការដោះខោអាវធ្វើអ្វី?

**ឆ៖** មិនច្បាស់ទេ ខ្ញុំមិនច្បាស់ទេ។ ប៉ុន្តែ តាមការពិតមាននៅសល់ខោអាវនៅហ្នឹងជាជម្លួស ។ ដូច្នេះ ខោអាវហ្នឹងមិនដឹងជាគេយកទៅធ្វើស្អីទេ តាមពិតគ្មានអ្នកណាយកមកប្រើទេ ។ ខ្ញុំសូមរំឭកព្រឹត្តិការណ៍មួយដែលខ្ញុំភ្លេច ។ ប៉ុន្តែ ឥឡូវខ្ញុំនឹកឃើញរឿងមួយ ជាពិសេសអ្នកដែលចូលមកស-២១ ហ្នឹងបើស្លៀកពាក់ខោអាវខ្មៅ ជាឯកសណ្ឋានអ្នកបដិវត្តន៍ គេដកហើយដល់ក្រោយមក គេឲ្យខោពណ៌ខោបារាំង ខោឡេវ អាវក្រឡេក្រឡាអី ជាអាវសីមី ទៅវិញ ។ នេះមានមួយបែប ។ ប៉ុន្តែ ធ្វើរបៀបនេះមិនដឹងជាមានប៉ុន្មាននាក់ទេ បែបមានតិចទេ ។ រួចបានជាខ្ញុំលើកបញ្ហានេះ មកនិយាយព្រោះខ្ញុំចាំ ។ ខ្ញុំចាំម្យ៉ាង ឈ្មោះ ញ៉ែម សឿន ដល់ផ្លាស់ខោអាវឲ្យគាត់ គាត់មិនព្រម គាត់ស្រែកចំទាល ទារយកអាខោអាវខ្មៅទៅស្លៀកវិញ ។ ដូច្នេះ ខ្ញុំសូមនិយាយនេះ ក្នុងឋានៈជាមនុស្សម្នាក់ដែលនៅចាំព្រឹត្តិការណ៍ហ្នឹងព្រាលៗ មិនដឹងជាគេអនុវត្តយ៉ាងម៉េច ពីខោអាវចាស់ ខោអាវអីហ្នឹង ខ្ញុំអត់មានបានគិតទេ ។ នេះសូមជម្រាបប្រសាសន៍លោកចៅក្រមប៉ុណ្ណេះ ។

**ស៖** ទាក់ទងទៅនឹងម្ហូបអាហារ លោកបាននិយាយអម្បាញ់មិញប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះលោកបានលើកឡើងថា ម្ហូមមិនគ្រប់គ្រាន់ ។ នេះគឺជាអ្វីដែលលោកបានលើកឡើង តើត្រឹមត្រូវដែរឬទេ? ហើយលោកក៏បានលើកឡើងផងដែរ នៅតាមជនបទផ្សេងៗ គឺវាមានការលំបាកក្នុងការយកអាហារនិងមានម្ហូបអាហារ ហើយខ្ញុំចង់សួរលោក នៅក្នុងការយល់ឃើញរបស់លោក ចំពោះបញ្ហាអ្នកទោសមិនមានអាហារគ្រប់គ្រាន់ហូបនោះ ។ ថាតើករណីនេះ គឺដោយសារតែវាជាការអនុវត្ត និងគោល

នយោបាយ ហើយវាជាចេតនាផ្ទាល់ ឬក៏វាជាគោលបំណងផ្ទាល់តែម្តង? ឬក៏វាបណ្តាលមកពីបញ្ហារៀបចំការចាត់តាំងទៅលើបញ្ហាទាំងអស់នេះ?

**ឆ៖** សូមជម្រាបលោកចៅក្រម! បញ្ហាម្ហូបអាហារនេះ ខ្ញុំនិយាយអម្បាញ់មិញវាមានលក្ខណៈទូទៅហើយ គឺមិនមានម្ហូបអាហារគ្រប់គ្រាន់សម្រាប់ទូទាំងប្រទេស។ ដោយឡែកអ្នកទោសកាន់តែរងគ្រោះថ្នាក់នេះ ជាងប្រជាជនធម្មតាទៅទៀត ។ ដូច្នេះ នេះជានយោបាយទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ក៏ប៉ុន្តែ ឯកសារខ្ញុំថ្មីៗឃើញឯកសារត្រង់ណាមួយទេ គេចែងថា កម្លាំងប្រយុទ្ធរបស់គេខ្លាំងក្លាបំផុតនោះមួយថ្ងៃដប់នាក់ អង្ករម្តៃបីកំប៉ុង ។ នេះ គឺកំណត់អ៊ីចឹងហ្នង ដូច្នេះកម្លាំងស្រួចផុតលេខរបស់គេ ម្តៃបីកំប៉ុងក្នុងរយៈកាលមួយថ្ងៃសម្រាប់ដប់នាក់ ។ ដូច្នេះ កម្លាំងអ្នកទោសប៉ុន្មានកំប៉ុង គេមានកំណត់ ។

**ស៖** តើលោកបានដឹងដែរឬទេ ថាលោកបានអនុវត្តគោលនយោបាយមួយដែលមានគោលបំណងក្នុងការផ្តល់ម្ហូបអាហារមិនគ្រប់គ្រាន់ដល់អ្នកទោស ។ តើលោកដឹងថា លោកអនុវត្តគោលនយោបាយនៃការខ្វះអាហារចំពោះអ្នកទោសនោះទេ?

**ឆ៖** បើនិយាយពីដឹងខ្ញុំដឹង ក៏ប៉ុន្តែបើនិយាយពីការឈឺចាប់ វាឈឺចាប់ វាហួសចិត្តៗ ។ តែមិនដឹងធ្វើម៉េច នេះជារឿងពិត ។

**ស៖** នៅពេលមួយនោះ ថាតើលោកមានដែលទទួលរងគ្រោះដោយសារមិនមានអាហារគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** ផ្ទាល់ខ្លួនខ្ញុំនៅក្នុងអង្គភាពស-២១ ខ្ញុំហូបបាយមួយពេល មួយកូនចានចង្អឹះ ហើយម្ហូបគេគ្រាន់តែអនុគ្រោះឲ្យខ្ញុំមានពីរមុខ ម្នាក់ឯងគត់មួយស-២១ គ្នាប៉ុន្មានរយនាក់ ប៉ុន្មានពាន់នាក់ហ្នឹងមានតែម្នាក់ឯងគត់ទេដែលមានម្ហូបពីរមុខ ។ ហើយម្ហូបតិចៗទេ រួចខ្ញុំសូមជម្រាបលោកចៅក្រមថា ពេលនោះទម្ងន់ខ្ញុំមានត្រឹមតែសែសិបប្រាំបួនគីឡូក្រាមទេ ។

**ស៖** តើលោកអាចនិយាយថា គោលនយោបាយនោះ គឺវាមានផលប្រយោជន៍ដែរឬទេ? បានន័យថា វាមានផលប្រយោជន៍ក្នុងការធ្វើឲ្យអ្នកទោសនោះ កាន់តែចុះខ្សោយ ហើយធ្វើឲ្យមានភាពខ្វះអាហារ និងការខ្វះអាហារផ្សេងៗ ដើម្បីឲ្យងាយស្រួលក្នុងការគ្រប់គ្រង?

**ឆ៖** ការឲ្យម្ហូបអាហារមិនគ្រប់គ្រាន់នេះ វាពិតជានាំឲ្យសុខភាពហើយនិងកម្លាំងកាយដុនដាប។ ដូច្នេះ វាស្រួលគ្រប់គ្រងដែរ មួយផ្នែកវាស្រួលគ្រប់គ្រង ។ ក៏ប៉ុន្តែ ចិត្តគេដែលអត់បាយស៊ី គប្បីជួនល្អ

ហើយដែលគេមិនបះបោរ ។ នេះជារឿងពិត ដូច្នេះហើយបានជាវាមានបទប្បញ្ញត្តិ ដែលមិត្តហ៊ ដែលគាត់សរសេរសារាចរ ងើបស្អីសុំ ស្អីសុំឯណានោះ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១៥:៥៥:៥៨]

**ស៖** ទាក់ទងទៅនឹងបទបញ្ជានោះ ថាតើអ្នកទោសគាត់មានសិទ្ធិក្នុងការនិយាយបញ្ចេញយោបល់ទេ នៅពេលដែលពួកគេត្រូវបានជាប់ខ្នោះនោះ?

**ឆ៖** តាមពិតអ្នកដែលជាប់ឃុំឃាំង គ្មានសិទ្ធិនិយាយគ្នា ជជែកគ្នាទេ ។ ក៏ប៉ុន្តែ រឿងនេះ មានពេលខ្លះអ្នកយាមខ្លះទៅគេយោគយល់ គេចិត្តទូលាយទៅ គ្នាគ្រាន់បានធូរខ្លះ ។

**ស៖** ថាតើអ្នកទោសមានសិទ្ធិក្នុងការផ្លាស់ទីកន្លែង មានសិទ្ធិឈរ ឬក៏ពួកគេអត់មានសិទ្ធិក្នុងការធ្វើចលនាផ្លាស់ប្តូរទីកន្លែងអ្វីទាំងអស់?

**ឆ៖** អ្នកជាប់ខ្នោះត្រូវដេកឲ្យស្ងៀម បើចង់អង្គុយៗទាល់តែសុំអនុញ្ញាតគេ ឬមួយគេឲ្យអង្គុយតាមពេលវេលាគេកំណត់ អាហ្នឹង វាមានមែន ។

**ស៖** មុននេះលោកបាននិយាយថា អ្នកទោសនៅស-២១ ត្រូវបានប្រព្រឹត្តដូចសត្វអ៊ីចឹង ហើយលោកប្រើប្រាស់ឃ្លានោះថា ត្រូវបានគេប្រព្រឹត្តលើដូចសត្វអ៊ីចឹង ។

តើលោកបានដឹងដែរឬទេថា ស្ថានភាពបែបនោះ គឺវាអាចបង្កឲ្យមានការធ្លាក់ចុះនូវផ្នែកផ្លូវអារម្មណ៍ផ្សេងៗ ហើយថាតើលោកមានការរៀបចំណាមួយដើម្បីធ្វើការចាត់ចែងទៅលើបញ្ហានោះដែរឬទេ? ដើម្បីធ្វើការរកវិធីសាស្ត្រក្នុងការដោះស្រាយទៅលើបញ្ហាធុញថប់ផ្លូវអារម្មណ៍នោះ?

**ឆ៖** សូមជម្រាបលោកចៅក្រម! រឿងដែលចាត់មនុស្សដូចជាសត្វ វាមានទិដ្ឋភាពគ្រប់ទាំងអស់ ជាពិសេសពាក្យដែលនិយាយទាក់ទងជាមួយនឹងជនរងគ្រោះដែលមកនៅជាប់ទោស ។ ក្មេងៗទៅហៅមនុស្សចាស់ អា, អ្អែង ។ ដូច្នេះ វាគិតសព្វៗទៅ វាជារឿងមួយនឹកឡើងដល់រឿងនោះពេលណា វាអាម៉ាស់ខ្លួនឯងពេលនោះ ។ ផ្ទាល់ខ្លួនខ្ញុំគិតបានត្រឹមតែចៀស មិនទៅជិត ។ ចៀសបានប៉ុនន៉ុង នឹងថាឲ្យមានផែនការលុបបំបាត់ពាក្យគ្រោតគ្រាតបែបនេះមិនបាន ព្រោះតែកាលណាយើងបានធ្វើគេថាយើងគ្មានទស្សនៈបែងចែកឲ្យច្បាស់លាស់រវាងមិត្ត-សត្រូវ ។ អ្នកឯងទុកសត្រូវជាមិត្ត បើអ្នកឯងចាត់ទុកសត្រូវជាមិត្តហើយ មិត្តឯងគ្មានជំហរវណ្ណៈទេ ។ ឥឡូវ មិត្ត ឯងបក្ខជនមែនឬមិនមែន? ដល់គេដាក់មកប៉ុណ្ណឹងយើងទាល់ច្រកហើយ។ ដូច្នេះ វិធានការមានតែមួយទេ គឺគេចមិនទៅជួប ។ ជួបវាក្អកវាក្អួលវាឈឺចាប់ វាហួសចិត្តដោះស្រាយមិនបាន ជួបធ្វើអី ។

សរុបមក ខ្ញុំបាទគ្មានបានរៀបចំផែនការអី ដើម្បីដោះស្រាយបញ្ហានេះទុកឲ្យវាទៅអ៊ីចឹង នេះហើយជាមាគ៌ាវណ្ណៈ ។

**ស៖** មិនត្រឹមតែថា លោកមិនបានចាត់វិធានការដើម្បីធ្វើឲ្យផ្លាស់ប្តូរស្ថានភាពនោះទេ? តើលោកមានបានចាត់វិធានការ ដើម្បីបង្ការចៀសវាងនូវភាពតានតឹង ដែលបណ្តាលឲ្យទទួលបានលទ្ធផលនូវចុងបញ្ចប់នោះ? ហើយដែលថាជនជាប់ឃុំឃាំងនឹងអាចត្រូវបានធ្វើអត្តឃាតដោយខ្លួនឯងដោយសារតែបញ្ហាតានតឹងអារម្មណ៍ផ្លូវចិត្តនេះ?

**ឆ៖** គិតដែរ ប៉ុន្តែ ដើម្បីទប់ទល់ជនជាប់ឃុំខ្លះដែលមានសារសំខាន់កុំឲ្យធ្វើអត្តឃាត ខ្ញុំប្រើវិធានការកម្លាំងទៅវិញទេ យកកម្លាំងជាធំ ពឹងផ្អែកលើកម្លាំងជាធំ ។ ឧទាហរណ៍ ការឃុំខ្លួន និងការសួរចម្លើយ កុយ ធួន ។ នៅនឹងបន្ទប់ដែលឃុំឃាំង កុយ ធួន ហ្នឹងមានកងពិសេសពីរនាក់នៅប្រចាំការជាប់ ហើយខ្ញុំដាក់ *កុំប៉ីណេ* ទូរស័ព្ទឲ្យមួយ។ កាលណាបើមានប្រតិកម្មឲ្យគេវាយទូរស័ព្ទមកខ្ញុំជាបន្ទាន់ ។ ហើយដល់កាលណាគាត់ឈប់ប្រតិកម្មនៅមួយសន្ទុះ ប្រហែលជាកន្លះម៉ោងទៅមួយម៉ោងបានខ្ញុំទៅជួបគាត់ ។

ដូច្នេះ សរុបមកវិធានការកុំឲ្យ កុយ ធួន ធ្វើអត្តឃាត ហើយឲ្យគាត់ខំសារភាព ខ្ញុំប្រើគ្រប់មធ្យោបាយក៏ពិតមែន ឲ្យគាត់សម្រាន្តឲ្យស្រួល បានហូបឆ្ងាញ់គួរសម ប្រហាក់ប្រហែលនឹងយើងខ្ញុំដែរ ។ ខ្ញុំទៅជួបគាត់តែម្នាក់ឯងទេ គ្មានអ្នកណាប៊ានទៅនិយាយជាមួយ កុយ ធួន ទេ ។ ខ្ញុំហៅគាត់សុទ្ធតែបង ។ ធានាខ្លួនជាអ្នកបញ្ជូនសេចក្តីសារភាពរបស់គាត់ទៅឲ្យអង្គការ ខ្ញុំអត់ប៊ានមើល អត់ធ្វើដឹងអីទេ ។ នេះប្រើគ្រប់មធ្យោបាយអ៊ីចឹង តែសំខាន់ គឺអាងលើកងពិសេសពីរនាក់នោះទៀត ដែលនៅប្រចាំការជាប់ ។ នេះជាវិធានការតែមួយគត់នៅក្នុងមួយជីវិតស-២១ ដែលខ្ញុំធ្វើបានដូច្នេះ ។ ដូច្នេះនៅស-២១ ពិតជាមានអ្នកធ្វើអត្តឃាតដោយយើងគ្រប់គ្រងមិនជាប់ ។

[១៦:០៦:២៨]

**ស៖** ពីមុនលោកបាននិយាយថា នៅពេលណាមួយនោះគ្រួសារទាំងមូលនឹងត្រូវបានឃុំខ្លួននៅស-២១ គឺទាំងឪពុក ទាំងប្តី ទាំងប្រពន្ធ ទាំងបងប្អូន ទាំងកូនក៏អាចត្រូវបានឃុំខ្លួននៅស-២១ ផងដែរ ។ តើមានកើតឡើងមែនទេ មានកើតឡើងដូចគ្នានេះដែរទេ ដែលថាព័ត៌មាននឹងត្រូវបានផ្លាស់ប្តូរនៅពេលដែលសមាជិកនៃគ្រួសារនោះបានទាក់ទងគ្នានោះ?

**ឆ៖** ស-២១ ប្រយ័ត្នជាពិសេស ទាំងខ្ញុំ ទាំងគេ ទាំងកងការពារ គេប្រយ័ត្នបញ្ហានេះណាស់ មិនឲ្យទាក់ទងគ្នាបានទេ ។ ជាពិសេសប្តី និងប្រពន្ធមិនឲ្យទាក់ទងគ្នាទេ មិនឲ្យដឹងគ្នាផង ។

**ស៖** តើលោកឯកភាពទេថា ជាទូទៅ គឺមានបរិយាកាសនៃការភ័យខ្លាច និងសេចក្តីវន្ធត់ដែលត្រូវដាក់គ្របដណ្តប់មកលើអ្នកជាប់ឃុំឃាំងទាំងអស់នោះឬ?

**ឆ៖** ប្រាកដណាស់ សូមជម្រាបលោកចៅក្រមដោយស្មោះថា ប្រាកដ ។

**ស៖** លោកបាននិយាយថា លោកម្តងម្កាលបានទៅមើលមន្ទីរឃុំឃាំងនោះ តើជួនកាលលោកមានបានឮអ្នកទោសស្រែកដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កន្លែងឃុំឃាំងរួមនៅលីសេពញាយ៉ាត ខ្ញុំអត់ចូលទេ ខ្ញុំអត់ចូលទាល់តែសោះ ។ មិនមែននេះទេ គឺខ្ញុំមិនបានចូលទៅក្នុងកន្លែងឃុំឃាំង ឯចំណែកក្នុងបរិវេណលីសេពញាយ៉ាត ខ្ញុំចូលទៅកន្លែងរោងជាង គួរហើយនិងឆ្លាក់ ចូលទៅអង្គុយសំកុកនឹងមែន ។

ឯចំណែកគុកពិសេស ខ្ញុំចេញចូលនៅពេលសួរចម្លើយ កុយ ធួន ញឹក ។ ខ្ញុំចូលទៅកន្លែងមិត្តប៉ុន សួរចម្លើយទៅ ជួបបង តូច ភឿន ដូចខ្ញុំរាយការណ៍ព្រឹកមិញអ៊ីចឹង ។ តូច ភឿន ហើយទៅជួបជនជាតិអង់គ្លេសនោះមួយភ្លែត ។ ហើយបើកន្លែងសួរចម្លើយវៀតណាមដែលបង ម៉ម ណៃ គាត់កាន់កាប់ ខ្ញុំទៅញឹក ទៅណែនាំគោលជំហរនៃការសួរផង ជាពិសេសណែនាំគោលជំហរនៃការសួរដើម្បីយកចម្លើយផ្សាយវិទ្យុ ហើយនិយាយដូចនិយាយច្រំដែលទេ ខ្ញុំចង់ទៅមើលមុខ ចៅ សេង បន្តិចដែរ គាត់នៅនុ៎ង ។

ដូច្នេះ ខ្ញុំសូមជម្រាបបញ្ជាក់ថា ខ្ញុំចូលកន្លែងគុកនេះ ចូលបានតែគុកពិសេសប៉ុន្មានកន្លែងហ្នឹងឯង ។ ដូច្នេះ ការឮអ្នកទោសស្រែក ខ្ញុំមិនដែលបានឮទេ ។ ខ្ញុំទៅហ្នឹងក្នុងបរិយាកាសដែលគេរៀបចំស្ងប់ស្ងាត់ហើយទេ ។ សូមបញ្ចប់ត្រឹមនេះ។

**ស៖** តើមានរឿងកើតឡើងចំពោះលោកទេម្តងម្កាល នៅពេលដែលលោកមានអារម្មណ៍ប៉ះពាល់ដោយសារតែក្លិនស្អុយ និងស្ថានភាពដ៏គគ្រិចដែលអ្នកជាប់ឃុំឃាំងត្រូវបានឃុំឃាំងខ្លួននោះ តើលោកមានដែលមានអារម្មណ៍បែបនោះទេ?

**ឆ៖** ជម្រាបប្រសាសន៍ចៅក្រម! ក្លិន១ដែលយ៉ាប់ហ្នឹង ពិតជាមាន ។ មិនដឹងជាក្លិនហ្នឹងវាប៉ះពាល់ដល់សុខភាពយ៉ាងម៉េច? តែវាមានខ្លះ តែខ្ញុំអត់បានចូល ដូច្នេះ ខ្ញុំវាងួចខ្លួនដែលមិនបានធុំក្លិនហ្នឹង ។ នេះសូមជម្រាបដោយត្រង់ ។ រឿងដែលខ្ញុំមិនបានចូលនេះមិនមែនមកពីខ្លាចក្លិនទេ ដឹងហើយរឿងក្លិន

វាខ្លាំង ក៏ប៉ុន្តែ មិនមែនមកពីខ្លាចក្លិនទេ សំខាន់គឺអ្នកដែលនៅជាប់នុំង ភាគច្រើន ច្រើនតែអ្នកដែលខ្ញុំស្គាល់ពីមុនមក ។ តើខ្ញុំទៅឃើញមុខគេ តើខ្ញុំត្រូវធ្វើទឹកមុខយ៉ាងម៉េច? ខ្ញុំទៅនិយាយបន្ថែបន្ថំបោកប្រាស់ចិត្តខ្លួនឯងយ៉ាងម៉េច? ដូច្នេះហើយ ដែលខ្ញុំគេចចូល គឺរឿងមនុស្សដែលខ្ញុំធ្លាប់ស្គាល់ មិនចង់ឲ្យឃើញមុខ នៅក្នុងពេលដែលគាមករងកម្មនៅកន្លែងខ្ញុំអ៊ីចឹងទេ នេះ ។ ដូច្នេះ ខ្ញុំសូមជម្រាបបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** លោកបារម្ភថា លោកមិនចង់មើលឃើញនូវភាពទុក្ខលំបាក សេចក្តីវេទនា ដែលពួកគេទទួលរងនៅក្រោមអំណាចរបស់លោកឬ?

**ឆ៖** រឿងនេះវាពិតណាស់ ក៏ប៉ុន្តែអ្នកដែលមករងកម្មនៅទីនេះ ជាមនុស្សដែលខ្ញុំធ្លាប់ស្គាល់ពីមុនមក កាន់តែធ្វើឲ្យខ្ញុំរន្ធត់តក់ស្លុតណាស់ទៅទៀត ។

**ស៖** តើលោកចាត់ទុកថា ពេលនុំងអត្តចរិតរបស់លោកយ៉ាងដូចម្តេចទៅ?

**ឆ៖** អានេះ ខ្ញុំមិនដឹងគេហៅអីទេ ប៉ុន្តែ ខ្ញុំគ្រាន់តែជម្រាបថា ខ្ញុំបិទភ្នែក ខ្ញុំបិទត្រចៀក អត់ចង់ឃើញសេចក្តីពិត ព្រោះសេចក្តីពិតនេះ វាញុំញីអារម្មណ៍ខ្ញុំខ្លាំងពេក ខ្ញុំគេចយកសុខ ធ្វើមិនដឹង ធ្វើមិនឮ ធ្វើមិនឃើញ ។

**ស៖** តើយើងអាចនិយាយថា អ្វីដែលលោកធ្វើហ្នឹង ជាអំពើកំសាកដែរឬទេ?

**ឆ៖** ហួសពីកំសាកទៅទៀត មិនដឹងជារកពាក្យហៅយ៉ាងម៉េចទេ។ ត្រង់កំសាកខ្ញុំទទួល ក៏ប៉ុន្តែហួសពីកំសាកទៅទៀត ក្បត់មិត្ត ក្បត់ភក្តិ ក៏ថាបាន ។ ខ្ញុំបញ្ជាក់លើកក្រោយនេះ គឺថាខ្ញុំជម្រាបលោកចៅក្រមថា ក្បត់មិត្ត ក្បត់ភក្តិក៏ថាបានដែរ មិនមែនត្រឹមតែកំសាកទេ ។

**ស៖** អ៊ីចឹងជាទូទៅ តើលោកទទួលស្គាល់ទេថា ជនដែលត្រូវបានគេឃុំឃាំងនៅស-២១ ទទួលរងនូវការប្រព្រឹត្តិមកលើទាំងផ្លូវចិត្ត ទាំងផ្លូវកាយ ដោយសារតែអំពើអមនុស្សធម៌ ដែលត្រូវបានប្រព្រឹត្តមកលើពួកគេ គឺជាអំពើអមនុស្សធម៌ ដែលរួមបញ្ចូលទាំង ការមិនផ្តល់ម្ហូបអាហារឲ្យបរិភោគ ការមិនផ្តល់ការព្យាបាល ជាថ្នាំពេទ្យ អនាម័យ តើលោកទទួលស្គាល់ថា ការឃុំឃាំងអ្នកទោសអស់ទាំងហ្នឹង គឺពួកគេត្រូវទទួលរងនូវអំពើហឹង្សា និងភាពលំបាក ដ៏ខ្លាំងក្លានោះ ។ តើលោកទទួលស្គាល់ទេថា លក្ខខណ្ឌដែលបានដាក់ទៅលើពួកគេនោះ ទោះបីជាលក្ខណៈបុគ្គលក្តី ឬក៏លក្ខណៈជារួមក្តី ដែលត្រូវបានធ្វើឡើងដើម្បីបំបាក់ចិត្ត បំបាក់ផ្លូវសីលធម៌របស់គេ និងដើម្បីចាត់ទុកថា ពួកគេហ្នឹង ជាសត្វធាតុ ហើយពួកគេត្រូវបានដាក់នៅក្នុងលក្ខណៈមួយ ដែលពួកគេតែងតែមានភាពភ័យខ្លាចជានិច្ចនោះ ។

**ឆ៖** ឧក្រិដ្ឋកម្មប៉ុន្មានដែលលោកមានប្រសាសន៍នេះ ខ្ញុំទទួលទាំងអស់ ដោយគោរព អត់ប្រកែកទេ ។

[១៦:១៩:៥៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំអស់សំណួរទៀតហើយ សូមអរគុណ លោកប្រធាន ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ខ្ញុំមានមួយពីរសំណួរទៀតតែប៉ុណ្ណោះ ។ សំណួរទីមួយ ងាយទេថា តើអ្នកជាប់ឃុំឃាំងត្រូវបង្អត់អាហារ ដោយមូលហេតុត្រឹមតែកំហុសបន្តិចបន្តួច ដោយសារមិនគោរពបទបញ្ជានៃមន្ទីរឃុំឃាំង ក្នុងអំឡុងពេលនៃការឃុំឃាំងពួកគេដែរឬទេ? បង្អត់អាហារ មានន័យថា វាផ្ដាច់របបនៅក្នុងអំឡុងពេលមួយពេល ឬក៏ប៉ុន្មានពេលទៅតាមលក្ខណៈនៃកំហុសដែលមិនបានគោរពនូវបទបញ្ជាដែលដាក់ដោយ ហ៊ី អំពីថា ងើប ថា អង្គុយ មិនឲ្យនិយាយគ្នា អីចឹង ។ តើមានករណីហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ថ្វីត្បិតតែខ្ញុំមិនបានឃើញនឹងភ្នែក តែខ្ញុំជឿជាក់ថា ពិតជាមាន ចៀសមិនរួច ។ ខ្ញុំសូមទទួលស្គាល់ ហើយក៏មិនទម្លាក់កំហុសទៅលើគេទេ មិនទម្លាក់កំហុសទៅលើ ហ៊ី ទាំងស្រុងទេ ។

**ស៖** អរគុណ ។ របបអាហារដែលបានសួរដោយចៅក្រម ខាតរ៉ាយថ៍ ក៏ដូចជាចៅក្រម ឡាវែន៍រួចហើយ របបអាហារ គឺមិនតិចតួច មិនគ្រប់គ្រាន់ ដូចនេះហើយ អ្នកជាប់ឃុំឃាំងត្រូវស្លាប់ដោយដាច់អាហារ មានមួយចំនួនច្រើនដែរ ដែលថា មានការស្លាប់ដោយសារដាច់អាហារនោះ ។ តើមានករណីហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ពិតជាមានករណីនេះ ខ្ញុំទទួលអត់ប្រកែកទេ ។ មាន ។

**ស៖** អរគុណ ។ តើមានសេវាពេទ្យនៅមន្ទីរស-២១ ដែរឬទេ? ហើយបើមានស្ថានភាព ឬលក្ខណៈសម្បត្តិនៃផ្នែកនៃផ្នែកសេវាពេទ្យ ចំពោះជនជាប់ឃុំឃាំងអនុវត្តដូចម្ដេចដែរ?

[១៦:២២:៣៩]

**ឆ៖** សេវាពេទ្យ ជម្រាបប្រសាសន៍លោកប្រធាន! គឺមាន ក្នុងគោលបំណងថែរក្សាមនុស្សសម្រាប់តែសួរចម្លើយឲ្យចប់ប៉ុណ្ណឹងឯង ។ ប៉ុន្តែ ដល់ក្រោយមកបុគ្គលិកពេទ្យខ្លួនឯងហ្នឹង ក៏ចេះតែត្រូវចាប់បណ្ដើរៗទៅណ៎ា វាទៅជាសេវាពេទ្យមួយដែលរខេករខាក កម្មាភិបាលនៅក្នុងស-២១នេះ ពឹង

ផ្អែកទៅលើពេទ្យដែលជាអ្នកទោសទៅវិញ ។ ដំបូងឡើយ យើងខ្ញុំប្រើប្រើប្រាស់ បង វ័ត្ន គត់ ដល់ បង វ័ត្ន គត់ ត្រូវគេបញ្ជាឲ្យយកទៅកម្ទេចទៅ ត្រូវពឹងផ្អែកលើអ្នកផ្សេងទៀត ។ ចុងក្រោយបំផុតនេះ លើ ខ្ញុំពឹងផ្អែកលើក្មួយ នួន ជា ម្នាក់ឈ្មោះ ឡាច ស្អីទេ? ហៅនាង ថន នេះ ជាពេទ្យខ្ញុំ ហើយនិង ហាក់ ផាដេត ធ្វើជាពេទ្យដែរ ។ ដូច្នេះ សេវាពេទ្យប្រកបថ្នាំ គឺពីរនាក់ហ្នឹង ។ ហាក់ ផាដេត ហើយនិង ឡាច វ៉ារី ហ្នឹង ជាអ្នកប្រកបថ្នាំ ។ ឯចំណែក ពេទ្យរបស់ខ្ញុំ គ្រាន់តែជាអ្នកឲ្យថ្នាំទេ ខ្ញុំផ្ទាល់ខ្លួនឯងឈឺ ក៏ពឹង ពីរនាក់ហ្នឹង ។ នេះជម្រាបដោយត្រង់ សេវាពេទ្យវារខេករខាកអស់ហើយ ក្រោយពេលចាប់អស់ទៅ ហ្នឹង អត់មានបានកសាងថ្មីថែមទេ ។

សរុបមក ចំពោះបុគ្គលិកវាអ៊ីចឹង ឯចំណែកចំពោះអ្នកទោស គឺដូចខ្ញុំបានជម្រាបលោកប្រធាន អ៊ីចឹង ហើយគេព្យាបាលសម្រាប់តែសួរចម្លើយឲ្យចប់ ។ នេះតែប៉ុណ្ណឹង ក៏សុំជម្រាបដោយស្មោះថា វារខេក វាយ៉ាប់អ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ ឥឡូវនេះ គឺដល់ពេលត្រូវសម្រាកនៅពេលល្ងាចហើយ ។ ដោយម៉ោងបួនម្ភៃនាទី ហើយ ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ។ ហើយសវនាការលើក ទៅបន្ត នៅថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួនព្រឹក ។ ដូច្នេះ ភាគីទាំងអស់សូមអញ្ជើញចូលរួមនៅក្នុងកិច្ច ដំណើរការសវនាការ នៅថ្ងៃស្អែកតាមម៉ោងកំណត់នេះ ។

អនុរក្សមន្ទីរឃុំឃាំង សូមនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់ សាលសវនាការឲ្យបានមុនម៉ោងប្រាំបួននៅថ្ងៃស្អែក ៕

*[សវនាការផ្អាកនៅម៉ោង ១៦:២៥:១៥ នាទី]*